

# កើតមកជា ទាសករ

# Born Slaves

និពន្ធដោយ៖ ម៉ាធិន លូសើរ

Written by: Martin Luther

# កើតមកជាទាសករ

នេះជាសៀវភៅបង្រួមឲ្យខ្លី ហើយងាយអានដែលសង្ខេបពីសៀវភៅដ៏ល្បីល្បាញមួយឈ្មោះ
*“ចំណងនៃឆន្ទៈ”* ជាស្នាដៃនិពន្ធរបស់លោក ម៉ធិន លូស៊ើរ ដែលបានបោះពុម្ពនៅឆ្នាំ ១៥២៥។


រៀបចំដោយ ឃ្លីហ្វត ផន

ចូលរួមកែសំរួលដោយ

ចេ ភី អស៊ើរ , អនុបណ្ឌិត

អេច ចេ អាពលប៊ី



Grace Publications Trust
139 Grosvenor Avenue
LONDON N5 2NH
England

First published 1984

Second impression 1994

Third impression 1998

Distributed by:

EVANGELICAL PRESS

Grange Close,

Faverdale North

Darlington DL3 0PH

England

Printed in Great Britain by: Creative Print And Design (Wales), Ebbw Vale

# កម្មសិទ្ធិរបស់
# ព្រះវិហារមេត្តាករុណាព្រែកអំបិល

បកប្រែដោយ

**លោក អ៊ុច អភិរិន**

**លោក ហេល ប៉ៀល**

ផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធខ្មែរដោយ

លោក ឯម វណ្ណាថន

លោក អ៊ុច អភិរិន

រក្សាសិទ្ធិគ្រប់យ៉ាង

Copyright 2013

**Contact Information:**

www.thechurchofmercy.org
info@thechurchofmercy.org

Cambodia:
Pastor Chheng Nuon
mmcchheng@yahoo.com
(+855) 12 662 710

USA:
Pastor Bill Hale
hale.bill@live.com
(+1) 972 977 82 61

**Church of Mercy Books**
Road 21 Prek Talay,
Prek Ambel, Saang

Kandal, Cambodia

# មាតិកា


បុព្វកថា . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦

សេចក្តីផ្តើម . . . . . . . . . . . . . . . . . . . . . . . . . ៧

ជំពូក ១ . . . . . . . . . . . . . . . . . . . . . . . . . . . . . .១១

ជំពូក ២ . . . . . . . . . . . . . . . . . . . . . . . . . . . . . .៥១

ជំពូក ៤ . . . . . . . . . . . . . . . . . . . . . . . . . . . . .១១៥

សេចក្តីបន្ថែម . . . . . . . . . . . . . . . . . . . . . . . .១៣១


(ខ្លឹមសារ ដែលជាសំណោរបង្រួមមួយនៃសៀវភៅរបស់លូសើរ នៅក្នុងសៀវភៅនេះ គឺមាននៅក្នុងជំពូក ១ ដល់ ៥។ រីឯបុព្វកថា, សេចក្តីផ្តើម, និងសេចក្តីបន្ថែម ជាយោបល់បច្ចុប្បន្ននេះ លើសៀវភៅរបស់លូសើរវិញ។ Ed.)

# បុព្វកថា

## សំនួរ

សំនួរនោះគឺថា តើមនុស្សមានអ្វីម្យ៉ាងហៅថា “ឆន្ទៈសេរី” ដែរឬទេ? បើគ្មានជំនួយ តើមនុស្សអាចបែរមកឯព្រះគ្រីស្ទដើម្បីឲ្យបានសេចក្តីសង្គ្រោះពីអំពើបាបដោយខ្លួនឯងបានទេ? អែរ៉ាស្មឹសឆ្លើយថា “បាន!” តែលូសើរ ឆ្លើយតមវិញថា”ទេ!”។ លូសើរជឿជាក់ថា “ឆន្ទៈសេរី” វាយចំបេះដូងនៃសេចក្តីបង្រៀនតាមបទគម្ពីរដែលបង្រៀនអំពីសេចក្តីសង្គ្រោះដោយសារព្រះគុណតែមួយ តាមរយៈសេចក្តីជំនឿតែមួយ។ យើងត្រូវតែមានការជឿជាក់ដូចគ្នានេះដែរ។ យើងត្រូវខំប្រឹងប្រែងប្រឆាំងនឹង “ឆន្ទៈសេរី” ដូចជាលូសើរប្រឆាំងយ៉ាងដូច្នោះដែរ។ អែរ៉ាស្មឹសបាននិយាយថា “ខ្ញុំអាចចាត់ទុក “ឆន្ទៈសេរី” ជាអំណាចមួយនៃឆន្ទៈរបស់មនុស្សដែលមនុស្សអាចអនុវត្តដោយខ្លួនឯង លើសេចក្តីនានាដែលនាំទៅរកសេចក្តីសង្គ្រោះអស់កល្បជានិច្ច ឬបែរចេញពីសេចក្តីទាំងអស់នោះវិញ”។ ចំពោះការនេះ យើងត្រូវប្រឆាំងថា “ទេ! មនុស្សកើតមកជាទាសករនៃអំពើបាបរួចទៅហើយ!”មនុស្សមិនមានសេរីភាពទេ។

# សេចក្ដីផ្ដើម

## សារតារបស់សៀវភៅនេះ និងការប្រឆាំងជាមួយលោក អ៊ែរ៉ាស្មឹស

លោក ម៉ធីន លូស៊ើរ បានសរសេរសៀវភៅ ***ចំណងនៃឆន្ទៈ*** ដើម្បីឆ្លើយតបនឹងសេចក្ដីបង្រៀនរបស់លោក អ៊ែរ៉ាស្មឹសជាអ្នកពន្ធដែលរិះគន់ពួកកាតូលិកតែប្រឆាំងពួកប្រូតេស្តង់កែទម្រង់។ អ៊ែរ៉ាស្មឹសកើតនៅក្នុង Rotterdam ចន្លោះឆ្នាំ ១៤៦៦ និង ១៤៦៩។ អ៊ែរ៉ាស្មឹសធ្លាប់ជាបព្វជិតម្នាក់អស់រយៈពេល ៧ឆ្នាំ ហើយបន្ទាប់មកបានធ្វើដំណើរទៅកាន់ប្រទេសអង់គ្លេស។ នៅទីនោះគាត់បានជួបមនុស្សដែលធ្វើឲ្យគាត់ចង់បន្តសិក្សាភាសាក្រិករបស់គាត់។ នៅទីបញ្ចប់ អ៊ែរ៉ាស្មឹស បានសរសេរអត្ថបទដ៏សំខាន់មួយនៃព្រះគម្ពីរសញ្ញាថ្មីភាសាក្រិក (១៥១៦)។ គាត់បានបដិសេធចំពោះរបៀបព្រលយពាក្យពេចន៍នៃការបកស្រាយបទគម្ពីរ និងចំពោះពួកគ្រូបង្រៀនតាមក្រុមជំនុំដែលជឿលើភ័ព្វសំណាង។ គាត់បានប្រឆាំងនឹងការខ្ជិលច្រអូស និងអំពើអសីលធម៌នៅក្នុងវត្ត។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ អ៊ែរ៉ាស្មឹស មិនមែនជាអ្នកជឿដែលមានទំនាក់ទំនងជាមួយព្រះ ហើយយកព្រះគម្ពីរជាសំខាន់ទេ។ គាត់ជាអ្នកខាងមនុស្សសាស្ត្រនិយម ដែលជឿថាមនុស្សអាចរកបានសេចក្ដីសង្គ្រោះជំនួសការពឹងលើព្រះយេស៊ូវគ្រីស្ទតែមួយ ការសុគត និងសេចក្ដីរស់ឡើងវិញរបស់ទ្រង់។ អ៊ែរ៉ាស្មឹស ពិតជាចូលចិត្តចំពោះរបៀបធម្មតាចំពោះការបង្រៀនរបស់គ្រីស្ទានបែបធម្មតា ជាជាងរបៀបបង្រៀន

ដ៏ស្មុកស្មាញនៃអ្នកបង្រៀនវិជ្ជាព្រះគម្ពីរដ៏ជំនាញវិញ។ គាត់បានចៀសវាងប្រឆាំង ហើយអស់រយៈពេលយ៉ាងយូរដែលគាត់មិនបានបើកចំហបញ្ហាអំពី “ឆន្ទៈសេរី” ប៉ុន្តែនៅពេលដែលគាត់បានបើកចំហ វាជាការលំបាកមួយដែល ម៉ាធិន លូសើរ មិនអាចនឹងមិនអើពើបាន។

ម៉ាធិន លូសើរ បានកើតនៅក្រុង Saxony ហើយប្រហែលក្មេងជាង លោក អ៊ែរ៉ាស្មឹស ១៩ ឆ្នាំ។ នៅពេលលូសើរនៅជាសង្ឃនៅឡើយ គាត់មានបទពិសោធន៍ដ៏អស្ចារ្យមួយអំពីដំណឹងល្អនៃព្រះគុណរបស់ព្រះ។ តាំងពីពេលនោះមក គាត់បានដឹងថា គ្រប់ទាំងបទពិសោធន៍ និងជំនឿត្រូវតែសាកដោយអំណាចនៃបទគម្ពីរសិន។ គាត់បានដឹងថា សេចក្តីសង្រ្គោះគឺបានដោយសារ “ព្រះគុណ ដែលអ្នករាល់គ្នាបានសង្រ្គោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន” (អេភេសូរ ២:៨-៩)។ បទពិសោធន៍របស់គាត់បញ្ជាក់ពីជំនឿនោះ។

លូសើរ ជាសាស្ត្រាចារ្យ ជាអ្នកប្រាជ្ញព្រះគម្ពីរ និងជាគ្រូគង្វាលម្នាក់។ មនុស្សរបស់គាត់ដឹងថា គាត់មានអារម្មណ៍យ៉ាងណាពីអ្វីដែលគាត់បានអធិប្បាយ។ គាត់មិនមែនជាអ្នកប្រាជ្ញដែលរឹងស្ងួតនោះទេ។ គាត់ដឹងពីសំពាធនៃភាពអស់កល្បរាល់ពេលដែលគាត់អធិប្បាយ។ ជួនកាល ការនេះជំរុញឲ្យគាត់ធ្វើការដែលគេមិននិយម ហើយគ្រោះថ្នាក់។ គាត់បានត្រៀមខ្លួនរួចជាស្រេច ក្នុងការឈរឡើងសំរាប់សេចក្តីពិតរបស់ព្រះ ប្រឆាំងនឹងលោកិយទាំងមូល។

នៅពេលដំបូង អេរ៉ាស្មឹស ហាក់ដូចជានៅខាងរបស់ លូស៊ើរដែរ ព្រោះទាំងពីរនាក់បានបដិសេធនឹងបញ្ហាជាច្រើនរបស់ពួកជំនុំរ៉ូម៉ាំងដូចគ្នា។ ប៉ុន្តែ លូស៊ើរបានប្រឆាំងកាន់តែខ្លាំងថែមទៀត ចំពោះការបង្រៀនរបស់ពួករ៉ូម៉ាំងដែលថាសេចក្តីសង្គ្រោះបានមកដោយការប្រព្រឹត្ត។ លោក បានទាមទារថា “មនុស្សសុចរិតនឹងរស់នៅ ដោយអាងសេចក្តីជំនឿ” (រ៉ូម ១:១៧)។ លោក អេរ៉ាស្មឹស នៅតែនៅក្នុងពួកជំនុំរ៉ូម៉ាំង ហើយជាអ្នកប្រាជ្ញម្នាក់ ដែលនៅទីបំផុតគាត់បានយល់ព្រមដោយស្ម័គ្រពីចិត្តទៅតាមសំពាធរបស់ពួកជំនុំរបស់គាត់ដោយថ្លែងពីការបង្រៀនអំពី “ឆន្ទៈសេរី”។ នៅក្នុងការបដិសេធនៃសំណូមពររបស់លូស៊ើរមិនឲ្យគាត់បានធ្វើដូច្នោះ នោះគាត់បានសរសេរ**ការពិភាក្សារបស់គាត់អំពី “ឆន្ទៈសេរី”** នៅឆ្នាំ ១៥២៤។ អេរ៉ាស្មឹស បានសរសេរទៅកាន់ ហិនរី ទី៧ថា “ការសម្រេចមិនអាចផ្លាស់ប្តូរបានទេ។ កូនសៀវភៅស្តីអំពី “ឆន្ទៈសេរី” បានឃើញពន្លឺថ្ងៃហើយ”។ សៀវភៅនោះបានធ្វើឲ្យសម្តេចប៉ាប និងអធិរាជ្យរ៉ូម៉ាំងពេញចិត្ត ហើយនិងមានការកោតសរសើរដោយហិនរីទី៧ យ៉ាងខ្លាំង។

ឥឡូវនេះ លូស៊ើរបានប្រកាសថា អេរ៉ាស្មឹស ជាសត្រូវរបស់សេចក្តីជំនឿតាមដំណឹងល្អ។ ព្រះជាម្ចាស់គ្រប់គ្រងលើការមិនចុះសម្រុងគ្នារវាងមនុស្សពីរនាក់នេះដើម្បីសេចក្តីល្អនៃនគររបស់ទ្រង់។ វាបានបង្កើតសេចក្តីថ្លែងការដ៏អស្ចារ្យមួយនៃគោលលទ្ធិតាមដំណឹងល្អដែលបានធ្វើឲ្យក្រុមជំនុំរបស់ព្រះគ្រីស្ទរីកចំរើនតាំងពីពេលនោះមក គឺសៀវភៅដែលមានឈ្មោះថា **ចំណងនៃឆន្ទៈ** របស់លូស៊ើរ។ នៅទីនេះ យើងសូមផ្តល់នូវសេចក្តីសង្ខេបនៃសៀវភៅដ៏អស្ចារ្យនេះ។ យើងបាន

នៅតែបន្តរបៀបរបស់លូស៊ើរ ប៉ុន្តែមិនធ្វើតាមបញ្ញារបស់លូស៊ើរនោះទេ។ យើងបានចាប់ផ្តើមពីកន្លែងដែលលូស៊ើរបានឈប់ ដោយសង្ខេបការបង្រៀនដ៏វិជ្ជមានរបស់លោកអំពីចំណងនៃឆន្ទៈ។ យើងបានធ្វើតាមជាមួយផ្នែកដទៃទៀតដែលលូស៊ើរបាននិយាយ ហើយបន្ទាប់មកបង្ហាញថា ការវែកញែករបស់អ៊ែរ៉ាស្មឹសគឺមិនត្រឹមត្រូវ។ ជាធម្មតា របៀបរបស់លូស៊ើរអាចនឹងធ្វើឲ្យយើងបន្ថែមពាក្យពេចន៍ផ្សេងៗ រាល់ពេលដែលគាត់ប្រើពាក្យ "ឆន្ទៈសេរី"។ ឧទាហរណ៍៖ ឆន្ទៈសេរី "*ដែលស្មានថាមាន*"។ ប៉ុន្តែយើងបានជ្រើសរើសដើម្បីឆ្លុះបញ្ចាំងអត្ថន័យរបស់លូស៊ើរដោយប្រើសញ្ញាអភន្តរៈ ដូចជា "ឆន្ទៈសេរី"។ ហើយនៅក្នុងជំពូក២, ៣ និង៩ យើងនៅតែបន្តសំដីផ្ទាល់របស់លូស៊ើរ ដោយរក្សាឲ្យមានការទាក់ទងជិតស្និតបំផុតតាមតែអាចធ្វើបានចំពោះបរិយាកាសនៃសៀវភៅរបស់គាត់។

យើងមិនបានដាក់បញ្ចូលគ្រប់ទាំងការវែកញែករបស់លូស៊ើរនោះទេ ព្រោះបើធ្វើយ៉ាងនោះ នឹងធ្វើឲ្យសៀវភៅនេះកាន់តែក្រាស់លើសពីភាពចាំបាច់របស់វា។

# ជំពូក ១

## អ្វីដែលបទគម្ពីរបានបង្រៀន

*ការវែកញែក ១ : ទោសសាកលរបស់មនុស្សជាតិ បង្ហាញឲ្យឃើញថា*

“ឆន្ទៈសេរី”មិនពិត

*ការវែកញែក ២ : ច្បាប់សាកលនៃអំពើបាប បង្ហាញឲ្យឃើញថា “ឆន្ទៈសេរី” មិនពិត*

*ការវែកញែក ៣ : “ឆន្ទៈសេរី”មិនអាចទទួលបាននូវការទទួលស្គាល់ពីព្រះជាម្ចាស់ តាមរយៈការកាន់តាមសីលធម៌ និងក្រិត្យវិន័យនៃពិធីបុណ្យបានឡើយ*

*ការវែកញែក ៤ : ក្រិត្យវិន័យត្រូវបានបង្កើតឡើងដើម្បីនាំមនុស្សឲ្យស្គាល់ ព្រះគ្រីស្ទ ដោយសារផ្តល់ចំណេះដឹងអំពីអំពើបាប*

*ការវែកញែក ៥ : គោលលទ្ធិនៃសេចក្តីសង្រ្គោះដោយសារជំនឿងល់ ព្រះគ្រីស្ទបាន បង្ហាញឲ្យឃើញថា “ឆន្ទៈសេរី” មិនពិត*

*ការវែកញែក ៦ : មិនមានកន្លែងសំរាប់ គំនិតនៃបុណ្យកុសល ឬធ្វើល្អបានល្អនោះទេ*

*ការវែកញែក ៧ : “ឆន្ទៈសេរីមិនមានតំលៃ ពីព្រោះការប្រព្រឹត្តិមិនមានការទាក់ទងនឹង សេចក្តីសុចរិតរបស់មនុស្សនៅចំពោះព្រះ*

*ការវែកញែក ៨ : ការវែកញែកមួយក្តាប់តូច*

*ការវែកញែក ៩ : សាវក ប៉ុល បាននិយាយយ៉ាងដាច់ខាត ក្នុងការដែលមិនគាំទ្រងល់*

"ឆន្ទៈសេរី"

ការវែកញែក ១០ : សណ្ឋានមនុស្សដែលគ្មានព្រះវិញ្ញាណ បង្ហាញថា "ឆន្ទៈសេរី" មិនអាចធ្វើអ្វីខាងឯវិញ្ញាណបានឡើយ

ការវែកញែក ១១ : អស់អ្នកដែលមកស្គាល់ព្រះគ្រីស្ទ មុននេះមិនបានគិតពីទ្រង់ស្វែង រកទ្រង់ ឬក៏រៀបចំខ្លួនសំរាប់ទ្រង់ឡើយ

ការវែកញែក ១២ : សេចក្តីសង្គ្រោះនៃលោកិយដែលមានបាបគឺដោយសារព្រះគុណនៃព្រះគ្រីស្ទ តាមរយៈជំនឿតែមួយប៉ុណ្ណោះ

ការវែកញែក ១៣ : ករណីរបស់លោក នីកូឌីម នៅក្នុងគម្ពីរយ៉ូហាន៣ ទាស់នឹង "ឆន្ទៈសេរី"

ការវែកញែក ១៤ : "ឆន្ទៈសេរី" គ្មានប្រយោជន៍ទេ ដោយព្រោះសេចក្តីសង្គ្រោះមកដោយ សារព្រះគ្រីស្ទតែមួយអង្គប៉ុណ្ណោះ

ការវែកញែក ១៥ : មនុស្សមិនអាចជឿដំណឹងល្អបានទេ ដូច្នេះគ្រប់ការខិតខំប្រឹងប្រែងរបស់គេ មិនអាចជួយសង្គ្រោះគេបានឡើយ

ការវែកញែក ១៦ : ការមិនជឿជាសាកល បង្ហាញថា "ឆន្ទៈសេរី" គឺមិនពិត

ការវែកញែក ១៧ : អំណាចនៃ "សាច់ឈាម" នៅក្នុងជីវិតរបស់អ្នកជឿពិតប្រាកដម្នាក់បានបង្ហាញថា មិនគាំទ្រដល់ "ឆន្ទៈសេរី"

ការវែកញែក ១៨ : ការស្គាល់ថា សេចក្តីសង្គ្រោះមិនអាស្រ័យលើ "ឆន្ទៈសេរី" គឺជាសេចក្តីកំសាន្តចិត្ត

ការវែកញែក ១៩ : គេមិនអាចធ្វើឲ្យកិត្តិយសរបស់ព្រះ បាត់បង់សិរីល្អបានឡើយ

បទគម្ពីរប្រៀបដូចជា កងទ័ពជាច្រើន ដែលច្បាំង នឹងគំនិតដែលមនុស្សមាន គឺជា "ឆន្ទៈសេរី" មួយ ដើម្បីជ្រើសរើស ហើយនិងទទួលសេចក្តីសង្គ្រោះ។ ប៉ុន្តែ វានឹងគ្រប់គ្រាន់សំរាប់ខ្ញុំ ដើម្បីនាំយកមេបញ្ជាការពីរនាក់ មកឯចំបាំងនេះគឺ សាវក ប៉ុល និងសាវក យ៉ូហាន ព្រមទាំងពលទាហានរបស់ពួកគាត់មួយចំនួនទៀត។

## ការវែកញែក ១ : ទោសសាកលរបស់មនុស្សជាតិ បង្ហាញឲ្យឃើញថា "ឆន្ទៈសេរី" មិនពិត

នៅក្នុងគម្ពីររ៉ូម ១:១៨ សាវក ប៉ុល បានបង្រៀនថា មនុស្សទាំងអស់ ដោយគ្មានការលើកលែងអ្នកណាម្នាក់ សមនឹងទទួលទណ្ឌកម្មពីព្រះជាម្ចាស់។ "សេចក្តីក្រោធរបស់ព្រះបានសំដែងមកពីស្ថានសួគ៌ ទាស់នឹងគ្រប់ទាំងសេចក្តីទមិឡល្មើស និងសេចក្តីទុច្ចរិតរបស់មនុស្ស ដែលគេបង្ខាំងសេចក្តីពិតដោយសេចក្តីទុច្ចរិត"។ ប្រសិនបើមនុស្សទាំងអស់មាន "ឆន្ទៈសេរី" ប៉ុន្តែមនុស្សទាំងអស់ដោយគ្មានការលើកលែងអ្នកមួយ សុទ្ធតែនៅក្រោមសេចក្តីក្រោធរបស់ព្រះ នោះមានន័យថា "ឆន្ទៈសេរី" នាំពួកគេទៅឯទិសដៅតែមួយប៉ុណ្ណោះ គឺ "សេចក្តីទមិឡល្មើស និងសេចក្តីទុច្ចរិត"។ ដូច្នេះ តើអំណាចនៃ"ឆន្ទៈសេរី" ដែលជួយឲ្យពួកគេបានធ្វើល្អនោះ នៅឯណា? ប្រសិនបើ "ឆន្ទៈសេរី" មានប្រាកដមែន វាហាក់ដូចជាមិនអាចជួយមនុស្សទៅឯសេចក្តីសង្គ្រោះឡើយ ពីព្រោះវានៅតែទុកឲ្យពួកគេនៅក្រោមសេចក្តីក្រោធរបស់ព្រះដដែល។

ប៉ុន្តែ អ្នកខ្លះចោទប្រកាន់ខ្ញុំថា មិនបានធ្វើតាមសាវក ប៉ុល ឲ្យបានត្រឹមត្រូវគ្រប់គ្រាន់ទៅវិញ។ ពួកគេប្រកាសថា ពាក្យរបស់សាវក ប៉ុលដែលថា "គ្រប់ទាំងសេចក្ដីទមិឡល្មើស និងសេចក្ដីទុច្ចរិតរបស់មនុស្ស ដែលគេបង្ខាំងសេចក្ដីពិតដោយសេចក្ដីទុច្ចរិត" មិនមានន័យថា មនុស្សទាំងអស់ដោយគ្មានការលើកលែងអ្នកណាម្នាក់ មានទោសនៅចំពោះព្រះនោះទេ ។ ពួកគេបានវែកញែកថា បទនេះធ្វើឲ្យវាអាចទៅរួច ដែលមនុស្សមួយចំនួនមិនបាន "បង្ខាំងសេចក្ដីពិតដោយសេចក្ដីទុច្ចរិត" ។ ប៉ុន្តែសាវក ប៉ុល កំពុងតែប្រើទំរង់ពាក្យមួយនៃភាសាហេព្រើរ ដែលមានន័យថា សេចក្ដីទុច្ចរិតនៃមនុស្សទាំងអស់វិញ។ លើសពីនេះទៅទៀត ចូរសំគាល់អ្វីដែលសាវក ប៉ុល បានសរសេរនៅខាងដើមនៃបទគម្ពីរនេះ។ នៅក្នុង ខ ១៦ សាវក ប៉ុល ប្រកាសថាដំណឹងល្អ "ជាព្រះចេស្ដានៃព្រះ សំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ"។ ការនេះត្រូវតែមានន័យថា វាចេញមកពីអំណាចនៃព្រះនៅក្នុងដំណឹងល្អ គ្មានអ្នកណាម្នាក់មានកំលាំងហើយបែរទៅរកព្រះដោយខ្លួនឯងបានទេ។ សាវក ប៉ុល បន្តនិយាយទៀតថា ការនេះសំដៅទាំងសាសន៍យូដា និងទាំងសាសន៍ក្រិកផង។ ពួកយូដា ចេះគ្រប់ទាំងសេចក្ដីលំអិតនៃក្រិត្យវិន័យរបស់ព្រះ ប៉ុន្តែការនេះមិនអាចសង្គ្រោះពួកគេពីសេចក្ដីក្រោធរបស់ព្រះបានឡើយ។ ពួកក្រិកចូលចិត្តអត្ថប្រយោជន៍នៃវប្បធម៌ដ៏អស្ចារ្យ ប៉ុន្តែការទាំងអស់នេះមិនអាចនាំឲ្យពួកគេចូលទៅជិតព្រះបានឡើយ។ មានពួកសាសន៍យូដា និងពួកសាសន៍ក្រិក បានខិតខំព្យាយាមធ្វើឲ្យខ្លួនពួកគេបានសុចរិតជាមួយនឹងព្រះ។ ប៉ុន្តែទោះអត្ថប្រយោជន៍ទាំងអស់ និង "ឆន្ទៈសេរី" របស់ពួកគេក៏ដោយ ពួកគេនៅតែបរាជ័យទាំងស្រុងដដែល។ សាវក ប៉ុលមិនបានស្ទាក់ស្ទើរក្នុងការថ្កោលទោស

ពួកគេទាំងអស់គ្នានោះទេ។

បន្ទាប់មក ចូរកត់សំគាល់នៅក្នុងខ ១៧ សាវក ប៉ុល បាននិយាយថា "សេចក្តីសុចរិតនៃព្រះ បានសំដែងមក" ហើយ។ ដូច្នេះព្រះបង្ហាញសេចក្តីសុចរិតរបស់ទ្រង់ដល់មនុស្ស។ ប៉ុន្តែព្រះមិនល្ងីល្ងើនោះទេ។ ប្រសិនបើមនុស្សមិនត្រូវការជំនួយរបស់ព្រះ នោះទ្រង់នឹងមិនចំណាយពេលឥតប្រយោជន៍ផ្តល់សេចក្តីសុចរិតនោះមកដល់មនុស្សនោះទេ។ រាល់វេលាណាមនុស្សបានប្រែចិត្តជឿ នោះគឺដោយសារតែព្រះយាងមកឯពួកគេ ហើយយកឈ្នះភាពព្រងើយកន្តើយរបស់ពួកគេដោយការសំដែងដំណឹងល្អដល់ពួកគេ។ ដោយគ្មានការទាំងអស់នេះ ពួកគេមិនអាចសង្គ្រោះខ្លួនឯងបានឡើយ។ នៅក្នុងប្រវត្តិសាស្រ្តរបស់មនុស្ស គ្មានអ្នកណាម្នាក់ បានគិតឃើញដោយខ្លួនឯង ពីសេចក្តីពិតនៃសេចក្តីក្រោធរបស់ព្រះ ដូចជាបានបង្រៀននៅក្នុងបទគម្ពីរឡើយ។ គ្មានអ្នកណាម្នាក់ធ្លាប់ស្រមើស្រមៃចង់ទទួលបាននូវសេចក្តីមេត្រីជាមួយព្រះ តាមរយៈព្រះជន្ម និងកិច្ចការដ៏គ្មានពីររបស់ព្រះអង្គសង្គ្រោះ ដែលទ្រង់ជាមនុស្សនិងជាព្រះ គឺជាព្រះយេស៊ូវគ្រីស្ទ នោះទេ។ ជាការពិតណាស់ ពួកសាសន៍យូដា បានបដិសេធព្រះគ្រីស្ទ ទោះទាំងសេចក្តីបង្រៀនរបស់ហោរារបស់ពួកគេក៏ដោយ។ វាហាក់ដូចជា ការល្អដែលពួកយូដា និងសាសន៍ដទៃមួយចំនួនបានទទួលនោះ បញ្ឈប់ពួកគេស្វែងរកព្រះនៅក្នុងរបៀបពួកគេ ពីព្រោះពួកគេត្រូវបានកំណត់ឲ្យធ្វើអ្វីៗទៅតាមរបៀបរបស់ខ្លួន។ ដូច្នេះនៅពេលណាដែល "ឆន្ទៈសេរី" កាន់តែព្យាយាម អ្វីៗកាន់តែអាក្រក់ឡើងទៅទៀត។

មិនមានក្រុមមនុស្សទីបី នៅចន្លោះអ្នកជឿ និងអ្នកមិនជឿឡើយ ជាក្រុម

ដែលមានសមត្ថភាពសង្គ្រោះខ្លួនឯង។ ពួកសាសន៍យូដា និងសាសន៍ក្រិក តំណាងឲ្យមនុស្សជាតិទាំងអស់ ហើយពួកគេទាំងអស់គ្នានៅក្រោមសេចក្ដីក្រោធរបស់ព្រះ។ គ្មានអ្នកណាម្នាក់មានសមត្ថភាពបែរទៅរកព្រះឡើយ។ ទ្រង់ត្រូវតែបង្ហាញអង្គទ្រង់ដល់ពួកគេជាមុនសិន។ ប្រសិនបើ "ឆន្ទៈសេរី"ពិតជាអាចទៅរួចក្នុងការរកឃើញសេចក្ដីពិតមែន នោះច្បាស់ជាមានជនជាតិយូដាណាម្នាក់នៅត្រង់ណាមួយបានទទួលជោគជ័យយ៉ាងនេះជាមិនខានហើយ! ការត្រិះរិះរកហេតុផលដ៏ខ្ពស់បំផុតរបស់ពួកសាសន៍ដទៃ និងការខិតខំប្រឹងប្រែងដ៏ខ្លាំងបំផុតរបស់ពួកសាសន៍យូដា (រ៉ូម ១:២១; ២:២៣, ២៨ និង ២៩) មិននាំឲ្យពួកគេបានមកជិតសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទទេ។ ពួកត្រូវទទួលការផ្ដន្ទាទោសជាមនុស្សមានបាបជាមួយនឹងអ្នកដទៃផ្សេងៗឯទៀតដែរ។ ប្រសិនបើមនុស្សទាំងអស់មាន "ឆន្ទៈសេរី" ហើយមនុស្សទាំងអស់មានទោស ហើយត្រូវទទួលការផ្ដន្ទាទោសនោះមានន័យថា "ឆន្ទៈសេរី" ពុំមានអំណាចនាំពួកគេមកឯសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទបានទេ។ ដូច្នេះឆន្ទៈរបស់ពួកគេមិនសេរីទេ។

### ការវែកញែក ២ : ច្បាប់សាកលនៃអំពើបាប បង្ហាញឲ្យឃើញថា "ឆន្ទៈ សេរី" មិនពិត

យើងត្រូវតែឲ្យសាវក ប៉ុល ពន្យល់សេចក្ដីបង្រៀនផ្ទាល់របស់គាត់។ នៅក្នុងគម្ពីររ៉ូម ៣:៩ គាត់បាននិយាយថា៖ "តើដូចម្ដេចយើងល្អជាងគេឬទេ? មិនមែនទេ ដ្បិតយើងខ្ញុំបានចោទប្រកាន់រួចហើយថា ទោះទាំងសាសន៍យូដា និងសាសន៍ក្រិកផង

សុទ្ធតែនៅក្រោមអំពើបាប”។ មនុស្សទាំងអស់មិនត្រឹមតែត្រូវបានប្រកាសថាមានទោសនៅចំពោះទ្រង់ប៉ុណ្ណោះទេ ពួកគេក៏ជាបាវបំរើនៃអំពើបាបដែលធ្វើឲ្យពួកគេមានទោសដែរ។ ការនេះរួមបញ្ចូលទាំងសាសន៍យូដាដែលបានគិតថាខ្លួនឯងមិនមែនជាបាវបំរើរបស់អំពើបាបដោយព្រោះពួកគេមានក្រិត្យវិន័យនៃព្រះ ផងដែរ។ ដោយព្រោះទាំងពួកសាសន៍យូដា និងសាសន៍ក្រិក មិនអាចដោះខ្លួនឯងឲ្យរួចពីទាសភាពនេះបាន ជាការពិតណាស់មានន័យថា នៅក្នុងមនុស្សគ្មានអំណាចណាមួយដែលអាចជួយខ្លួនពួកគេ ដើម្បីឲ្យធ្វើល្អបានទេ។

ទាសភាពនៃអំពើបាបជាសាកលនេះ រួមបញ្ចូលទាំងពួកអ្នកដែលហាក់ដូចជាល្អបំផុត និងទៀងត្រង់បំផុតផងដែរ។ ទោះបីជាការល្អដ៏ច្រើន ដែលមនុស្សអាចទទួលបានក៏ដោយ នេះមិនមែនជាការដូចគ្នាទៅនឹងចំណេះដឹងអំពីព្រះនោះទេ។ ការដ៏ល្អបំផុតអំពីមនុស្ស គឺជាហេតុផលរបស់ពួកគេ និងជាឆន្ទៈរបស់ពួកគេ ប៉ុន្តែត្រូវតែទទួលស្គាល់ថា ផ្នែកដ៏ល្អបំផុតនេះ គឺជាសេចក្ដីពុករលួយវិញ។ សាវក ប៉ុលបាននិយាយនៅក្នុងគម្ពីររ៉ូម ៣:១០-១២ ថា៖ “គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលប្រព្រឹត្តិតាមសេចក្ដីសប្បុរសសោះ តែម្នាក់ក៏គ្មានផង”។ អត្ថន័យនៃព្រះបន្ទូលត្រង់នេះ បានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ណាស់។ វានៅក្នុងហេតុផល និងឆន្ទៈដែលព្រះត្រូវបានគេស្គាល់។ ប៉ុន្តែគ្មានមនុស្សខាងឯសាច់ឈាមណាម្នាក់ ស្គាល់ព្រះបានទេ។ ដូច្នេះយើងត្រូវតែសន្និដ្ឋានថា ឆន្ទៈរបស់មនុស្សបានខូចអាក្រក់ហើយ មនុស្សមិនអាចស្គាល់ព្រះ ឬធ្វើឲ្យគាប់ដល់ព្រះហឫទ័យព្រះ ដោយខ្លួនឯងបានឡើយ។ ប្រហែល

ជាមានបុគ្គលខ្លះក្លាហាននឹងនិយាយថា ពួកយើងអាចធ្វើបានច្រើនជាង គឺយើងធ្វើបានយ៉ាងពិតប្រាកដ។ ត្រង់កន្លែងនេះយើងផ្តោតលើអ្វីដែលយើងអាចធ្វើបាន មិនមែនអ្វីដែលយើងអាច ឬមិនអាចធ្វើបានយ៉ាងពិតប្រាកដនោះឡើយ។ សាវក ប៉ុល បានដកស្រង់បទគម្ពីររ៉ូម ៣:១០-១២ ថា នឹងមិនអនុញ្ញាតិឲ្យយើងធ្វើការបែងចែកយ៉ាងដូច្នេះនោះទេ។ ព្រះផ្តន្ទាទោសទាំងអសមត្ថភាពដ៏មានបាបរបស់មនុស្ស និងទាំងសកម្មភាពពុករលួយរបស់ពួកគេផងដែរ។ ប្រសិនបើមនុស្សអាចព្យាយាមផ្លាស់ទីមកឯផ្លូវរបស់ព្រះបានសូម្បីតែបន្តិចនោះ នឹងមិនបាច់ត្រូវការឲ្យព្រះបានសង្គ្រោះពួកគេនោះឡើយ។ ទ្រង់អាចនឹងអនុញ្ញាតិឲ្យពួកគេសង្គ្រោះខ្លួនឯង ប៉ុន្តែគ្មានអ្នកណាម្នាក់អាចព្យាយាមធ្វើបានទេ។

នៅក្នុងគម្ពីររ៉ូម ៣:១៩ សាវក បានប្រកាសថា គ្រប់ទាំងមាត់ត្រូវបានបិទជិត ពីព្រោះគ្មានអ្នកណាអាចប្រកែកនឹងសេចក្តីជំនុំជំរះរបស់ព្រះចំពោះពួកគេបានទេ ដ្បិតគ្មានអ្វីមួយនៅក្នុងមនុស្ស ដែលព្រះអាចសរសើរបានទេ- មិនមានសោះ សូម្បីតែឆន្ទៈសេរីមួយបែរទៅរកព្រះក៏គ្មានដែរ។ ប្រសិនអ្នកណាម្នាក់និយាយថា៖ “ខ្ញុំមានសមត្ថភាពបន្តិចបន្តួចបែរទៅរកព្រះដែរ” នោះមានន័យថាគាត់គិតថាមានអ្វីមួយនៅក្នុងគាត់ ដែលព្រះត្រូវតែសរសើរ និងមិនផ្តន្ទាទោស។ មាត់របស់គាត់នឹងមិនបិទទេ! ប៉ុន្តែការនេះបញ្ច្រាសទៅនឹងបទគម្ពីរ។

ព្រះបានមានបន្ទូលថា មាត់*ទាំងអស់*ត្រូវបានបិទទេ។ វាមិនគ្រាន់តែសំដៅលើក្រុមមនុស្សជាក់លាក់ណាមួយនោះទេ ហើយក៏មិនគ្រាន់តែសំដៅលើពួកផារិស៊ីនៅក្នុងចំណោមពួកសាសន៍យូដាដែលត្រូវផ្តន្ទាទោសនោះដែរ។ ប្រសិនបើវាពិត

ជាសំដៅអញ្ចឹងមែននោះ នោះមានន័យថា ពួកយូដាដែលនៅសល់អាចនឹងមាន អំណាចផ្ទាល់ខ្លួនរបស់ពួកគេខ្លះ ដើម្បីកាន់តាមក្រិត្យវិន័យ ហើយដើម្បីចៀសឲ្យរួចពីភាពមានទោស។ ប៉ុន្តែសូម្បីតែមនុស្សដែលល្អបំផុត ក៏ត្រូវបានទទួលការផ្តន្ទាទោសពីបទទមិឡល្មើសរបស់ពួកដែរ។ ពួកគេស្លាប់ខាងឯព្រលឹងវិញ្ញាណ ដូចជាពួកអ្នកដែលមិនខំព្យាយាមកាន់តាមក្រិត្យវិន័យរបស់ព្រះយ៉ាងដូច្នោះដែរ។ មនុស្សទាំងអស់ជាពួកទមិឡល្មើស និងមានទោស ហើយពួកគេសមនឹងទទួលទណ្ឌកម្មពីព្រះ។ ការទាំងអស់នេះពិតជាបានបង្ហាញយ៉ាងច្បាស់ណាស់ ដែលគ្មានអ្នកណាម្នាក់អាចខ្សឹបតវ៉ានឹងចំនុចទាំងអស់នេះបានឡើយ។

## ការវែកញែក ៣ : "ឆន្ទៈសេរី" មិនអាចទទួលបាននូវការទទួលស្គាល់ពី ព្រះជាម្ចាស់តាមរយៈការកាន់តាមសីលធម៌ និងក្រឹត្យវិន័យ នៃពិធីបុណ្យ បានឡើយ

ខ្ញុំសូមវែកញែកថា នៅពេលដែលសាវក ប៉ុល បាននិយាយនៅក្នុងគម្ពីររ៉ូម ៣:២០-២១ "គ្មានមនុស្សណាបានរាប់ជាសុចរិតនៅចំពោះទ្រង់ដោយអាងការប្រព្រឹត្តិតាមក្រិត្យវិន័យនោះឡើយ" គាត់សំដៅលើច្បាប់សីលធម៌ (ក្រិត្យវិន័យទាំងដប់ប្រការ) និងច្បាប់នៃពិធីផ្សេងៗ។ មានគំនិតមួយដែលសាវក ប៉ុលចង់និយាយគឺច្បាប់នៃពិធីផ្សេងៗ ដូចជាពិធីថ្វាយយញ្ញបូជាសត្វ និងការថ្វាយបង្គំដល់ព្រះវិហារ។ វាគួរឲ្យចាប់អារម្មណ៍លើសពីធម្មតា ដែលមនុស្សបានហៅ ជារ៉ូមជាអ្នកដែលបង្កើតគំនិតនេះ ថាជាអ្នកដ៏បរិសុទ្ធ! ខ្ញុំប្រហែលជាអាចនឹងហៅគាត់ថាជាអ្នកមួយផ្សេងវិញ! ជារ៉ូម បាននិយាយថា ការសុគតរបស់ព្រះគ្រីស្ទបានបញ្ចប់ដោយលទ្ធភាពនៃការ

រាប់ជាសុចរិត ដោយការកាន់តាមច្បាប់នៃពិធីនានា។ ប៉ុន្តែគាត់បានចំហចោលនូវលទ្ធភាពនៃការរាប់ជាសុចរិត ដោយកាន់តាមច្បាប់សីលធម៌ ដោយអាងកំលាំងខ្លួនរបស់ពួកយើងផ្ទាល់ ដោយគ្មានជំនួយរបស់ព្រះទៅវិញ។

ចម្លើយរបស់ខ្ញុំគឺថា ប្រសិនបើសាវក ប៉ុល គ្រាន់តែនិយាយសំដៅលើច្បាប់នៃពិធីនានាប៉ុណ្ណោះនោះ ការវែកញែករបស់គាត់នឹងគ្មានន័យសោះ។ សាវក ប៉ុល កំពុងតែខំវែកញែកថា មនុស្សទាំងអស់ទុច្ចរិត ហើយត្រូវការព្រះគុណពិសេសរបស់ព្រះ គឺសេចក្តីស្រឡាញ់ ប្រាជ្ញា ហើយនិងអំណាចនៃព្រះ ដែលការទាំងអស់នេះហើយ ព្រះបានសង្គ្រោះយើងឲ្យរួច។ លទ្ធផលនៃគំនិតរបស់ជារ៉ូម អាចនឹងជាព្រះគុណរបស់ព្រះ ដែលត្រូវការដើម្បីសង្គ្រោះយើងឲ្យរួចពីពិធីបុណ្យផ្សេងៗ តែមិនសង្គ្រោះឲ្យរួចពីច្បាប់សីលធម៌ឡើយ។ យើងមិនអាចកាន់តាមច្បាប់សីលធម៌ ដាច់ចេញពីព្រះគុណបានឡើយ។ អ្នកអាចបន្លាចមនុស្សឲ្យកាន់តាមពិធីផ្សេងៗ ប៉ុន្តែគ្មានអំណាចមនុស្សណាមួយអាចបង្ខំឲ្យពួកគេកាន់តាមច្បាប់សីលធម៌បានឡើយ។ សាវក ប៉ុល កំពុងតែវែកញែកថា យើងមិនអាចទទួលការរាប់ជាសុចរិតនៅចំពោះព្រះ ដោយព្យាយាមកាន់តាមច្បាប់សីលធម៌ ឬក៏ច្បាប់នៃពិធីនានាបានឡើយ។ ការបរិភោគ និងការផឹក មិនអាចរាប់ជាសុចរិត ឬផ្តន្ទាទោសដល់យើងបានឡើយ។

ខ្ញុំនឹងទៅឆ្ងាយជាងនេះ ហើយអះអាងថា សាវក ប៉ុល សំដៅថាក្រិត្យវិន័យទាំងមូល (មិនមែនគ្រាន់តែផ្នែកជាក់លាក់ណាមួយនោះទេ) នៅតែជាប់នៅលើមនុស្ស។ ប្រសិនក្រិត្យវិន័យមិននៅជាប់លើមនុស្សទៀតដោយព្រោះព្រះគ្រីស្ទ

បានសុគត នោះមានន័យថា អ្វីដែលសាវក ប៉ុល ចង់ធ្វើគឺ គ្រាន់តែនិយាយប៉ុណ្ណឹង ហើយមិនធ្វើអ្វីទៀតសោះ។ នៅក្នុងគម្ពីរកាឡាទី ៣:១០ សាវក ប៉ុល បានសរសេរថា "អស់អ្នកដែលអាងដល់ការប្រព្រឹត្តិតាមក្រិត្យវិន័យ នោះត្រូវបណ្ដាសាវិញ ដ្បិតមានសេចក្ដីចែងទុកមកថា "ត្រូវបណ្ដាសាហើយ អស់អ្នកណាដែលមិនកាន់ខ្ជាប់តាម គ្រប់ទាំងសេចក្ដីដែលកត់ទុកក្នុងគម្ពីរក្រិត្យវិន័យ ដើម្បីនឹងប្រព្រឹត្តិតាម"។ នៅក្នុងអត្ថបទនេះ សាវក ប៉ុល ប្រកាសការគាំទ្រពីលោក ម៉ូសេ ថា ក្រិត្យវិន័យកំពុងតែនៅជាប់លើមនុស្សទាំងអស់ ហើយដែលអាក់ខានមិនបានស្ដាប់បង្គាប់តាមក្រិត្យវិន័យនោះនឹងដាក់មនុស្សទាំងអស់នៅក្រោមបណ្ដាសារបស់ព្រះ។

ទាំងពួកអ្នកដែលព្យាយាមកាន់តាម ទាំងពួកអ្នកដែលមិនព្យាយាមកាន់តាមក្រិត្យវិន័យ មិនបានទទួលនូវការរាប់ជាសុចរិតនៅចំពោះព្រះបានឡើយ ដ្បិតពួកគេជាមនុស្សដែលស្លាប់ខាងឯវិញ្ញាណហើយ។ ការបង្រៀនរបស់សាវក ប៉ុល គឺថា មានមនុស្សពីរពួកនៅក្នុងលោកិយនេះគឺ ពួកអ្នកខាងឯវិញ្ញាណ និងពួកអ្នកដែលមិនមែនខាងឯវិញ្ញាណ (សូមមើល គម្ពីររ៉ូម ៣:២១ និង ២៨)។ ការនេះគឺនៅក្នុងសេចក្ដីសុខសាន្តនៃសេចក្ដីបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងយ៉ូហាន ៣:៦ ថា "របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ"។ ចំពោះមនុស្សដែលមិនមានព្រះវិញ្ញាណ ក្រិត្យវិន័យឥតប្រយោជន៍សោះ។ ទោះបីជាពួកគេខំព្យាយាមកាន់តាមក្រិត្យវិន័យយ៉ាងណាក៏ដោយ ក៏ពួកគេនឹងមិនបានទទួលការរាប់ជាសុចរិតដែរ លើកលែងតែសេចក្ដីជំនឿខាងឯវិញ្ញាណប៉ុណ្ណោះ។

ជាចុងបញ្ចប់ មានន័យថា ប្រសិនបើពិតជាមានអ្វីមួយដែលគេហៅថា "ឆន្ទៈសេរី"មែន នោះវាជាការដ៏ល្អបំផុតនៅក្នុងមនុស្សហើយ ព្រោះថាដោយមិនបាច់ពឹងដល់ព្រះវិញ្ញាណបរិសុទ្ធ "ឆន្ទៈសេរី" អាចជួយមនុស្សឲ្យកាន់តាមក្រិត្យវិន័យទាំងស្រុងបាន! ប៉ុន្តែ សាវក ប៉ុល បាននិយាយថាពួកអ្នកដែលអាង "ប្រព្រឹត្តិតាមក្រិត្យវិន័យ" មិនបានទទួលការរាប់ជាសុចរិតឡើយ។ ការនេះមានន័យថា "ឆន្ទៈសេរី"នេះ មិនអាចធ្វើឲ្យមនុស្សបានទទួលការរាប់ជាសុចរិតនៅចំពោះព្រះបានឡើយ។ ការពិតនៅក្នុងព្រះគម្ពីររ៉ូម ៣:២០ សាវក ប៉ុល បាននិយាយថា ក្រិត្យវិន័យគឺចាំបាច់ ដើម្បីបង្ហាញឲ្យយើងស្គាល់ពីអំពើបាបប៉ុណ្ណោះ។ "តាមរយៈក្រិត្យវិន័យ យើងបានស្គាល់អំពើបាប"។ រីឯមនុស្សដែលអាងការ"ប្រព្រឹត្តិតាមក្រិត្យវិន័យ" មិនអាចស្គាល់អំពើបាបថាជាអ្វីបានឡើយ។ ក្រិត្យវិន័យមិនត្រូវបានប្រទានមក ដើម្បីបង្ហាញពីអ្វីៗដែលយើងអាចធ្វើនោះទេ ប៉ុន្តែដើម្បីកែតម្រង់គំនិតរបស់ពួកគេឲ្យដឹងថាខុសនិងត្រូវនៅចំពោះព្រះវិញ។ "ឆន្ទៈសេរី" ជាភាពងងឹតងងល់ ដ្បិតវាត្រូវការឲ្យក្រិត្យវិន័យបង្រៀនដល់វា។ វាក៏គ្មានអំណាចដែរ ដ្បិតវាទទួលបរាជ័យក្នុងការរាប់មនុស្សជាសុចរិតនៅចំពោះព្រះ។

## ការវែកញែក ៤ : ក្រិត្យវិន័យត្រូវបានបង្កើតឡើងដើម្បី នាំមនុស្សឲ្យស្គាល់ព្រះគ្រីស្ទ ដោយសារផ្តល់ចំណេះដឹងពីអំពើបាប

ការវែកញែកដែលគាំទ្រដល់ "ឆន្ទៈសេរី" និយាយថា ប្រសិនបើយើងមិនអាចកាន់តាមក្រិត្យវិន័យបាន នោះព្រះនឹងមិនប្រទានវាមកទេ។ អែរ៉ាស្មឹសអើយ!

អ្នកតែងនិយាយដដែលៗថា “ប្រសិនបើយើងមិនអាចធ្វើអ្វីបាន ចុះតើអ្វីទៅជាគោលបំណងនៃក្រិត្យវិន័យ ច្បាប់សីលធម៌ ការគំរាម និងសេចក្តីសន្យា? ចម្លើយគឺថា ក្រិត្យវិន័យមិនត្រូវបានប្រទានមកដើម្បីបង្ហាញឲ្យយើងនូវអ្វីមួយដែលយើងអាចធ្វើនោះទេ ហើយវាក៏មិនត្រូវបានប្រទានមកដើម្បីជួយយើងឲ្យធ្វើការត្រឹមត្រូវនោះដែរ។ សាវក ប៉ុល បាននិយាយនៅក្នុងគម្ពីររ៉ូម ៣:២០ ថា “ក្រិត្យវិន័យគ្រាន់តែសំដែងឲ្យស្គាល់អំពើបាបប៉ុណ្ណោះ”។ គោលបំណងរបស់ក្រិត្យវិន័យ គឺដើម្បីបង្ហាញថាអំពើបាបជាអ្វី ហើយអ្វីខ្លះដែលវានាំទៅរក សេចក្តីស្លាប់ ស្ថាននរក និងសេចក្តីក្រោធរបស់ព្រះ។ ក្រិត្យវិន័យគ្រាន់តែចង្អុលបង្ហាញពីចំនុចទាំងនេះប៉ុណ្ណោះ។ វាមិនអាចដោះយើងឲ្យរួចពីការទាំងនោះបានទេ។ ការប្រោសលោះគឺមកតាមរយៈតែព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ដែលបានសំដែងមកយើងរាល់គ្នានៅក្នុងដំណឹងល្អ។ ការត្រិះរិះពិចារណា និង “ឆន្ទៈសេរី” មិនអាចនាំមនុស្សទៅឯព្រះគ្រីស្ទបានទេ ដ្បិតការត្រិះរិះពិចារណា និង“ឆន្ទៈសេរី” ផ្ទាល់ត្រូវការពន្លឺនៃក្រិត្យវិន័យដើម្បីបង្ហាញពីជំងឺផ្ទាល់ខ្លួនរបស់ពួកវា។ សាវក ប៉ុល បានសួរសំនួរនេះនៅក្នុងគម្ពីរកាឡាទី ៣:១៩ ថា “តើហេតុអ្វីបានជាមានក្រិត្យវិន័យនោះ?” ប៉ុន្តែចម្លើយរបស់សាវក ប៉ុល ចំពោះសំនួរផ្ទាល់របស់គាត់នោះ គឺផ្ទុយនឹងចម្លើយរបស់អ្នក និងគំនិតរបស់ជារ៉ូម។ អ្នកនិយាយថាក្រិត្យវិន័យត្រូវបានប្រទានមកដើម្បីបញ្ជាក់បង្ហាញពីវត្តមាននៃ “ឆន្ទៈសេរី”។ ជារ៉ូមបាននិយាយថា វាត្រូវគ្រប់គ្រងអំពើបាប។ ប៉ុន្តែសាវក ប៉ុល មិនបាននិយាយអ្វីទាំងអស់នៃការទាំងពីរនេះ។ ការវែកញែកទាំងស្រុងរបស់គាត់ គឺថាមនុស្សត្រូវការព្រះគុណពិសេស ដើម្បីច្បាំងនឹងសេចក្តីអាក្រក់ដែលក្រិត្យវិន័យបង្ហាញឲ្យឃើញ។ មិនមានការព្យាបាលទេ របួត

ទាល់តែជំងឺត្រូវបានរកឃើញសិន។ ក្រិត្យវិន័យមានភាពចាំបាច់ដើម្បីធ្វើឲ្យមនុស្ស ឃើញពីស្ថានភាពគ្រោះថ្នាក់របស់ពួកគេ ដើម្បីឲ្យពួកគេចង់បាននូវវិធីព្យាបាល ដែលមានតែនៅក្នុងព្រះគ្រីស្ទ ប៉ុណ្ណោះ។ ដូច្នេះសំដីរបស់សាវកប៉ុលនៅក្នុងគម្ពីររ៉ូម ៣:២០ អាចនឹងហាក់ដូចជាសាមញ្ញណាស់ ប៉ុន្តែវាមានអំណាចគ្រប់គ្រាន់ដើម្បីធ្វើ ឲ្យ "ឆន្ទៈសេរី" គ្មានវត្តមានសូម្បីតែបន្តិច។ សាវក ប៉ុល បាននិយាយនៅក្នុងគម្ពីរ រ៉ូម ៧:៧ ថា ខ្ញុំមិនបានទាំងស្គាល់ថាសេចក្ដីលោភជាអ្វីផង ដ្បិតបើសិនជាក្រិត្យ វិន័យមិនបានថា "កុំលោភ"។ នេះមានន័យថា "ឆន្ទៈសេរី" មិនដឹងសូម្បីតែអំពើ បាបជាអ្វី! អញ្ចឹងតើ "ឆន្ទៈសេរី" នឹងអាចស្គាល់សេចក្ដីត្រឹមត្រូវដោយរបៀបណា បាន? ហើយប្រសិនបើវាមិនស្គាល់ភាពត្រឹមត្រូវ តើវាអាចព្យាយាមធ្វើការដែល ត្រឹមត្រូវដោយរបៀបណាបាន?

## ការវែកញែក ៥ : គោលលទ្ធិនៃសេចក្ដីសង្គ្រោះដោយសារជំនឿដល់ ព្រះគ្រីស្ទ បានបង្ហាញឲ្យឃើញថា "ឆន្ទៈសេរី" មិនពិត

នៅក្នុងគម្ពីររ៉ូម ៣:២១-២៥ សាវក ប៉ុល បានប្រកាសយ៉ាងជឿជាក់ថា "ប៉ុន្តែឥឡូវ នេះក្រៅពីក្រិត្យវិន័យសេចក្ដីសុចរិតផងព្រះដែលមានទាំងក្រិត្យវិន័យ និងពួក ហោរាធ្វើបន្ទាល់ឲ្យផង នោះបានលេចចេញមកហើយ គឺជាសេចក្ដីសុចរិតរបស់ ព្រះដែលបានដោយសារសេចក្ដីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ ក៏សំរាប់គ្រប់អស់ អ្នកណាដែលជឿផង ដ្បិតគ្មានខុសអំពីគ្នាទេ ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយ ខ្វះមិនដល់សិរីល្អនៃព្រះ តែដោយពឹងដល់ព្រះគុណទ្រង់នោះបានរាប់ជាសុចរិត

ទទេ ដោយសារសេចក្តីប្រោសលោះដដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ដែលព្រះបានតាំងទ្រង់ទុកជាទីសន្តោសប្រោស ដោយសារសេចក្តីជំនឿដល់ព្រះលោហិតទ្រង់”។ ព្រះបន្ទូលត្រង់នេះជារន្ទះដែលបាញ់ប្រឆាំងនឹង “ឆន្ទៈសេរី”។ សាវ៉ក ប៉ុលបានវែកញែកសេចក្តីសុចរិតដែលព្រះប្រទាន ពីសេចក្តីសុចរិតមួយដែលមកពីការកាន់តាមក្រិត្យវិន័យ។ “ឆន្ទៈសេរី” អាចនឹងទទួលជោគជ័យបាន លុះត្រាណាតែមនុស្សបានទទួលការសង្គ្រោះដោយសារការកាន់តាមក្រិត្យវិន័យ។ ប៉ុន្តែសាវ៉កប៉ុល បានបង្ហាញយ៉ាងច្បាស់ថា យើងបានទទួលការសង្គ្រោះ មិនដោយពឹងលើមធ្យោបាយណាមួយនៃកិច្ចការនៃក្រិត្យវិន័យនោះទេ។ ទោះបីជាយើងអាចស្រមើស្រមៃថា “ឆន្ទៈសេរី” អាចនឹងធ្វើការល្អ ឬធ្វើឲ្យយើងក្លាយជាពលរដ្ឋល្អក៏ដោយក៏សាវ៉ក ប៉ុល នៅតែនិយាយថាសេចក្តីសុចរិតដែលព្រះប្រទានមកគឺជាការមួយផ្សេងពីគ្នា។ មិនអាចទៅរួចទេ ដែល “ឆន្ទៈសេរី” អាចមានជីវិតរស់នៅពីការវាយប្រហារនៃខគម្ពីរទាំងនេះ។

ខទាំងនេះក៏ជារន្ទះដែលបាញ់ “ឆន្ទៈសេរី” ផងដែរ។ នៅក្នុងខទាំងនេះសាវ៉ក ប៉ុល គូសបន្ទាត់មួយនៅចន្លោះអ្នកជឿ និងអ្នកមិនជឿ (រ៉ូម ៣:២២)។ គ្មានអ្នកណាម្នាក់អាចបដិសេធថា អំណាចក្លែងក្លាយនៃ “ឆន្ទៈសេរី” គឺផ្សេងគ្នាពីសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទទេ។ ប៉ុន្តែសាវ៉ក ប៉ុល និយាយថា បើគ្មានសេចក្តីជំនឿលើព្រះគ្រីស្ទ គ្មានអ្វីមួយដែលទទួលយកបាននៅចំពោះព្រះបានឡើយ។ ហើយប្រសិនបើការមួយដែលមិនអាចទទួលយកបាននៅចំពោះព្រះ នោះវាជាអំពើបាប។ វាមិនអាចនៅកណ្តាលបានទេ។ ដូច្នេះប្រសិនបើ “ឆន្ទៈសេរី” មានមែននោះ មាន

ន័យថា "ឆន្ទៈសេរី" គឺជាអំពើបាបពីព្រោះវាប្រឆាំងនឹងសេចក្តីជំនឿ ហើយវាមិនលើកដំកើងដល់ព្រះ។

គម្ពីររ៉ូម ៣:២៣ គឺជារន្ធះមួយទៀត។ សាវក ប៉ុល មិនបាននិយាយថា "មនុស្សទាំងអស់មានបាប លើកលែងតែពួកអ្នកដែលធ្វើល្អដោយ "ឆន្ទៈសេរី" របស់ពួកគេផ្ទាល់" នោះទេ។ មិនមានការលើកលែងទេ។ ប្រសិនបើ ការធ្វើឲ្យខ្លួនឯងអាចទទួលយកបាននៅចំពោះព្រះ ពិតជាអាចទៅរួចមែននោះ មានន័យថា សាវក ប៉ុលជាអ្នកកុហក។ គាត់គួរតែបានអនុញ្ញាតិឲ្យមានការលើកលែង។ ប៉ុន្តែគាត់បាននិយាយយ៉ាងច្បាស់ថា ដោយព្រោះអំពើបាប គ្មានអ្នកណាម្នាក់លើកដំកើង ហើយធ្វើឲ្យព្រះសព្វព្រះហឫទ័យដោយពិតប្រាកដបានឡើយ។ អស់អ្នកដែលធ្វើឲ្យព្រះសព្វព្រះហឫទ័យ ត្រូវតែដឹងថាព្រះសព្វព្រះហឫទ័យជាមួយនឹងពួកគេ។ ប៉ុន្តែបទពិសោធន៍របស់យើងបង្រៀនថា គ្មានអ្វីនៅក្នុងយើងដែលធ្វើឲ្យព្រះសព្វព្រះហឫទ័យឡើយ។ សូមសួរទៅពួកអ្នកដែលគាំទ្រ "ឆន្ទៈសេរី" ថា តើមានអ្វីខ្លះនៅក្នុងពួកគេដែលធ្វើឲ្យព្រះសព្វព្រះហឫទ័យ។ ពួកគេច្បាស់ជាសារភាពថា មិនមាន។ ហើយសាវក បាននិយាយយ៉ាងច្បាស់ថា មិនមានរួចទៅហើយ។

សូម្បីតែពួកអ្នកដែលជឿលើ "ឆន្ទៈសេរី" ត្រូវតែយល់ព្រមជាមួយខ្ញុំដែរថា ពួកគេមិនអាចលើកដំកើងព្រះដោយកំលាំងពួកគេផ្ទាល់បានទេ។ សូម្បីតែជាមួយ "ឆន្ទៈសេរី" ពួកគេ គេសង្ស័យថា ពួកគេបានគាប់ព្រះហឫទ័យដល់ព្រះឬអត់ផង។ ដូច្នេះខ្ញុំសូមបង្ហាញភស្តុតាង ពីទីបន្ទាល់នៃបញ្ញាចិត្តផ្ទាល់របស់ពួក

ថា “ឆន្ទៈសេរី” មិនធ្វើឲ្យព្រះសព្វព្រះហឫទ័យទេ។ សូម្បីតែជាមួយនឹងអំណាច និងការប្រឹងប្រែងរបស់វា “ឆន្ទៈសេរី” គឺមានទោសនៃអំពើបាបដោយការមិនជឿ ដែរ។ ដូច្នេះយើងឃើញថា គោលលទ្ធិនៃសេចក្តីសង្គ្រោះដោយសេចក្តីជំនឿ ពិត ជាផ្ទុយនឹងគំនិតនៃ “ឆន្ទៈសេរី”។

## ការវែកញែក ៦ : មិនមានកន្លែងសំរាប់គំនិតនៃបុណ្យកុសលឬរង្វាន់ទេ

ពួកអ្នកដែលបង្រៀនពី “ឆន្ទៈសេរី” បាននិយាយថា ប្រសិនបើគ្មាន “ឆន្ទៈសេរី” នោះនឹងមិនមានកន្លែងសំរាប់បុណ្យកុសល ឬរង្វាន់ទេ។

តើអ្នកគាំទ្រ“ឆន្ទៈសេរី”បាននិយាយអំពីពាក្យថា “ទទេ” នៅក្នុងគម្ពីររ៉ូម ៣:២៤ មានន័យថាយ៉ាងដូចម្តេច? សាវក ប៉ុល បាននិយាយថាអ្នកជឿ “តែដោយ ពឹងផល់ ព្រះគុណទ្រង់ នោះបានរាប់ជាសុចរិតទទេ”។ តើពួកគេគិតយ៉ាងដូចម្តេចពី ពាក្យថា “ដោយពឹងផល់ព្រះគុណទ្រង់”? ប្រសិនបើសេចក្តីសង្គ្រោះបានមកដោយ ទទេ ហើយត្រូវបានប្រទានមកដោយព្រះគុណ នោះមានន័យថាគេមិនអាចរកវា បាន ឬសមទទួលបានវានោះទេ។ ប៉ុន្តែលោក អ៊ែរ៉ាស្មឹសបានវែកញែកថា មនុស្ស ត្រូវតែអាចធ្វើអ្វីមួយដើម្បីរកឲ្យបានសេចក្តីសង្គ្រោះ បើមិនដូច្នោះទេ មនុស្សនឹង មិនសមទទួលបាននូវសេចក្តីសង្គ្រោះឡើយ។ គេគិតថា ហេតុផលដែលព្រះរាប់ មនុស្សម្នាក់ជាសុចរិត ហើយមិនរាប់ម្នាក់ផ្សេងទៀត គឺពីព្រោះម្នាក់បានប្រើ “ឆន្ទៈ សេរី” ហើយបានព្យាយាមធ្វើខ្លួនឲ្យបានសុចរិត ខណៈដែលម្នាក់ទៀតមិនបាន

ធ្វើ។ ការនេះធ្វើឲ្យព្រះក្លាយជាអ្នករើសមុខ ហើយព្រះគម្ពីរចែងថា ព្រះមិនរើសមុខអ្នកណាឡើយ (កិច្ច ១០:៣៤)។ លោក អ៊ែរ៉ាស្ម៊ឺស និងអ្នកផ្សេងទៀត ដែលគិតដូចគាត់និយាយថា មនុស្សអាចធ្វើបានបន្តិចបន្តួចដែរជាមួយនឹង "ឆន្ទៈសេរី" របស់ពួកគេ ដើម្បីទទួលបាននូវសេចក្តីសង្គ្រោះ។ ពួកគេនិយាយថា "ឆន្ទៈសេរី" មានបុណ្យកុសលបន្តិចបន្តួចដែរ។ វាមិនសមទទួលបានច្រើនទេ។ ប៉ុន្តែពួកគេនៅតែគិតថា "ឆន្ទៈសេរី" ធ្វើឲ្យវាអាចទៅរួចសំរាប់មនុស្សក្នុងការព្យាយាមស្វែងរកព្រះ។ ហើយពួកគេនៅតែគិតថា ប្រសិនបើមនុស្សមិនព្យាយាមស្វែងរកព្រះ នោះវាជាកំហុសរបស់ពួកគេផ្ទាល់ បើសិនជាពួកគេមិនបានទទួលបាននូវព្រះគុណទ្រង់។

ដូច្នេះមិនថា "ឆន្ទៈសេរី" នេះ មានបុណ្យកុសលច្រើន ឬតិចតួចនោះទេ តែលទ្ធផលគឺនៅតែដដែល។ ព្រះគុណនៃព្រះ ត្រូវរកបានមកដោយសារវា។ ប៉ុន្តែសាវក ប៉ុល បានបដិសេធចំពោះគ្រប់បុណ្យកុសលទាំងអស់ នៅពេលដែលគាត់និយាយថា យើងបានរាប់ជាសុចរិតដោយ "ទទេ"។ ពួកអ្នកដែលនិយាយថា "ឆន្ទៈសេរី" មានបុណ្យកុសលតិចតួច គឺអាក្រក់ដូចជាពួកអ្នកដែលនិយាយថា "ឆន្ទៈសេរី" មានបុណ្យកុសលច្រើនយ៉ាងដូច្នោះដែរ។ ទាំងពីរនេះសុទ្ធតែបង្រៀនថា "ឆន្ទៈសេរី" មានបុណ្យកុសលគ្រប់គ្រាន់ដើម្បីធ្វើឲ្យគាប់ដល់ព្រះ។ ដូច្នេះពួកគេទាំងពីរពិតជាមិនខុសគ្នាទេ។

ជាការពិតណាស់ពួកអ្នកគាំទ្រដល់ "ឆន្ទៈសេរី" ផ្តល់ឲ្យយើងនូវគំរូដ៏ល្អមួយគឺ "ការលោតចេញពីខ្ទះឆា ចូលទៅក្នុងភ្លើង"។ ពួកគេធ្វើឲ្យជំហររបស់ពួកគេកាន់តែអាក្រក់ទៅៗ ដោយព្រោះពួកគេនិយាយថា "ឆន្ទៈសេរី" ក៏មានបុណ្យ

កុសលបន្តិចបន្តួចដែរ។ យ៉ាងហោចណាស់ពួកអ្នកដែលនិយាយអំពីបុណ្យកុសល (ពួកជឿថាមនុស្សអាចបានទទួលសេចក្តីសង្គ្រោះ ដោយមិនបាច់ពឹងជំនួយរបស់ព្រះ) បានដាក់តំលៃដ៏ខ្ពស់មួយលើព្រះគុណរបស់ព្រះ ដោយព្រោះបុណ្យកុសលដែលគេត្រូវការចាំបាច់ដើម្បីរកឲ្យបានសេចក្តីសង្គ្រោះ។ ប៉ុន្តែលោក អ៊ែរ៉ាស្មឹសធ្វើឲ្យព្រះគុណមិនសូវមានតំលៃ។ វាត្រូវរកបានមកដោយការខិតខំប្រឹងប្រែងដ៏ទន់ខ្សោយមួយ។ ប៉ុន្តែសាវក ប៉ុល បានកាត់បន្ថយគំនិតទាំងពីរដើម្បីធ្វើវាឲ្យទន់ដោយពាក្យមួយថា “ទទេ” នៅក្នុងគម្ពីររ៉ូម ៣:២៨។ ក្រោយមក នៅក្នុងព្រះគម្ពីររ៉ូម ១១:៦ គាត់បាននិយាយថាការដែលយើងរាល់គ្នាត្រូវបានទទួលស្គាល់នៅចំពោះព្រះ គឺដោយសារព្រះគុណតែមួយប៉ុណ្ណោះ “ដោយសារព្រះគុណពិត នោះមិនមែនដោយអាងការប្រព្រឹត្តិទៀតទេ ពុំនោះ ព្រះគុណមិនមែនជាព្រះគុណទៀត”។ ការបង្រៀនរបស់សាវក ប៉ុល ពិតជាច្បាស់ណាស់ មិនពិបាកយល់ទេ។ គ្មានបុណ្យកុសលណាមួយរបស់មនុស្សដែលមាននៅចំពោះព្រះនេត្រទ្រង់ឡើយ មិនថាបុណ្យកុសលនោះធំក្តី ឬតូចក្តី។ គ្មានអ្នកណាម្នាក់សមបានទទួលសេចក្តីសង្គ្រោះឡើយ។ គ្មានអ្នកណាម្នាក់អាចប្រព្រឹត្តិឲ្យបានសេចក្តីសង្គ្រោះឡើយ។ សាវក ប៉ុល បានទាត់ចោលគ្រប់ទាំងកិច្ចការស្នានៗនៃ “ឆន្ទៈសេរី” ហើយបានបង្កើតព្រះគុណតែមួយប៉ុណ្ណោះ។ យើងមិនអាចឲ្យការសរសើរដល់ខ្លួនយើងសំរាប់សេចក្តីសង្គ្រោះរបស់យើងបានទេ សូម្បីតែបន្តិច ពីព្រោះសេចក្តីសង្គ្រោះនោះជាព្រះគុណរបស់ព្រះទាំងស្រុង។

## ការវែកញែក ៧ : "ឆន្ទៈសេរីមិនមានតំលៃ ពីព្រោះការប្រព្រឹត្តិមិនមានការ ទាក់ទងនឹងសេចក្តីសុចរិតរបស់មនុស្សនៅចំពោះព្រះ

ឥឡូវនេះខ្ញុំនឹងដើរកាត់តាមការវែកញែករបស់សាវក ប៉ុល នៅក្នុងគម្ពីររ៉ូម ៤:២-៣ "បើសិនណាជាលោក អាប្រាហាំបានរាប់ជាសុចរិតដោយការដែលលោកប្រព្រឹត្តិ នោះលោកមានកន្លែងនឹងអួតខ្លួនហើយ តែមិនមែនចំពោះព្រះទេ។ តើព្រះគម្ពីរថាដូចម្តេច? គម្ពីរថា "អាប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីជំនឿនោះបានរាប់ជាសុចរិតដល់លោក"។ ឥឡូវនេះសាវក ប៉ុល មិនបានបដិសេធថា លោក អាប្រាហាំជាមនុស្សសុចរិតនោះទេ។ និយាយឲ្យចំទៅ គឺចង់និយាយថាសេចក្តីសុចរិតនេះមិនធ្វើឲ្យគាត់រកបានសេចក្តីសង្គ្រោះនោះទេ។ គ្មានអ្នកណាម្នាក់មិនព្រមថា កិច្ចការអាក្រក់មិនអាចទទួលស្គាល់នៅចំពោះព្រះបានទេ។ ពួកគេធ្វើបុណ្យកុសលឲ្យបានសេចក្តីក្រោធរបស់ព្រះ មិនមែនឲ្យបានការសព្វព្រះហឫទ័យរបស់ព្រះទេ។ នៅក្នុងគម្ពីររ៉ូម ៤:៤-៥ សាវក ប៉ុល បានកំណត់លក្ខខ័ណ្ឌឲ្យ "អ្នកណាដែលធ្វើការ" និង "អ្នកដែលមិនធ្វើការសោះ"។ សេចក្តីសុចរិតដែលព្រះទទួលស្គាល់ គឺមិនរាប់ជាគុណដល់ "អ្នកណាដែលធ្វើការ" ឡើយ ប៉ុន្តែដល់ "អ្នកដែលមិនធ្វើការ" ដែលទុកចិត្តដល់ព្រះវិញ។ មិនមានជំហារកណ្តាលនោះទេ។

## ការវែកញែក ៨ : ការវែកញែកមួយក្ដាប់តូច

ខ្ញុំត្រូវតែនិយាយពីការវែកញែកមួយចំនួនទៀតដែលប្រឆាំងនឹង "ឆន្ទៈសេរី"។ ខ្ញុំនឹងនិយាយពីការវែកញែកទាំងនោះដោយត្រួសៗប៉ុណ្ណោះ ប៉ុន្តែការវែកញែកនិមួយៗអាចបំផ្លាញគំនិត "ឆន្ទៈសេរី"ទាំងស្រុងបាន។ ឧទាហរណ៍៖ ប្រភពនៃព្រះគុណដែលយើងរាល់គ្នាបានទទួលការសង្គ្រោះ គឺជាគោលបំណងដ៏អស់កល្បរបស់ព្រះ។ ការនេះមិនធ្វើឲ្យការលើកឡើងដែលថា ព្រះមានសេចក្ដីទន់សន្ដោសដល់យើងដោយព្រោះតែអ្វីមួយដែលយើងអាចធ្វើកើតនោះទេ។

ការវែកញែកមួយទៀត មានមូលដ្ឋានលើសេចក្ដីពិតដែលព្រះបានសន្យាពីសេចក្ដីសង្គ្រោះដោយព្រះគុណ (ចំពោះលោកអាប្រាហាំ) មុនពេលដែលទ្រង់បានប្រទានក្រិត្យវិន័យ។ សាវក ប៉ុល បានវែកញែកនៅក្នុងគម្ពីររ៉ូម ៤:១៣-១៥; កាឡាទី ៣:១៥-២១ ថា ឥឡូវនេះប្រសិនបើយើងបានទទួលសេចក្ដីសង្គ្រោះដោយសារការកាន់តាមក្រិត្យវិន័យតាម "ឆន្ទៈសេរី" នោះមានន័យថាការសន្យារបស់ព្រះពីសេចក្ដីសង្គ្រោះដោយសារព្រះគុណ ត្រូវបានលើកចោលហើយ។ ហើយជំនឿក៏គ្មានតំលៃផងដែរ។

សាវក ប៉ុលក៏បានប្រាប់យើងផងដែរថា ក្រិត្យវិន័យគ្រាន់តែអាចបង្ហាញពីអំពើបាបប៉ុណ្ណោះ ប៉ុន្តែវាមិនអាចយកអំពើបាបចេញបានទេ។ ដោយព្រោះ "ឆន្ទៈសេរី" គ្រាន់តែអាចពឹងលើមូលដ្ឋានគ្រឹះនៃការកាន់តាមក្រិត្យវិន័យប៉ុណ្ណោះ ប៉ុន្តែវាគ្មានសេចក្ដីសុចរិតដែលអាចទទួលយកបាននៅចំពោះព្រះបានឡើយ។

ជា ចុង ក្រោយ  យើង រាល់ គ្នា ស្ថិត នៅ ក្រោម ការ ផ្តន្ទាទោស របស់ ព្រះ ដោយព្រោះការមិនស្តាប់បង្គាប់ដ៏ពោរពេញដោយអំពើបាបរបស់លោកអ័ដាម។ យើងរាល់គ្នាស្ថិតនៅក្រោមការផ្តន្ទាទោសនេះតាំងពីកំណើតរបស់យើង រួមទាំងពួកអ្នកដែលមាន "ឆន្ទៈសេរី" ផងដែរ (ប្រសិនបើពិតជាមានមនុស្សយ៉ាងដូច្នេះមែន!)។ យ៉ាងនោះក្រៅពីឲ្យយើងធ្វើបាប ហើយរកបាននូវការផ្តន្ទាទោស តើ "ឆន្ទៈសេរី" អាចជួយយើងដោយរបៀបណាបាន?

ខ្ញុំ អាច ផាត់  ការ វែក ញែក ទាំង នេះ ចោល  ហើយ គ្រាន់ តែ  ផ្តល់ ការ អធិប្បាយពីសំនួរនានារបស់សាវក ប៉ុលក៏បានដែរ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់បង្ហាញថា គូបដិបក្ខរបស់ខ្ញុំគេឆោតល្ងង់យ៉ាងណាប៉ុណ្ណោះ គឺជាពួកដែលមិនអាចយល់ច្បាស់ពីសេចក្តីដ៏សាមញ្ញនេះ។ ខ្ញុំទុកឲ្យពួកគេគិតពីការវែកញែកទាំងនេះដោយខ្លួនឯងចុះ។

## ការវែកញែក ៩ : សាវក ប៉ុល បាននិយាយ យ៉ាងដាច់ខាត ក្នុង ការដែល មិន គាំទ្រដល់ "ឆន្ទៈសេរី"

ការវែកញែករបស់សាវក ប៉ុល បានបង្ហាញយ៉ាងច្បាស់ណាស់។ វាគួរឲ្យភ្ញាក់ផ្អើលមែនទែន ដែលគេអាចភាន់ច្រឡំចំពោះគាត់។ គាត់បាននិយាយថា "ពួកគេទាំងអស់គ្នាបានទាសចេញពីផ្លូវ, គ្មានអ្នកណាមួយសុចរិតសោះ, គ្មានអ្នកណាមួយដែលធ្វើល្អសោះ សូម្បីតែម្នាក់"។ ខ្ញុំមានការភ្ញាក់ផ្អើលមែនទែនដែលគេនិយាយថា

“មនុស្សខ្លះមិនទាសចេញពីផ្លូវ មនុស្សខ្លះមិនទុច្ចរិត មនុស្សខ្លះមិនអាក្រក់ មនុស្សខ្លះមិនមែនជាមនុស្សមានបាប។ ហើយមានអ្វីមួយដែលនៅក្នុងមនុស្សដែលដេញតាមសេចក្ដីល្អបាន”។ សាវក ប៉ុល មិនបានធ្វើការវែកញែកទាំងនេះនៅក្នុងបទគម្ពីរបីបួនដាច់ឆ្ងាយពីគ្នានោះទេ។ ជួនកាលគាត់ធ្វើការវែកញែកដោយវិជ្ជមាន ហើយជួនកាលដោយអវិជ្ជមាន ដោយការវែកញែកដ៏ច្បាស់ស្រួលយល់ និងដោយការប្រៀបធៀបពីភាពខុសគ្នា ។ អត្ថន័យដ៏ងាយយល់នៃសំដីរបស់គាត់ ហើយបរិបទទាំងមូល និងការវែកញែកនានារបស់គាត់ទាំងអស់ គឺរួមមកក្នុងការនេះថា ក្រៅពីជំនឿលើព្រះគ្រីស្ទ នោះគ្មានអ្វីសោះក្រៅពីអំពើបាប និងការផ្ដន្ទាទោស។ គូបដិបក្ខរបស់ខ្ញុំបានចាញ់ ទោះបើគេមិនចុះចាញ់ក៏ដោយ! ប៉ុន្តែនោះមិនមែននៅក្នុងអំណាចរបស់ខ្ញុំក្នុងការដែលធ្វើឲ្យពួកគេចាញ់ឡើយ  គឺជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធវិញ។

## ការវែកញែក ១០ : សណ្ឋានមនុស្សដែលគ្មានព្រះវិញ្ញាណ បង្ហាញថា “ឆន្ទៈ សេរី” មិនអាចធ្វើអ្វីខាងឯវិញ្ញាណបានឡើយ

នៅក្នុងព្រះគម្ពីររ៉ូម ៨:៥ សាវក ប៉ុល បានបែងចែកមនុស្សជាតិជាពីរពួកគឺ មនុស្សខាង “សាច់ឈាម” (ឬមនុស្សដែលមាននិស្ស័យពោរពេញដោយអំពើបាប) ហើយនិងមនុស្សខាង “ព្រះវិញ្ញាណ” (ក៏សូមមើលនៅក្នុង យ៉ូហាន ៣:៦ផងដែរ)។ ការនេះមានន័យថា ពួកអ្នកដែលមិនមានព្រះវិញ្ញាណ គឺរស់នៅក្នុងសាច់ឈាម ហើយនៅតែមាននិស្ស័យដែលពោរពេញដោយអំពើបាប។ សាវក ប៉ុល

បាននិយាយថា “បើអ្នកណាគ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ” (រ៉ូម ៨:៩)។ និយាយឲ្យងាយយល់ទៅ ការនេះមានន័យថា ពួកអ្នកដែលគ្មានព្រះវិញ្ញាណ នោះជារបស់ផងអារក្សសាតាំង។ “ឆន្ទៈសេរី” មិនមានសេចក្តីល្អចំពោះពួកគេទេ! សាវក ប៉ុល បាននិយាយថា “ពួកអ្នកដែលនៅខាងសាច់ឈាម នោះពុំអាចនឹងគាប់ព្រះហឫទ័យដល់ព្រះបានឡើយ” (រ៉ូម ៨:៨)។ គាត់បាននិយាយថា “គំនិតខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ ដ្បិតមិនចុះចូលនឹងក្រិត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង” (រ៉ូម ៨:៧)។ វាមិនអាចទៅរួចបានទេ ដែលមនុស្សខិតខំប្រឹងប្រែងដោយខ្លួនឯងដើម្បីធ្វើឲ្យព្រះសព្វព្រះហឫទ័យនោះ។

បុរសម្នាក់ឈ្មោះថា អ័រីជិន បានលើកឡើងថា មនុស្សម្នាក់ៗសុទ្ធតែមាន “ព្រលឹង” មួយ ដែលមានសមត្ថភាពបែរទៅរក “សាច់ឈាម” ក៏បាន ឬក៏ទៅឯ “ព្រះវិញ្ញាណ” ក៏បាន។ នេះគ្រាន់តែជាការស្រមើស្រមៃរបស់គាត់ប៉ុណ្ណោះ។ គាត់បានយល់សប្តិឃើញដូច្នេះ! គាត់គ្មានអំណះអំណាងសំរាប់ការនេះទាល់សោះ។ តាមពិតទៅ មិនមានជំហរកណ្តាល (ចាក់ខ្សែ)នោះទេ។ អ្វីៗក៏ដោយដែលគ្មានព្រះវិញ្ញាណ គឺជាសាច់ឈាម ហើយសកម្មភាពដ៏ល្អបំផុតរបស់សាច់ឈាម គឺទាស់ទទឹងនឹងព្រះ។ នេះដូចគ្នានឹងការបង្រៀនរបស់ព្រះគ្រីស្ទនៅក្នុងគម្ពីរម៉ាថាយ ៧:១៨ ដែរ ដែលថា ដើមឈើអាក្រក់មិនអាចបង្កើតផ្លែល្អបានទេ។ វាក៏ស៊ីគ្នានឹងការវែកញែករបស់សាវក ប៉ុល ផងដែរ គឺថា “មនុស្សសុចរិតនឹងរស់នៅដោយអាងសេចក្តីជំនឿ” (រ៉ូម ១:១៧) ហើយ “ការទាំងប៉ុន្មានដែលធ្វើដោយឥតមាន

សេចក្តីជំនឿនោះសុទ្ធតែជាបាបទាំងអស់” (រ៉ូម ១៤:២៣)។ ពួកអ្នកដែលគ្មានសេចក្តីជំនឿមិនបានរាប់ជាសុចរិតទេ ហើយពួកអ្នកដែលមិនបានរាប់ជាសុចរិតជាមនុស្សមានបាប ដែល “ឆន្ទៈសេរី” បង្កើតតែសេចក្តីអាក្រក់នៅក្នុងអ្នកទាំងនោះ។ ដូច្នេះ “ឆន្ទៈសេរី” គ្មានអ្វីទាំងអស់ ក្រៅពីជាទាសករនៃអំពើបាប សេចក្តីស្លាប់ និងអារក្សសាតាំង។ “សេរីភាព” បែបនេះ គឺគ្មានសេរីភាពទាល់តែសោះ។

## ការវែកញែក ១១ : អស់អ្នកដែលមកស្គាល់ព្រះគ្រីស្ទ មុននេះមិនបានគិតពី ទ្រង់ ស្វែងរកទ្រង់ ឬក៏រៀបចំខ្លួនសំរាប់ទ្រង់ឡើយ

នៅក្នុងគម្ពីររ៉ូម ១០:២០ សាវក ប៉ុល បានដកស្រង់ បទគម្ពីរអេសាយ ៦៥:១ “អញបានឆ្លើយតបនឹងពួកអ្នកដែលមិនបានសួររកអញ ហើយពួកអ្នកដែលមិនបានស្វែងរកអញ នោះអញបានឲ្យគេប្រទះឃើញអញវិញ អញបាននិយាយនឹងសាសន៍មួយដែលមិនបានហៅតាមឈ្មោះអញថា មើលនេះអញហើយ មើលនេះអញហើយ”។

សាវក ប៉ុល បានដឹងពីបទពិសោធន៍របស់គាត់ផ្ទាល់ថា គាត់មិនបានស្វែងរកព្រះគុណរបស់ព្រះទេ ប៉ុន្តែគាត់បានទទួលព្រះគុណមកក្នុងការដែលគាត់មានកំហឹងប្រឆាំងនឹងព្រះគុណនោះទៅវិញ។ សាវក ប៉ុល បាននិយាយនៅក្នុងគម្ពីររ៉ូម ៩:៣០-៣១ថា ពួកយូដាដែលខិតខំកាន់តាមក្រិត្យវិន័យ មិនបានទទួលការសង្គ្រោះដោយការខិតខំទាំងនោះឡើយ ប៉ុន្តែសាសន៍ដទៃដែលទមិឡល្មើសបែរជាទទួល

បានសេចក្តីមេត្តាករុណារបស់ព្រះទៅវិញ។ ការនេះបង្ហាញយ៉ាងច្បាស់ថា គ្រប់ការខិតខំរបស់មនុស្ស "ឆន្ទៈសេរី" ម្នាក់ គឺជាការឥតប្រយោជន៍ ក្នុងការជួយសង្គ្រោះដល់គាត់។ ការឧស្សាហ៍របស់សាសន៍យូដា មិនបាននាំឲ្យពួកគេទៅដល់កន្លែងណាមួយនោះទេ ក្នុងខណៈពេលដែលពួកសាសន៍ដទៃទទួលបានសេចក្តីសង្គ្រោះ។ ព្រះគុណត្រូវបានប្រទានមកដោយឥតគិតថ្លៃដល់ពួកអ្នកដែលមិនសមទទួល និងពួកអ្នកដែលមិនសក្តិសម ។ ហើយព្រះគុណមិនរកបានមកដោយការខិតខំប្រឹងប្រែងទេ សូម្បីតែមនុស្សល្អបំផុត និងទៀងត្រង់បំផុតព្យាយាមធ្វើ ក៏មិនបានដែរ។

## ការវែកញែក ១២ : សេចក្តីសង្គ្រោះនៃលោកិយដែលមានបាបគឺដោយសារព្រះគុណនៃព្រះគ្រីស្ទតាមរយៈជំនឿតែមួយប៉ុណ្ណោះ

ឥឡូវនេះសូមយើងបែរទៅរក សាវក យ៉ូហានវិញ គាត់ក៏បានសរសេរប្រឆាំងនឹង "ឆន្ទៈសេរី" ផងដែរ។ នៅក្នុងយ៉ូហាន ១:៥ គាត់បាននិយាយថា "ពន្លឺនោះក៏ភ្លឺមកក្នុងសេចក្តីងងឹត តែសេចក្តីងងឹតយល់ (ឬ យកឈ្នះ) មិនដល់ពន្លឺទេ"។ ហើយនៅក្នុងយ៉ូហាន ១:១០-១១ ថា "ទ្រង់បានគង់នៅក្នុងលោកិយ ហើយលោកិយក៏កើតមកដោយសារទ្រង់ តែមិនស្គាល់ទ្រង់ទេ។ ទ្រង់បានយាងមកគង់នៅផែនដីរបស់ទ្រង់ តែរាស្ត្រទ្រង់មិនបានទទួលទ្រង់សោះ"។ ពាក្យថា "លោកិយ" សាវក យ៉ូហាន ចង់សំដៅលើមនុស្សជាតិទាំងអស់។ ដោយព្រោះ "ឆន្ទៈសេរី" អាចនឹងជាការដែលល្អបំផុតនៅក្នុងមនុស្ស យ៉ាងនោះវាច្បាស់ជាត្រូវបានរាប់បញ្ចូលនៅក្នុងអ្វីៗដែលសាវក យ៉ូហានបាននិយាយអំពី "លោកិយ" ហើយ។ ដូច្នេះយោង

ទៅតាមអត្ថបទទាំងពីរនេះ “ឆន្ទៈសេរី” មិនស្គាល់ពន្លឺនៃសេចក្តីពិតឡើយ ហើយវាស្អប់ព្រះគ្រីស្ទ និងរាស្ត្ររបស់ទ្រង់ថែមទៀតផង។ មានបទគម្ពីរជាច្រើនដូចជា យ៉ូហាន ៧:៧; ៨:២៣; ១៤:៧; ១៥:១៩; ១យ៉ូហាន ២:១៦; ៥:១៩ ដែលប្រកាសថា “លោកិយ” (ដែលរាប់បញ្ចូលទាំង “ឆន្ទៈសេរី” ផងនោះ) គឺនៅក្រោមការបង្គាប់របស់អារក្សសាតាំង។

“លោកិយ” គឺរួមបញ្ចូលអ្វីៗទាំងអស់ដែលមិនបានញែក ឲ្យបានទៅឯព្រះដោយព្រះវិញ្ញាណ។ ឥឡូវប្រសិនពិតជាមានអ្នកណាម្នាក់នៅក្នុងលោកិយនេះ បានស្គាល់សេចក្តីពិតដោយ “ឆន្ទៈសេរី” ហើយមិនបានស្អប់ព្រះគ្រីស្ទដោយ “ឆន្ទៈសេរី” នោះមានន័យថា សាវក យ៉ូហាន បានផ្លាស់ប្តូរនូវអ្វីដែលគាត់បានសរសេរហើយ។ ប៉ុន្តែគាត់មិនបានធ្វើដូច្នេះទេ។ ដូច្នេះវាបង្ហាញយ៉ាងច្បាស់ថា “ឆន្ទៈសេរី” មានទោសដូចជា “លោកិយ” អញ្ចឹងដែរ។ នៅក្នុងគម្ពីរយ៉ូហាន ១:១២-១៣ សាវកយ៉ូហាន បានបន្តថា “ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ” គឺជាកូនដែលមិនមែនកើតមកពីឈាម ឬតាមប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើយ គឺកើតមកអំពីព្រះវិញ”។ ពាក្យថា “មិនមែនកើតមកពីឈាម” មានន័យថា វាជាការឥតប្រយោជន៍ដែលពឹងលើទីកន្លែងកំណើត ឬលើគ្រួសាររបស់អ្នក។ រីឯពាក្យថា មិន“តាមប្រាថ្នាខាងរូបសាច់” មានន័យថា ជាការល្ងីល្ងើដែលយើងពឹងលើ “ការប្រព្រឹត្តិតាមក្រិត្យវិន័យ”។ ហើយ មិន “តាមចំណង់មនុស្សឡើយ” មានន័យថា មិនមានការខំប្រឹងប្រែងណាមួយរបស់មនុស្ស ដែលចាប់ផ្តើមធ្វើឲ្យព្រះ

អាចទទួលយកបានឡើយ។

ប្រសិនបើ “ឆន្ទៈសេរី” មានប្រយោជន៍មែននោះ សាវក យ៉ូហានមិនគួរបដិសេធនឹង “ប្រាថ្នារបស់មនុស្ស” ទេ បើមិនអញ្ចឹងទេ គាត់នឹងស្ថិតនៅក្នុងការគ្រោះថ្នាក់នៃគម្ពីរអេសាយ ៥:២០ ថា “វេទនាដល់ពួកអ្នកដែលរាប់សេចក្តីអាក្រក់ថាជាល្អ ហើយសេចក្តីល្អថាជាអាក្រក់វិញ”។ យ៉ាងនេះឃើញថា កំណើតខាងសាច់ឈាមមិនមានប្រយោជន៍ ដើម្បីឲ្យបានទទួលសេចក្តីសង្គ្រោះឡើយ ពីព្រោះនៅក្នុងគម្ពីររ៉ូម ៩:៨ សាវក ប៉ុល បានសរសេរថា “មិនមែនកូនខាងសាច់ឈាមដែលជាកូនរបស់ព្រះនោះទេ ឯកូនខាងឯសេចក្តីសន្យា នោះទើបបានរាប់ជាពូជវិញ”។

បន្ទាប់មកសាវក យ៉ូហាន ក៏បាននិយាយនៅក្នុងគម្ពីរយ៉ូហាន ១:១៦ ថា “យើងទាំងអស់គ្នា បានទទួលអំពីសេចក្តីពោរពេញរបស់ទ្រង់មក គឺជាព្រះគុណថែមលើព្រះគុណផង”។ ដូច្នេះយើងទទួលបាននូវព្រះពរខាងឯវិញ្ញាណតាមរយៈព្រះគុណតែប៉ុណ្ណោះ មិនមែនតាមរយៈការខិតខំប្រឹងប្រែងរបស់យើងឡើយ។ សេចក្តីពីរផ្ទុយពីគ្នា សេចក្តីទាំងពីរនោះមិនអាចពិតទាំងពីរបានឡើយ គឺថា ព្រះគុណមានតំលៃថោកណាស់ អ្នកណានៅកន្លែងណាក៏អាចរកវាបានដែរ នៅពេលដំណាលគ្នានោះ ព្រះគុណគួរជាទីចង់បានខ្លាំងណាស់ ដែលយើងអាចទទួលវាមកបានតាមរយៈតែការល្អរបស់មនុស្សម្នាក់ប៉ុណ្ណោះ គឺព្រះយេស៊ូវគ្រីស្ទ។

ខ្ញុំចង់ឲ្យគូរបដិបក្ខរបស់ខ្ញុំភ្ញាក់ដឹងខ្លួនថា នៅពេលពួកគេវែកញែកឲ្យ

“ឆន្ទៈសេរី” មានន័យ ពួកគេកំពុងតែបដិសេធព្រះគ្រីស្ទហើយ។ ប្រសិនបើយើងអាចទទួលព្រះគុណដោយ “ឆន្ទៈសេរី” នោះយើងមិនត្រូវការព្រះគ្រីស្ទទេ។ ហើយប្រសិនបើយើងមានព្រះគ្រីស្ទ យើងមិនត្រូវការ “ឆន្ទៈសេរី” ដែរ។ អ្នកគាំទ្រ “ឆន្ទៈសេរី” បានបង្ហាញពីការបដិសេធរបស់ពួកគេចំពោះព្រះគ្រីស្ទដោយសកម្មភាពរបស់ពួកគេផ្ទាល់ ពីព្រោះពួកគេមួយចំនួនបានសូម្បីតែប្រើការអធិស្ឋានជំនួសដល់នាងម៉ារា និង “ពួកបរិសុទ្ធ” ហើយពួកគេខកខានមិនបានពឹងលើព្រះគ្រីស្ទដែលជាអ្នកសម្រុះសម្រួលតែមួយរវាងមនុស្សនិងព្រះទៅវិញ។ ពួកគេបោះបង់ចោលព្រះគ្រីស្ទនៅក្នុងកិច្ចការរបស់ទ្រង់ក្នុងនាមជាអ្នកសម្រុះសម្រួល ហើយជាព្រះអង្គសង្គ្រោះដ៏សប្បុរស ហើយមិនតែប៉ុណ្ណោះពួកគេថែមទាំងចាត់ទុកការល្អរបស់ព្រះគ្រីស្ទ មានតំលៃទាបជាងការខំប្រឹងប្រែងរបស់ពួកគេទៅវិញ។

## ការរែកញែក ១៣ : ករណីរបស់លោក នីកូដែម នៅក្នុងគម្ពីរយ៉ូហាន ៣ ជំទាស់នឹង “ឆន្ទៈសេរី”

សូមមើលទៅឯគុណធម៌របស់លោកនីកូដែម (យ៉ូហាន ៣:១-២)។ គាត់បានសារភាពថាទ្រង់ជាព្រះគ្រីស្ទពិត ហើយទ្រង់ពិតជាមកពីព្រះមែន។ គាត់និយាយសំដៅលើការអស្ចារ្យរបស់ព្រះគ្រីស្ទ។ គាត់បានស្វែងរកព្រះគ្រីស្ទ ដើម្បីឲ្យបានលឺច្រើនថែមទៀតអំពីទ្រង់។ ឥឡូវនេះនៅពេលដែលយើងបានលឺពីកំណើតថ្មី (យ៉ូហាន ៣:៣-៨) តើគាត់សារភាពថា មានអ្វីមួយដែលគាត់បានស្វែងរកនៅអតីតកាលឬទេ? ទេ! គាត់ភ្ញាក់ផ្អើល ហើយច្របូកច្របល់ ហើយគាត់ក៏បានបែរ

ចេញពីវានៅពេលដំបូង ថាវាជាអ្វីដែលមិនអាចទៅរួច (យ៉ូហាន ៣:៩)។ សូម្បីតែទស្សនវិទូដ៏ពូកែបំផុត ក៏ត្រូវតែសារភាពថា ពួកគេមិនស្គាល់ព្រះគ្រីស្ទដែរ។ មុនពេលដែលព្រះគ្រីស្ទយាងមក គ្មានការណាមួយដែលស្វែងរកសេចក្តីនានានៃសេចក្តីសង្គ្រោះឡើយ។ នៅពេលដែលពួកគេបានសារភាពយ៉ាងដូច្នេះ នោះមានន័យថាពួកគេកំពុងតែសារភាពថា "ឆន្ទៈសេរី" របស់ពួកគេគឺល្ងង់ ហើយគ្មានអំណាច! ប្រាកដមែនហើយ ពួកអ្នកដែលបង្រៀន "ឆន្ទៈសេរី" គឺឆ្កួត ប៉ុន្តែពួកគេនឹងមិននៅស្ងៀម ហើយថ្វាយសិរីល្អដល់ព្រះឡើយ។

**ការវែកញែក ១៩ : "ឆន្ទៈសេរី"គ្មានប្រយោជន៍ទេ ដោយព្រោះសេចក្តី សង្គ្រោះមកដោយសារព្រះគ្រីស្ទតែមួយអង្គប៉ុណ្ណោះ**

វាបានបង្ហាញយ៉ាងច្បាស់ពីគម្ពីរយ៉ូហាន ១៤:៦ ជាកន្លែងដែលបានចែងថាព្រះយេស៊ូវ "ជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត" ដែលសេចក្តីសង្គ្រោះត្រូវបានរកឃើញតែនៅក្នុងព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ។ យ៉ាងនេះមានន័យថា អ្វីៗក្រៅពីព្រះគ្រីស្ទ ជាសេចក្តីងងឹត ក្លែងក្លាយ និង ស្លាប់ ប៉ុណ្ណោះ។ បើមនុស្សអាចស្គាល់ផ្លូវទៅឯព្រះ បានស្គាល់សេចក្តីពិតរបស់ព្រះ និងបានចែករំលែកព្រះជន្មរបស់ព្រះដោយខ្លួនឯងបានមែននោះ តើព្រះគ្រីស្ទមកមានប្រយោជន៍អ្វី?

គូរបដិបក្ខរបស់យើងនិយាយថា មនុស្សអាក្រក់ក៏មាន "ឆន្ទៈសេរី" ទោះជាពួកគេរំលោភបំពានលើវាក៏ដោយ។ ប្រសិនបើយ៉ាងដូច្នេះមែន នោះមានន័យថា

មានការល្អមួយនៅក្នុងភាពដឹអាក្រក់របស់មនុស្ស។ ហើយប្រសិនបើវាអញ្ជឹងមែន នោះមានន័យថាព្រះមិនយុត្តិធម៌ទេក្នុងការដែលទ្រង់ផ្តន្ទាទោសពួកគេ។ ប៉ុន្តែសាវក យ៉ូហាន និយាយថា ពួកអ្នកដែលមិនជឿលើព្រះយេស៊ូវគ្រីស្ទ ត្រូវបានផ្តន្ទាទោស រួចជាស្រេចទៅហើយ (យ៉ូហាន ៣:១៨)។ ប៉ុន្តែប្រសិនបើមនុស្សមានការល្អ ដែល ហៅថា "ឆន្ទៈសេរី" នេះមែន នោះមានន័យថា សាវក យ៉ូហានគួរបាននិយាយ ថា ពួកគេត្រូវបានផ្តន្ទាទោសដោយព្រោះតែផ្នែកអាក្រក់របស់ពួកគេប៉ុណ្ណោះ មិន មែនដោយព្រោះផ្នែកល្អរបស់ពួកគេឡើយ។ បទគម្ពីរបានចែងថា "អ្នកណាដែល មិនព្រមជឿព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្តីក្រោធ របស់ព្រះតែងនៅជាប់លើអ្នកនោះឯង" (យ៉ូហាន ៣:៣៦)។ ខនេះត្រូវតែមានន័យ សំដៅលើមនុស្សជាតិទាំងអស់។ ប្រសិនបើមិនមានន័យយ៉ាងដូច្នេះទេ នោះមាន ន័យថា មានផ្នែកមួយនៅក្នុងមនុស្សដែលការពារកុំឲ្យអ្នកនោះត្រូវបានផ្តន្ទាទោស ហើយអ្នកនោះនៅតែអាចបន្តការធ្វើបាបដោយគ្មានការភ័យខ្លាច ដោយដឹងថាខ្លួន មានសុវត្ថិភាពពីការផ្តន្ទាទោសហើយ។

ម្តងទៀត យើងអាននៅក្នុងគម្ពីរយ៉ូហាន ៣:២៧ ថា "គ្មានមនុស្សណាអាច នឹងទទួលអ្វីបានទេ លើកតែបានប្រទានពីស្ថានសួគ៌មកឲ្យប៉ុណ្ណោះ"។ នេះគឺសំដៅ ជាពិសេសលើសមត្ថភាពរបស់មនុស្ស ក្នុងធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះ។ មានតែអ្វីៗដែលបានទទួលមកពីខាងលើប៉ុណ្ណោះដែលអាចជួយមនុស្សឲ្យធ្វើតាម បំណងព្រះហឫទ័យទ្រង់បាន។ ប៉ុន្តែ "ឆន្ទៈសេរី" មិនមកពីខាងលើទេ មានន័យថា "ឆន្ទៈសេរី" គឺឥតប្រយោជន៍។

នៅក្នុងគម្ពីរយ៉ូហាន ៣:៣១ សាវក យ៉ូហាន បាននិយាយថា "ឯមនុស្ស ដែលនៅផែនដី នោះកើតពីផែនដីមក ហើយក៏និយាយតាមរបៀបផែនដី តែព្រះអង្គដែលយាងមកពីស្ថានសួគ៌ នោះខ្ពស់លើសជាងទាំងអស់"។ ឥឡូវនេះ "ឆន្ទៈសេរី" ពិតជាគ្មានប្រភពមកពីស្ថានសួគ៌ទេ។ វាមានប្រភពមកពីផែនដី ហើយក៏មិនមានភាពដែលអាចកើតមានឯទៀតដែរ។ ដូច្នេះ ការនេះមានតែន័យថា "ឆន្ទៈសេរី" គ្មានអ្វីដែលពាក់ព័ន្ធនឹងការខាងឯស្ថានសួគ៌ឡើយ។ វាអាចផ្តោតសំខាន់ជាមួយតែការខាងលោកិយប៉ុណ្ណោះ។ ព្រះគ្រីស្ទបានមានបន្ទូល នៅក្នុងគម្ពីរយ៉ូហាន ៨:២៣ ថា "អ្នករាល់គ្នាមកពីស្ថានក្រោម ឯខ្ញុំៗមកពីស្ថានលើវិញ អ្នករាល់គ្នាកើតពីលោកិយនេះ តែខ្ញុំមិនកើតពីលោកិយនេះទេ"។ ព្រះបន្ទូលត្រង់នេះមានន័យថា រូបកាយរបស់ពួកគេកើតពីលោកិយ ហើយព្រះបន្ទូលនេះអាចមិនសូវជាចាំបាច់ទេ ដ្បិតពួកគេបានដឹងការនេះរួចទៅហើយ។ ព្រះគ្រីស្ទចង់មានន័យសំដៅថា ពួកគេខ្វះអំណាចខាងឯវិញ្ញាណ ហើយការនេះមកតែពីព្រះប៉ុណ្ណោះ។

## ការវែកញែក ១៥ : មនុស្សមិនអាចជឿព្រះបានទេ ដូច្នេះគ្រប់ការខិតខំប្រឹងប្រែងរបស់គេមិនអាចជួយសង្គ្រោះគេបានឡើយ

នៅក្នុងព្រះគម្ពីរយ៉ូហាន ៦:៤៤ ព្រះគ្រីស្ទបានមានបន្ទូលថា "គ្មានអ្នកណា អាចនឹងមកឯខ្ញុំបានទេ លើកតែព្រះវរបិតាដែលចាត់ខ្ញុំឲ្យមក ទ្រង់ទាញនាំគេប៉ុណ្ណោះ"។ នេះគឺមិនមានកន្លែងទំនេរសំរាប់ "ឆន្ទៈសេរី" ទេ។ ព្រះអម្ចាស់ទ្រង់នៅបន្តពន្យល់

ពីគំរោងការរបស់ព្រះវរបិតា "អស់អ្នកណាដែលលឺព្រះវរបិតាហើយ បានរៀនពីទ្រង់ នោះក៏មកឯខ្ញុំ (ខ ៤៥)។ ឆន្ទៈរបស់មនុស្សគ្មានអំណាចនឹងធ្វើអ្វីមួយដើម្បីចូលមកឯព្រះគ្រីស្ទដើម្បីសេចក្តីសង្គ្រោះទេ។ សូម្បីតែព្រះបន្ទូលនៃដំណឹងល្អនឹងត្រូវបានលើជាឥតប្រយោជន៍ ប្រសិនបើព្រះវរបិតាផ្ទាល់មិនបានមានបន្ទូលទៅកាន់ចិត្តគំនិតរបស់ពួកយើង ហើយទាញពួកយើងមកឯព្រះគ្រីស្ទទេនោះ។ លោកអ៊ែរ៉ាស្មាស ចង់ធ្វើឲ្យអត្ថន័យងាយយល់នៃខគម្ពីរនេះត្រឡប់ជាមិនសូវសំខាន់ដោយប្រដូចមនុស្សនឹងសត្វចៀមដែលឆ្លើយតបចំពោះអ្នកគង្វាល នៅពេលដែលអ្នកគង្វាលនោះកាន់រំពាត់មួយដើរសំដៅទៅឯពួកគេ។ គេបានវែកញែកថា មានអ្វីម្យ៉ាងនៅក្នុងមនុស្ស ដែលឆ្លើយតបនឹងដំណឹងល្អ។ ប៉ុន្តែការនេះនឹងមិនយ៉ាងដូច្នេះ ពីព្រោះសូម្បីតែព្រះជាម្ចាស់ បានបង្ហាញអំណោយទាននៃព្រះរាជបុត្រារបស់ព្រះដល់មនុស្សទមិឡល្មើសក៏ដោយ ពួកគេក៏នៅតែមិនឆ្លើយតបដែរ លុះត្រាតែទ្រង់ធ្វើការនៅក្នុងពួកគេ។ ជាការពិតណាស់ បើគ្មានកិច្ចការខាងក្នុងរបស់ព្រះវរបិតា មនុស្សទំនងជាបៀតបៀនព្រះរាជបុត្រារបស់ទ្រង់ច្រើនជាជាងដើរតាមទ្រង់។ ប៉ុន្តែនៅពេលព្រះវរបិតាបង្ហាញពីភាពអស្ចារ្យរបស់ព្រះរាជបុត្រាដល់ពួកអ្នកដែលទ្រង់បានប្រទានការយល់ដឹង ពេលនោះពួកគេត្រូវបានទាញមកឯទ្រង់។ ពួកអ្នកដែលជា "ចៀម" ស្គាល់សម្លេងអ្នកគង្វាល!

## ការវែកញែក ១៦ : ការមិនជឿជាសាកល បង្ហាញថា "ឆន្ទៈសេរី" គឺមិនពិត

នៅក្នុងគម្ពីរយ៉ូហាន ១៦:៨ ព្រះយេស៊ូវមានបន្ទូលថា ព្រះវិញ្ញាណបរិសុទ្ធនឹង

កាត់ទោសលោកិយដែលមានទោសដោយព្រោះអំពើបាប។ នៅក្នុងខ៩ ទ្រង់ពន្យល់ថា អំពើបាបគឺជាការដែល "គេមិនជឿដល់ខ្ញុំ" ។ ឥឡូវ អំពើបាបនៃការមិនជឿនេះមិននៅក្នុងស្បែក ឬនៅក្នុងសក់ទេ ប៉ុន្តែនៅក្នុងគំនិត និងឆន្ទៈវិញ។ មនុស្សទាំងអស់មិនយល់ដឹងពីសេចក្តីពិតនៃទោសមិនជឿរបស់ពួកគេ ដូចជាពួកគេមិនស្គាល់ព្រះគ្រីស្ទផ្ទាល់យ៉ាងដូច្នេះដែរ។ ទោសមិនជឿត្រូវតែសំដែងឲ្យពួកគេឃើញ ដោយព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះអ្វីៗដែលនៅក្នុងមនុស្សដោយរួមទាំង "ឆន្ទៈសេរី" ផងនោះ ត្រូវផ្តន្ទាទោសដោយព្រះជាម្ចាស់ ហើយអ្វីៗទាំងនោះអាចតែបន្ថែមលើទោសនៃការដែលគេមិនយល់ដឹងប៉ុណ្ណោះ រហូតទាល់តែព្រះបានសំដែងវាមក។ បទគម្ពីរទាំងមូល ប្រកាសថា ព្រះគ្រីស្ទជាផ្លូវតែមួយគត់នៃសេចក្តីសង្គ្រោះ។ អ្នកណាដែលនៅខាងក្រៅព្រះគ្រីស្ទ គឺនៅក្រោមអំណាចរបស់សាតាំង អំពើបាប សេចក្តីស្លាប់ និងសេចក្តីក្រោធរបស់ព្រះ។ ព្រះគ្រីស្ទតែមួយប៉ុណ្ណោះដែលអាចសង្គ្រោះមនុស្សពីនគររបស់សាតាំង។ យើងមិនបានទទួលការប្រោសលោះដោយសារអំណាចណាមួយនៅក្នុងយើងទេ ប៉ុន្តែដោយសារព្រះគុណតែមួយនៃព្រះវិញ។

## ការវែកញែក ១៧ : អំណាចនៃ"សាច់ឈាម" នៅក្នុងជីវិតរបស់អ្នកជឿ ពិតប្រាកដម្នាក់បានបង្ហាញថា មិនគាំទ្រដល់"ឆន្ទៈសេរី"

ដោយហេតុផលណាមួយ អ្នកបានធ្វើព្រងើយកន្តើយនឹងការវែកញែករបស់ខ្ញុំពីគម្ពីររ៉ូម ជំពូក ៧ និងគម្ពីរកាឡាទី ជំពូក ៥។ ជំពូកទាំងពីរនេះបង្ហាញយើងថា

សូម្បីតែនៅក្នុងអ្នកជឿពិតប្រាកដ អំណាចនៃ "សាច់ឈាម" ពួកគេមិនអាចធ្វើអ្វីមួយដែលពួកគេដឹងថាពួកគេគួរធ្វើ ហើយចង់ធ្វើបានឡើយ។ និស្ស័យរបស់មនុស្សគឺអាក្រក់ណាស់ សូម្បីតែនៅក្នុងមនុស្សដែលមានព្រះវិញ្ញាណគង់នៅក៏ដោយ។ ពួកគេមិនត្រឹមតែបរាជ័យក្នុងការធ្វើការត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រឆាំងនឹងការត្រឹមត្រូវនោះទៀតផង។ នោះតើនឹងមានលទ្ធភាពអ្វីដែលអំណាចនៅក្នុងមនុស្សដែលមិនបានកើតជាថ្មី អាចធ្វើល្អបាន? ដូចជាសាវក ប៉ុល បាននិយាយនៅក្នុងគម្ពីររ៉ូម ៨:៧ ថា "គំនិតខាងសាច់ឈាមនោះរមែងទាស់ទទឹងនឹងព្រះ"។ ខ្ញុំចង់ជួបមនុស្សដែលមានសមត្ថភាពអាចយកឈ្នះការវែកញែកនេះបាន!

## ការវែកញែក ១៨ : ការស្គាល់ថា សេចក្តីសង្គ្រោះមិនអាស្រ័យលើ"ឆន្ទៈសេរី" គឺជាសេចក្តីកំសាន្តចិត្ត

ខ្ញុំសូមប្រកាសថា ខ្ញុំមិនត្រូវការ "ឆន្ទៈសេរី"ទេ ទោះបីជាគេឲ្យវាមកខ្ញុំក៏ដោយ! ប្រសិនបើសេចក្តីសង្គ្រោះពឹងលើខ្លួនខ្ញុំ នោះខ្ញុំនឹងមានកំលាំងតិចជាងការគ្រោះថ្នាក់ ការលំបាក និងអារក្សសាតាំង ដែលខ្ញុំត្រូវប្រយុទ្ធជាមួយ។ ប៉ុន្តែទោះបីជាគ្មានខ្មាំងសត្រូវដែលត្រូវប្រយុទ្ធជាមួយក៏ដោយ ក៏ខ្ញុំមិនដែលប្រាកដថា នឹងបានទទួលជោគជ័យដែរ។ ខ្ញុំមិនដែលប្រាកដថា ខ្ញុំបានធ្វើឲ្យព្រះសព្វព្រះហឫទ័យ ឬថាតើមានអ្វីមួយដែលខ្ញុំត្រូវធ្វើថែមទៀតដែរ។ ខ្ញុំអាចបញ្ជាក់ការនេះ ពីបទពិសោធន៍ដ៏ឈឺចាប់របស់ខ្ញុំផ្ទាល់អស់រយៈពេលជាច្រើនឆ្នាំ។ ប៉ុន្តែសេចក្តីសង្គ្រោះរបស់ខ្ញុំគឺនៅក្នុងព្រះហស្តរបស់ព្រះ មិននៅក្នុងដៃរបស់ខ្ញុំទេ។ ទ្រង់នឹងស្មោះត្រង់ចំពោះ

ការដែលទ្រង់បានសន្យាថា នឹងសង្គ្រោះខ្ញុំ ដោយមិនមានមូលដ្ឋានលើអ្វីដែលខ្ញុំធ្វើ ប៉ុន្តែលើសេចក្ដីមេត្តាករុណាដ៏ធំធេងរបស់ទ្រង់វិញ។ ព្រះមិនចេះកុហក ហើយទ្រង់មិនអនុញ្ញាតិឲ្យខ្មាំងសត្រូវរបស់ខ្ញុំ ដែលជាអារក្សបានឆក់ខ្ញុំពីព្រះហស្តទ្រង់ឡើយ។ គ្មានមនុស្សណាម្នាក់អាចទទួលសេចក្ដីសង្គ្រោះដោយ“ឆន្ទៈសេរី”ឡើយ។ ប៉ុន្តែដោយសារព្រះគុណ មនុស្សជាច្រើននឹងបានទទួលសេចក្ដីសង្គ្រោះ។ មិនតែប៉ុណ្ណោះ ខ្ញុំមានសេចក្ដីអំណរដែលដឹងថា ខ្ញុំជាគ្រីស្ទានម្នាក់ ខ្ញុំផ្គាប់ព្រះហឫទ័យព្រះ មិនដោយព្រោះអ្វីមួយដែលខ្ញុំធ្វើនោះទេ ប៉ុន្តែដោយព្រោះព្រះគុណរបស់ទ្រង់វិញ។ ប្រសិនបើខ្ញុំធ្វើការតិច ឬអាក្រក់ពេក ទ្រង់អត់ទោសដល់ខ្ញុំដោយព្រះហឫទ័យទន់សន្ដោស ហើយធ្វើឲ្យខ្ញុំបានប្រសើរឡើង។ នេះហើយជាសិរីរុងរឿងរបស់គ្រីស្ទានគ្រប់រូប។

## ការរែកញែក ១៩ : គេមិនអាចធ្វើឲ្យកិត្តិយសរបស់ព្រះ បាត់បង់សិរីល្អបានឡើយ

លោកអ្នកអាចនឹងព្រួយបារម្ភថា វានឹងមានការលំបាកក្នុងការការពារកិត្តិយសរបស់ព្រះនៅក្នុងការទាំងអស់នេះ។ “យ៉ាងណា” លោកអ្នកអាចនិយាយថា ទ្រង់ផ្ដន្ទាទោសអស់អ្នកណាដែលមិនអាចជួយខ្លួនឯងពីអំពើបាបបាន ហើយនិងពួកអ្នកដែលត្រូវបានបង្ខំឲ្យនៅតាមរបៀបនោះ ពីព្រោះតែព្រះជ្រើសរើសដើម្បីមិនសង្គ្រោះពួកគេ។ សាវក ប៉ុល និយាយថា “តាមកំណើតរបស់យើង នោះយើងជាមនុស្សជាប់នៅក្នុងសេចក្ដីខ្ញាល់ដូចមនុស្សឯទៀតដែរ” (អេភេសូរ ២:៣)។ ប៉ុន្តែ

អ្នកត្រូវតែមើលវាតាមរបៀបមួយផ្សេងទៀត។ ព្រះជាម្ចាស់គួរត្រូវបានគោរពកោតខ្លាច ទុកជាព្រះមួយអង្គដែលពោរពេញដោយសេចក្តីមេត្តាករុណា ដល់មនុស្សដែលទ្រង់បានរាប់ជាសុចរិត និងសង្គ្រោះ ទោះបីជាពួកគេមិនសក្តិសមយ៉ាងណាក៏ដោយ។ យើងដឹងថាព្រះជាម្ចាស់ទ្រង់ជាព្រះ។ ទ្រង់ក៏ពោរពេញដោយព្រះប្រាជ្ញាញាណ និងយុត្តិធម៌ផងដែរ។ សេចក្តីយុត្តិធម៌របស់ទ្រង់មិនដូចជាសេចក្តីយុត្តិធម៌របស់មនុស្សទេ។ សេចក្តីយុត្តិធម៌របស់ទ្រង់លើសពីការយល់ដឹងរបស់មនុស្ស ដែលមនុស្សមិនអាចយល់ដឹងទាំងស្រុងបាន ដូចជាសាវក ប៉ុល បានលាន់មាត់នៅក្នុងគម្ពីររ៉ូម ១១:៣៣ ថា “អើហ្ន៎ ប្រាជ្ញា និងចំណេះដឹងបរិបូររបស់ព្រះជ្រៅណាស់តើ ឯព្រះតំរិះរបស់ទ្រង់ តើមានអ្នកណានឹងស្ទង់បាន ហើយផ្លូវទ្រង់ តើមានអ្នកណានឹងរកតាមបាន!” ។ ប្រសិនបើយើងយល់ព្រមថា និស្ស័យរបស់ព្រះ កំលាំង ប្រាជ្ញាញាណ និងចំណេះរបស់ទ្រង់លើសពីគ្រប់ទាំងអ្វីៗរបស់មនុស្ស នោះយើងគួរតែជឿថា សេចក្តីយុត្តិធម៌របស់ទ្រង់ធំលើសជាង ហើយល្អជាងសេចក្តីយុត្តិធម៌របស់យើងឆ្ងាយណាស់។ ទ្រង់បានសន្យាចំពោះយើងថា នៅពេលដែលទ្រង់បើកសំដែងពីសិរីល្អរបស់ទ្រង់ដល់យើង នោះយើងនឹងឃើញយ៉ាងច្បាស់នូវអ្វីដែលយើងគួរជឿនៅពេលឥឡូវនេះ ដូចជា ទ្រង់យុត្តិធម៌ជាដរាបតាំងពីអតីតកាល និងអនាគតរបហូតតទៅ។

នេះគឺជាឧទាហរណ៍មួយផ្សេងទៀត។ ប្រសិនបើយើងប្រើហេតុផលរបស់មនុស្ស ដើម្បីពិចារណាពីរបៀបដែលព្រះគ្រប់គ្រងកិច្ចការផ្សេងៗនៃលោកិយទាំងមូល នោះអ្នកច្បាស់ជានិយាយថា គ្មានព្រះក៏បាន ឬថាព្រះអយុត្តិធម៌ក៏បាន។

មនុស្សអាក្រក់ចេះតែបានសុខចំរើន រីឯមនុស្សល្អចេះតែរងទុក្ខ (សូមមើលនៅក្នុងគម្ពីរយ៉ូប ១២:៦ និងគម្ពីរទំនុកដំកើង៧៣:១២) ហើយការទាំងនោះហាក់ដូចជាអយុត្តិធម៌។ ដូច្នេះបានជាមនុស្សជាច្រើនបដិសេធថាគ្មានព្រះ ហើយថា ការទាំងអស់កើតឡើងដោយចៃដន្យ។ ចម្លើយចំពោះបញ្ហានេះគឺថា មានជីវិតបន្ទាប់ពីជីវិតនេះ ហើយពួកអ្នកដែលមិនបានទទួលទណ្ឌកម្ម និងសងថ្លៃអំពើរបស់គេនៅក្នុងជីវិតនេះ នឹងត្រូវទទួលទណ្ឌកម្ម និងសងថ្លៃអំពើរបស់ពួកគេនៅក្នុងជីវិតនោះ។ ជីវិតនេះ គ្រាន់តែជាការរៀបចំសំរាប់ពេលចាប់ផ្តើមនៃជីវិតដែលត្រូវមកតែប៉ុណ្ណោះ។ បញ្ហានេះត្រូវបានវែកញែកគ្រប់ជំនាន់មកហើយ ប៉ុន្តែមិនដែលត្រូវបានដោះស្រាយឡើយ លើកលែងតែដោយជំនឿជឿលើដំណឹងល្អ ដូចដែលបានរកឃើញនៅក្នុងព្រះគម្ពីរប៉ុណ្ណោះ។ មានពន្លឺបីដែលបំភ្លឺលើបញ្ហានេះគឺ ពន្លឺនៃធម្មជាតិ ពន្លឺនៃព្រះគុណ និងពន្លឺនៃសិរីល្អ។ ដោយពន្លឺនៃធម្មជាតិ ព្រះហាក់ដូចជាអយុត្តិធម៌ក្នុងការដែលមនុស្សល្អរងទុក្ខ ហើយមនុស្សអាក្រក់បានសុខចំរើន។ ពន្លឺនៃព្រះគុណជួយយើងលើសពីហ្នឹង ប៉ុន្តែវាមិនអាចឆ្លើយនឹងសំនួរដែលសួរថា តើព្រះផ្តន្ទាទោសអ្នកដែលមិនអាចធ្វើអ្វីបានក្រៅពីធ្វើបាបហើយមានទោស ដោយរបៀបណា បានទេ។ មានតែពន្លឺនៃសិរីល្អប៉ុណ្ណោះដែលពន្យល់ពីការនេះពីថ្ងៃដែលត្រូវមកដែលព្រះនឹងបើកសំដែងអង្គទ្រង់ថា ជាព្រះដ៏យុត្តិធម៌គ្រប់យ៉ាង ទោះបីជាការវិនិច្ឆ័យរបស់ទ្រង់លើសពីការយល់ដឹងរបស់មនុស្សជាតិក៏ដោយ។ អ្នកកោតខ្លាចដល់ព្រះម្នាក់ ជឿថា ព្រះជ្រាបជាមុន ហើយជ្រើសតាំងជាមុនចំពោះគ្រប់ការទាំងអស់ ហើយគ្មានអ្វីមួយកើតឡើងក្រៅពីព្រះហឫទ័យទ្រង់ឡើយ។ ដូច្នេះគ្មានមនុស្ស ឬទេវតា ឬសត្វលោកណា មាន “ឆន្ទៈសេរី” ទេ។ សាតាំងគឺជាស្តេចនៃ

លោកិយនេះ ហើយវាបានគ្រប់គ្រងមនុស្សដែលជាឈ្លើយរបស់វា ទាល់តែពួកគេត្រូវបានដោះលែងដោយព្រះវិញ្ញាណបរិសុទ្ធ។

# ជំពូក ២

## អ្វីដែល អ៊ែរ៉ាស្មឹស បានបង្រៀន

*ការវែកញែក ១ : និយមន័យនៃ “ឆន្ទៈសេរី” របស់ អ៊ែរ៉ាស្មឹស*

*ការវែកញែក ២ : ការវែកញែកចេញពីកណ្ឌមួយនៅក្នុងសៀវភៅអាប៉ូគ្រីហ្វា របស់ អ៊ែរ៉ាស្មឹស*

*ការវែកញែក ៣ : ទស្សនៈបីអំពី “ឆន្ទៈសេរី” របស់ អ៊ែរ៉ាស្មឹស*

*ការ វែក ញែក ៤ : ការ ត្រឡប់ ទៅ កាន់ ការ វែក ញែក របស់ អ៊ែរ៉ាស្មឹសពី* Ecclesiasticus *(កណ្ឌមួយនៃសៀវភៅ អាប៉ូគ្រីហ្វា) ១៥:១៤-១៧*

*ការវែកញែក ៥ : ការពន្យល់បន្ថែមពីការប្រើប្រាស់* Ecclesiasticus *១៥:១៤-១៧ របស់ អ៊ែរ៉ាស្មឹស*

*ការវែកញែក ៦ : ការវែកញែកនានារបស់អ៊ែរ៉ាស្មឹស ត្រូវតែមានន័យថា ឆន្ទៈរបស់មនុស្សគឺមានសេរីភាពពេញទី*

*ការវែកញែក ៧ : លោកុប្បត្តិ ៤:៧-ជាអត្ថបទមួយផ្សេងទៀតដែលបង្ហាញ ថាការបង្គាប់មួយ មិនមានន័យថា ជាសមត្ថភាពក្នុងការ ស្តាប់បង្គាប់នោះទេ*

ការវែកញែក ៨ : ចោទិយកថា ៣០:១៩- ក្រិត្យវិន័យត្រូវបានរៀបចំឡើង ដើម្បីផ្តល់ចំណេះដឹងពីអំពើបាប

ការវែកញែក ៩ : ការអាន់ច្រឡំរបស់ អ៊ែរ៉ាស្មឹស អំពីក្រិត្យវិន័យនិងដំណឹង ល្អ

ការវែកញែក ១០ : បំណងព្រះហប្ញទ័យបើកសំដែង និងបំណងព្រះហប្ញទ័យលាក់កំបាំង

ការវែកញែក ១១ : កាតព្វកិច្ច គឺគ្មានភស្តុតាងពីសមត្ថភាពក្នុងការស្តាប់បង្គាប់ ទេ

ការវែកញែក ១២ : មនុស្សមិនត្រូវខំបើកចូលទៅក្នុងបំណងព្រះហប្ញទ័យ លាក់កំបាំងរបស់ព្រះឡើយ

ការវែកញែក ១៣ : ក្រិត្យវិន័យបង្ហាញពីសេចក្តីកម្សោយរបស់មនុស្ស និងអំណាចសង្គ្រោះរបស់ព្រះ

ការវែកញែក ១៤ : សេចក្តីបង្រៀននៅក្នុងគម្ពីរសញ្ញាថ្មី ត្រូវបានប្រទានមកដើម្បីនាំផ្លូវដល់អ្នកដែលបានរាប់ជាសុចរិត

ការវែកញែក ១៥ : មូលដ្ឋាននៃការប្រទានរង្វាន់ គឺជាសេចក្តីសន្យារបស់ព្រះ មិនមែនជាបុណ្យកុសលរបស់មនុស្សទេ

ការវែកញែក ១៦ : អំណាចគ្រប់គ្រងរបស់ព្រះ មិនបំផ្លាញទំនួលខុសត្រូវ របស់យើងទេ

## ការវែកញែក ១ : និយមន័យនៃ "ឆន្ទៈសេរី" របស់អ៊ែរ៉ាស្មឹស

ដើម្បីឲ្យយុត្តិធម៌ ខ្ញុំត្រូវតែដកស្រង់និយមន័យនៃ "ឆន្ទៈសេរី" របស់អ្នកផ្ទាល់ ដែលនិយាយថា "ខ្ញុំយល់ថាឆន្ទៈសេរីគឺជាអំណាចនៃឆន្ទៈមនុស្ស ដែលមនុស្សម្នាក់អាចអនុវត្តដោយខ្លួនឯងផ្ទាល់ចំពោះការនានាដែលនាំទៅកាន់ជីវិតអស់កល្បជានិច្ច ឬបែរចេញពីការទាំងអស់នោះវិញ។

អ្នកមិនអាចហៅការនេះជានិយមន័យបានទេ! និយមន័យមួយគួរតែមានភាពច្បាស់លាស់ ប៉ុន្តែផ្នែកនិមួយៗនៃសំដីខាងលើ ត្រូវតែបានពន្យល់ឲ្យបានច្បាស់។ មិនតែប៉ុណ្ណោះ នៅពេលអ្នកចាប់ផ្តើម អ្នកឲ្យនិយមន័យវាថាជាអ្វីមួយ ប៉ុន្តែនៅចុងបំផុតបែរជាឲ្យនិយមន័យថាវាជាអ្វីមួយផ្សេងទៀតទៅវិញ។ ខ្ញុំចង់និយាយថា មានតែព្រះប៉ុណ្ណោះដែលមានសេរីភាពនៃឆន្ទៈដែលអ្នកកំពុងពិពណ៌នានេះ ប៉ុន្តែអ្នកបែរជាស្មានថាវាជារបស់មនុស្សទៅវិញ។ ប៉ុន្តែមនុស្សម្នាក់គឺដូចជាទាសករដែលសេរីភាពរបស់គាត់គឺត្រូវតែស្តាប់បង្គាប់ចៅហ្វាយគាត់ប៉ុណ្ណោះ។ មនុស្សធ្វើអ្វីៗទៅតាមតែការបង្គាប់របស់ព្រះប៉ុណ្ណោះ។ តើនោះជា "សេរីភាពនៃឆន្ទៈ" ដូចដែលអ្នកពិពណ៌នាឬ?

ឥឡូវនេះខ្ញុំត្រូវតែដកអ្វីដែលហៅថានិយមន័យនេះចេញ។ ផ្នែកខ្លះមានភាពច្បាស់លាស់គ្រប់គ្រាន់ហើយ ប៉ុន្តែខ្ញុំត្រូវតែបង្ហំផ្នែកផ្សេងៗទៀតជាចំហមុននឹងខ្ញុំអាចវាយប្រហារពួកវា។ ពួកគេហាក់ដូចជាខ្លាចពន្លឺ ប្រៀបដូចជាពួកគេមានទោសពីអ្វីមួយ។ ខ្ញុំនឹងចាប់ផ្តើមដោយការឧបមាថា "អំណាចនៃឆន្ទៈមនុស្ស"

ដែលអ្នកបានលើកឡើង គឺជាអំណាចដើម្បីជ្រើសរើស ឬក៏បដិសេធអ្វីមួយ ជាអំណាចដើម្បីគាំទ្រ ឬក៏មិនគាំទ្រ។ ការនេះពិតជាមុខងារឆន្ទៈរបស់មនុស្ស។ ប៉ុន្តែអ្នកបានបន្ថែមថា៖ “ដែលមនុស្សម្នាក់អាចអនុវត្តដោយខ្លួនឯងផ្ទាល់ចំពោះ...”។ អ្វីដែលអ្នកកំពុងធ្វើនេះ គឺកំពុងតែដើម្បីបំបែកមនុស្សម្នាក់ពីឆន្ទៈរបស់គាត់ហើយ។ អ្នកឲ្យអំណាចដល់មនុស្សដើម្បីដឹកនាំឆន្ទៈរបស់ពួកគេ។ ប៉ុន្តែឆន្ទៈរបស់មនុស្សម្នាក់គឺជាផ្នែកនៃខ្លួនគាត់ផ្ទាល់គឺ វាជាផ្នែករបស់គាត់ដែលធ្វើការសំរេចចិត្ត។ ច្បាស់ណាស់ គឺដើម្បីបំបែកមនុស្សចេញពីឆន្ទៈរបស់គាត់ ហើយឲ្យអំណាចដល់គាត់គ្រប់គ្រងលើឆន្ទៈរបស់គាត់។ នេះគឺជាគំនិតដែលមិនសមហេតុផលទាល់តែសោះ! ប្រសិនបើខ្ញុំភាន់ច្រឡំលើអ្នក នោះជាកំហុសរបស់អ្នក ព្រោះតែអ្នកមិនបានសរសេរឲ្យបានច្បាស់លាស់!

ឥឡូវនេះតើអ្វីខ្លះជាការដែល “នាំទៅកាន់សេចក្តីសង្គ្រោះអស់កល្បជានិច្ច”? នោះត្រូវតែជាព្រះបន្ទូល និងកិច្ចការរបស់ព្រះ។ គ្មានអ្វីផ្សេងទៀតដែលនាំយើងទៅសេចក្តីសង្គ្រោះអស់កល្បបានឡើយ។ ប៉ុន្តែចិត្តមនុស្សមិនអាចយល់បាននូវអត្ថន័យនៃសេចក្តីសង្គ្រោះបានឡើយ។ សាវក ប៉ុល បាននិយាយថា គ្មានភ្នែកណាដែលបានឃើញ គ្មានត្រចៀកណាដែលបានឮ គ្មានគំនិតណាដែលបានយល់នូវអ្វីដែលព្រះបានរៀបចំសំរាប់ពួកអ្នកដែលស្រឡាញ់ទ្រង់ឡើយ។ បន្ទាប់មកគាត់បានបន្តនិយាយពីរបៀបដែលយើងអាចស្គាល់ការទាំងអស់នេះ គឺថា ព្រះបានបើកសំដែងការនេះដល់យើងរាល់គ្នាដោយព្រះវិញ្ញាណរបស់ទ្រង់។ ការនេះត្រូវតែមានន័យថា បើគ្មានព្រះវិញ្ញាណ នោះយើងមិនអាចស្គាល់សេចក្តីសង្គ្រោះ

នេះបានឡើយ ហើយយើងក៏មិនអាចអនុវត្តដោយខ្លួនយើងទៅនឹងការនេះបានដែរ។

មនុស្សដែលមានការអប់រំខ្ពង់ខ្ពស់មួយចំនួននៅក្នុងពិភពលោកនេះ បានស្គាល់ ហើយបានចាត់ទុកថាសេចក្តីខាងឯវិញ្ញាណគឺជាការឥតន័យ។ ជាការពិតណាស់ កាលណាគំនិតរបស់ពួកគេកាន់តែពូកែ សេចក្តីពិតខាងឯព្រលឹងវិញ្ញាណកាន់តែគួរឲ្យអស់សំណើចចំពោះពួកគេ។ មនុស្សអាចស្គាល់ភាពពិតនៃសេចក្តីខាងព្រលឹងវិញ្ញាណនៅក្នុងចិត្តរបស់ពួកគេបាន ដោយព្រោះតែព្រះវិញ្ញាណបរិសុទ្ធបំភ្លឺពួកគេប៉ុណ្ណោះ។

បន្ទាប់មកទៀត អ្នកបានប្រាប់យើងថា “ឆន្ទៈសេរី” គឺជាអំណាចនៃឆន្ទៈមនុស្សផ្ទាល់ ដែលអាចសំរេចទទួល ឬមិនទទួលព្រះបន្ទូល និងកិច្ចការរបស់ព្រះ។ ការនេះត្រូវធ្វើឲ្យឆន្ទៈមនុស្សអាចជ្រើសរើសស្ថានសួគ៌ ឬក៏ស្ថាននរក។ វាន័យថា គ្មានកន្លែងសំរាប់ព្រះវិញ្ញាណបរិសុទ្ធ ឬព្រះគុណរបស់ព្រះ។ ការធ្វើយ៉ាងនេះមានន័យថា អ្នកដាក់ឆន្ទៈមនុស្សលើថ្នាក់ជាមួយនឹងព្រះហើយ។

ពួកអ្នកដែលគេហៅថា Pelagians (ពួកអ្នកជឿលើឆន្ទៈសេរីមុនដំបូង) ក៏ធ្វើយ៉ាងដូច្នោះដែរ។ ប៉ុន្តែអ្នកធ្វើឲ្យវារីកចំរើនឡើងលើមូលដ្ឋានរបស់ពួកគេ! ពួកគេបែងចែក “ឆន្ទៈសេរី” ជាពីរផ្នែកគឺ៖ អំណាចដើម្បីយល់ពីភាពខុសគ្នារវាងការនានា ហើយនិងអំណាចដើម្បីជ្រើសរើសសេចក្តីអស់កល្ប ដែលមិនអាចយល់ទាំងស្រុងបាន។ តែអ្នកវិញ អ្នកបានបង្កើត “ឆន្ទៈសេរីពាក់កណ្តាល” ប៉ុណ្ណោះ!

ហើយអ្នកក៏កំពុងតែប្រឆាំងនឹងខ្លួនឯងផងដែរ ពីព្រោះនៅពេលមួយអ្នកបាននិយាយថា ឆន្ទៈមនុស្សមិនអាចធ្វើអ្វីបានទេបើគ្មានព្រះគុណ។ ប៉ុន្តែនៅពេលអ្នកសរសេរនិយមន័យនៃ "ឆន្ទៈសេរី" អ្នកបែរជាអនុញ្ញាតិឲ្យសេរីភាពពេញលេញដល់ឆន្ទៈរបស់មនុស្សទៅវិញ។ អ្នកឯងពិតជាមនុស្សចំឡែកមែន!

ខ្ញុំចូលចិត្តការបង្រៀនរបស់ទស្សនៈវិទូចាស់ៗមួយចំនួន ជាជាងការបង្រៀនរបស់អ្នក។ ពួកគេបាននិយាយថា មនុស្សចង់តែធ្វើខុសប៉ុណ្ណោះ។ មនុស្សអាចធ្វើល្អបាន ជាមួយនឹងជំនួយនៃព្រះគុណ។ ពួកគេបាននិយាយថា មនុស្សមានសេរីភាពដើម្បីធ្លាក់ចុះ ប៉ុន្តែត្រូវការជំនួយដើម្បីងើបឡើង! ប៉ុន្តែវាគួរឲ្យអស់សំណើច ដែលហៅការនោះថា "ឆន្ទៈសេរី"។ លើមូលដ្ឋានទាំងអស់នោះ ខ្ញុំអាចនិយាយថា ថ្មមួយដុំដែលមាន "ឆន្ទៈសេរី" ពីព្រោះវាអាចតែធ្លាក់ចុះប៉ុណ្ណោះ ប្រសិនបើគ្មានអ្នកណាម្នាក់លើកវាឡើងទេនោះ! សេចក្តីបង្រៀននៃទស្សនវិទូល្អជាងសេចក្តីបង្រៀនរបស់អ្នក។ ចំឡែកមែនទែនដែលថ្មរបស់អ្នកអាចជ្រើសរើសឡើងចុះដោយខ្លួនឯងបាន!

## ការវែកញែក ២ ៖ ការវែកញែកចេញពីកណ្ឌមួយនៅក្នុងសៀវភៅអាប៉ូគ្រីហ្វារបស់ អ៊ែរ៉ាស្មឹស

អ្នកវែកញែកថា ករណីសំរាប់"ឆន្ទៈសេរី" របស់អ្នកពីកណ្ឌ Ecclesiasticus ១៥:១៤-១៧។ "កាលពីដើមដំបូងព្រះបានបង្កើតមនុស្ស ហើយបានទុកមនុស្ស

នោះនៅក្នុងការបង្គាប់របស់ទ្រង់”។ អ្នកសរសេរក៏បានបន្ថែមពាក្យពេចន៍ខាងក្រោមអំពីបញ្ញត្ត និងច្បាប់សីលធម៌របស់ព្រះផងដែរថា “ប្រសិនបើឯងចង់កាន់តាមបញ្ញត្តព្រះ និងរក្សាសេចក្ដីជំនឿដែលធ្វើឲ្យអញសព្វព្រះទ័យ នោះបញ្ញត្ត និងសេចក្ដីជំនឿនោះនឹងការពារថែរក្សាឯង។ ទ្រង់បានដាក់ទឹក និងភ្លើងនៅពីមុខឯងហើយ អ្នកនៅតែឈោងដៃទៅចាប់ទេ។ ជីវិត និងសេចក្ដីស្លាប់នៅចំពោះមនុស្សហើយអ្វីក៏ដោយដែលធ្វើឲ្យទ្រង់សព្វព្រះទ័យនឹងត្រូវបានអត់ទោសឲ្យ”។ ខ្ញុំអាចបដិសេធចោលអត្ថបទភស្ដុតាងដែលស្នានៗនេះដោយនិយាយថា Ecclesiaticus មិនត្រូវបានរាប់បញ្ចូលទៅក្នុងព្រះគម្ពីរសញ្ញាចាស់ដោយពួកសាសន៍យូដាទេ ប៉ុន្តែដែលអ្នកផ្ទាល់គ្រាន់តែពន្យល់ថា វា “មិនសំខាន់ និងពិបាកយល់” នោះគ្រប់គ្រាន់ទៅហើយ។ វានឹងចំណាយពេលដ៏អស់កល្បមួយសំរាប់អ្នក ឬអ្នកដទៃណាទៀតសំរាប់បញ្ហានេះ ដើម្បីបង្កើតអត្ថបទមួយដែលប្រាប់យ៉ាងច្បាស់ថា “ឆន្ទៈសេរី” ជាអ្វី។

## ការវែកញែក ៣ : ទស្សនៈបីអំពី “ឆន្ទៈសេរី” របស់ អ៊ែរ៉ាស្មឹស

អ្នកបានបង្កើតទស្សនៈបីអំពី “ឆន្ទៈសេរី” ចេញពីទស្សនៈមួយ! អញ្ចឹងសូមយើងក្រឡេកមើលទស្សនៈទាំងបីនោះ។ ទីមួយគឺជាទស្សនៈដែលមនុស្សមិនអាចចង់ធ្វើល្អបាន។ មនុស្សមិនអាចចាប់ផ្ដើមវា ដើម្បីធ្វើឲ្យវារីកចំរើន ឬបញ្ចប់វា ដោយគ្មានព្រះគុណពិសេសបានទេ។ អ្នកហៅទស្សនៈនេះថា “តឹងរឹងប៉ុន្តែប្រហែលជាគ្រប់គ្រាន់”។

ទស្សនៈទីពីរ ជាអ្វីដែលអ្នកចាត់ទុកថា "តឹងរឹងជាង"គឺថា "ឆន្ទៈសេរី" ដែលអាចនាំយើងបានតែទៅឯបាបប៉ុណ្ណោះ ហើយព្រះគុណនោះតែមួយប៉ុណ្ណោះ ដែលអាចនាំទៅសេចក្តីល្អបាន។

ទស្សនៈទីបី ដែលអ្នកនិយាយគឺ "តឹងរ៉ឹងបំផុត" គឺជា "ឆន្ទៈសេរី" ដែលគ្មានន័យ ហើយព្រះជាបុព្វហេតុនៃសេចក្តីល្អនិងអាក្រក់នៅក្នុងយើង។

អ្នកត្រៀមខ្លួនដើម្បីទទួលយកទស្សនៈទីមួយនៃទស្សនៈទាំងនេះ ពីព្រោះវាផ្តល់ឲ្យមនុស្សនូវការខិតខំប្រឹងប្រែងមួយចំនួន ដែលគេអាចធ្វើបាន។ អ្នកនិយាយថា អ្នកប្រឆាំងនឹងទស្សនៈទីពីរ និងទីបី។ អ្នកហាក់ដូចជាមិនស្គាល់អំពីអ្វីដែលយើងកំពុងនិយាយទេ! ទាំងនេះជាទស្សនៈបីដែលមិនខុសគ្នាទេ។ ទស្សនៈទាំងបីនេះគឺដូចតែគ្នា តែគ្រាន់តែប្រើពាក្យពេចន៍ខុសគ្នានៅពេលវេលាខុសៗគ្នា ដោយគូរបដិបក្ខរបស់អ្នកប៉ុណ្ណោះ។ និយមន័យនៃ "ឆន្ទៈសេរី" របស់អ្នកគឺគ្មានអ្វីដូចជាទស្សនៈទីមួយដែលអ្នកបាននិយាយថាអាចទទួលយកបាន នោះទេ។ និយមន័យរបស់អ្នកចែងថា "ឆន្ទៈសេរី" អាចធ្វើទាំងល្អ និងអាក្រក់បាន។ ប៉ុន្តែទស្សនៈដែលអ្នកទទួលយកចែងថា ឆន្ទៈរបស់មនុស្សមិនអាចជ្រើសរើសធ្វើល្អដោយគ្មានជំនួយនៃព្រះគុណរបស់ព្រះបានទេ។ ឥឡូវនេះអ្នកមានឆន្ទៈពីរដែលប្រឆាំងគ្នាយ៉ាងខ្លាំង។ ដោយអ្នកទទួលយកទស្សនៈទីមួយ អ្នកបានឯកភាពថា "ឆន្ទៈសេរី" មិនអាចធ្វើល្អបាន។ ពីមុននេះបន្តិចអ្នកបាននិយាយថា "ឆន្ទៈរបស់មនុស្សអាក្រក់ណាស់ យ៉ាងនេះហើយបានជាវាបាត់សេរីភាពរបស់វា ហើយវាត្រូវបានបង្ខំឲ្យបំរើអំពើបាប ដោយមិនអាចមកឯសភាពល្អប្រសើរវិញបាន។ ប៉ុន្តែនៅពេលដែលខ្ញុំ

និយាយពីការដដែលអ្នកទើបបាននិយាយនេះ អ្នកបែរជានិយាយថា៖ "គ្មានអ្វីដែលល្ងីល្ងើពេកដែលគេធ្លាប់លឺនោះទេ"។ អ្វីដែលអ្នកសរសេរមានន័យថា ការព្យាយាមធ្វើល្អគឺទាំងនៅក្នុង "ឆន្ទៈសេរី" និងទាំងមិននៅក្នុង "ឆន្ទៈសេរី" នៅពេលតែមួយ។ ប្រសិនបើការនេះមិនមែនជាការធម្មតា ខ្ញុំចង់ដឹងថា នោះជាអ្វីទៅ!

ការថ្លែងនានារបស់អ្នកផ្ទុយគ្នាខ្លាំងណាស់ រហូតដល់គ្មានលទ្ធភាពគាំទ្រគ្នាបាន។ គ្មានជំហរកណ្ដាលរវាងឃ្លា "អាចធ្វើល្អ" និងឃ្លា "មិនអាចធ្វើល្អ" ទេ។

ទស្សនៈទីពីរនិងទីបីដែលអ្នកបានពិពណ៌នា មិនមានការណាមួយដែលមិនបានរកឃើញនៅក្នុងទស្សនៈទីមួយនោះទេ។ ទាំងបីនេះសុទ្ធតែត្រូវគ្នាទាំងអស់។ អ្នកនិយាយថា អ្នកប្រឆាំងតែនឹងទស្សនៈទីពីរនិងទីបីទេ ប៉ុន្តែនៅក្នុងទស្សនៈទាំងបីនោះអ្នកសុទ្ធតែនិយាយយ៉ាងច្បាស់ថា ឆន្ទៈរបស់មនុស្សបាត់បង់សេរីភាពរបស់វា។ មិនតែប៉ុណ្ណោះ វាត្រូវបានចងភ្ជាប់នឹងការបំរើអំពើបាប ហើយមិនអាចធ្វើល្អបានទេ។ ឥឡូវនេះប្រសិនបើវាជាការពិតមែន វាធ្វើតាមនៅពេលមនុស្សធ្វើអាក្រក់។ មនុស្សធ្វើយ៉ាងដូច្នេះ ពីព្រោះគេត្រូវតែធ្វើ ដោយមិនអាចជៀសវាងបាន។

## ការ វែក ញែក ៩ : ការ ត្រឡប់ ទៅ កាន់ ការ វែក ញែក របស់ អែរ៉ាស្មើស ពី Ecclesiasticus ១៥:១៤-១៧

សូមយើងត្រឡប់ទៅឯអត្ថបទនេះពីសៀវភៅអាប៉ូគ្រីហ្វា ហើយប្រៀបធៀបវាជាមួយនឹងទស្សនៈទីមួយនៃទស្សនៈទាំងបីដែលយើងទើបតែបាននិយាយខាងដើមនេះ។ អ្នកប្រហែលជាអាចគិតថាត្រឹមត្រូវ នូវទស្សនៈដែលថា "ឆន្ទៈសេរី" មិនអាចធ្វើល្អបាន។ ប៉ុន្តែអត្ថបទដែលគេដកស្រង់ពី Ecclesiasticus ដើម្បីបង្ហាញថា "ឆន្ទៈសេរី" អាចធ្វើល្អបានខ្លះដែរ។ យោងទៅតាមអ្វីដែលអ្នកបាននិយាយ អត្ថបទនេះគួរតែគាំទ្រទស្សនៈទីមួយ ប៉ុន្តែវាមិនបាននិយាយអ្វីទាំងអស់អំពីការនោះ។ អ្នកអាចនឹងដកស្រង់អត្ថបទមួយអំពីលោក ពីឡាត់ចៅហ្វាយខេត្តស៊ីរី មកបង្ហាញថា ព្រះគ្រីស្ទគឺជាព្រះម៉ែស៊ី!

ប៉ុន្តែដើម្បីឲ្យយុត្តិធម៌ យើងនឹងក្រឡេកមើលឯ Ecclesiasticus ១៥:១៤-១៧។ អត្ថបទនេះចាប់ផ្តើមថា៖ "កាលដើមឡើយព្រះបានបង្កើតមនុស្ស ហើយបានទុកមនុស្សនោះនៅក្នុងព្រះហស្តនៃការប្រឹក្សារបស់ទ្រង់"។ មកដល់ចំនុចនេះមិនមានសេចក្តីពិតយោងចំពោះសេចក្តីបង្គាប់នេះទេ។ ឆន្ទៈរបស់មនុស្សមានសេរីភាពទាំងស្រុង នៅពេលដែលព្រះតាំងឲ្យគេធ្វើជាម្ចាស់លើអ្វីៗទាំងអស់។ ប៉ុន្តែបន្ទាប់មក គេបាននិយាយថា ព្រះបានបន្ថែមសេចក្តីបង្គាប់និងក្រមសីលធម៌របស់ទ្រង់ ដោយមានបន្ទូលថា "ប្រសិនបើឯងពេញចិត្តកាន់តាមសេចក្តីបង្គាប់របស់អញ..."។ នេះក៏ជាការពិតផងដែរ។ ព្រះបានយកមនុស្សពីកន្លែងនៃរាជ្យរបស់ទ្រង់ ហើយបន្ទាប់មកព្រះបានដាក់មនុស្សនៅក្រោមការបង្គាប់របស់ទ្រង់។

មនុស្សមិនមានសេរីភាពទេ។ ដូច្នេះយើងឃើញថា វាអាចទៅរួចក្នុងការយល់តាមរបៀបមួយដែលឯកភាពជាមួយនឹងខ្ញុំ ហើយមិនឯកភាពជាមួយអ្នក! ការយល់ដឹងរបស់ខ្ញុំពីអត្ថបទនេះ ឯកភាពជាមួយបទគម្ពីរទាំងមូល។ ការយល់ដឹងរបស់អ្នកនៃអត្ថបទនេះ បែរជាធ្វើឲ្យវាប្រឆាំងនឹងបទគម្ពីរទាំងមូលទៅវិញ។

## ការវែកញែក ៥ : ការពន្យល់បន្ថែមពីការប្រើប្រាស់ Ecclesiasticus ១៥:១៤-១៧ របស់ អែរ៉ាស្មឹស

ខ្ញុំសូមលើកពីឃ្លាដែលថា “ប្រសិនបើអ្នកចង់កាន់តាម...” មកបង្ហាញថា មនុស្សអាចជ្រើសរើសដោយសេរី។ ការវែកញែកបែបនោះ ដោយព្រោះវិនិច្ឆ័យព្រះបន្ទូលរបស់ផងព្រះតាមហេតុផលរបស់មនុស្ស។ ខ្ញុំអាចបង្ហាញថា សូម្បីតែតាមហេតុផលរបស់មនុស្ស ឃ្លាដែលថា “បើអ្នកចង់កាន់តាម...” មិនតែងតែមានន័យថា ជាសមត្ថភាពមួយដែលអាចស្ដាប់បង្គាប់នោះទេ។ ឧទាហរណ៍៖ ជាញឹកញាប់ឪពុកម្ដាយប្រាប់ដល់កូនរបស់ពួកគាត់ឲ្យធ្វើអ្វីមួយ។ នោះមិនដើម្បីបង្ហាញពីអ្វីដែលពួកគេអាចធ្វើទេ ប៉ុន្ដែដើម្បីបង្ហាញពីអ្វីដែលពួកគេមិនអាចធ្វើវិញ យ៉ាងនោះដើម្បីឲ្យពួកគេចេះស្រែកហៅរកជំនួយ។

នេះ ជា របៀប ដែល ព្រះ ជួយ ដោះ ស្រាយ ឲ្យ យើង។  ទ្រង់ បាន ប្រទាន ក្រឹត្យវិន័យ ដល់ យើង  ដើម្បី បង្ហាញ ឲ្យ ឃើញ ពី អសមត្ថភាព ទាំង ស្រុង របស់ មនុស្សក្នុងការកាន់តាមក្រិត្យវិន័យនោះ។ នេះគឺជាការបង្រៀនរបស់សាវក ប៉ុល

នៅក្នុងគម្ពីររ៉ូម ៣:២០; ៥:២០; កាឡាទី ៣:១៩,២៤។

## ការវែកញែក ៦ : ការវែកញែកនានារបស់អេរ៉ាស្មឹស ត្រូវតែមានន័យថា ឆន្ទៈរបស់មនុស្សគឺមានសេរីភាពពេញទី

នេះគឺជាការផ្ទុយស្រឡះគ្នាមួយនៅក្នុងការវែកញែករបស់អ្នក។ ម្យ៉ាងវិញទៀត អ្នកនិយាយពាក្យពេចន៍ពី Ecclesiasticus ១៥:១៤-១៧ (បើអ្នកចង់កាន់តាម...") មានន័យថាមនុស្សមានឆន្ទៈសេរី ឬមិនមាន។ ប៉ុន្តែអ្នកក៏បាននិយាយផងដែរថា ទស្សនៈទីមួយនៃទស្សនៈដែលអាចទៅរួចទាំងបីដែលទើបតែបាននិយាយថាប្រហែលជាពិត។ ប៉ុន្តែទស្សនៈនោះបាននិយាយថា "ឆន្ទៈសេរី" មិនអាចធ្វើល្អបានឡើយ។ អ្នកមិនអាចមានវាទាំងពីររបៀបបានឡើយ!

ឥឡូវនេះ Ecclesiasticus មិននិយាយថា៖ "បើឯងចង់ព្យាយាមកាន់តាមបញ្ញត្តរបស់អញ..." នោះទេ។ វាចែងថា៖ "បើឯងចង់កាន់តាមបញ្ញត្តរបស់អញ..." ។ ដូច្នេះប្រសិនបើ Ecclesiasticus កាន់ខាង "ឆន្ទៈសេរី" មានន័យថានោះជាសេរីភាពពេញលេញមួយហើយ មិនមែនតែពាក់កណ្ដាលនោះទេ។

នេះគឺជាការសន្និដ្ឋានមួយ ដែលពួកអ្នកដែលគេហៅថា Pelagians ឈោងចាប់ពាក្យទាំងនេះ។

អ្នកណាដែលមិនឯកភាពជាមួយពួក Pelagians នឹងមានបញ្ហាធំមួយ។

អ្នកនោះអាចនឹងគ្រាន់តែចង់បាន “ឆន្ទៈសេរី” បន្តិចបន្តួចនៅក្នុងអត្ថបទនោះ ដូចជាអ្នកចង់បានយ៉ាងដូច្នោះដែរ។ មានន័យថា មនុស្សម្នាក់មានសេរីភាពក្នុងការដែលគាត់ចង់និងព្យាយាមស្តាប់បង្គាប់ព្រះ។ ពួក Pelagians អាចនឹងឆ្លើយដោយនិយាយថា អត្ថបទនោះបង្រៀនយើងពី “ឆន្ទៈសេរី” ទាំងស្រុង ឬក៏ចំណែងនៃឆន្ទៈទាំងស្រុង។ ហើយពួកគេអាចនឹងធ្វើការវែកញែកលើសពីហ្នឹងទៀត ព្រោះអត្ថបទនោះចែងថា “ប្រសិនបើអ្នករក្សាសេចក្តីជំនឿ...”។ ជាលទ្ធផល ពួកគេបង្រៀនថាមនុស្សមានសេរីភាពក្នុងការជឿ។ ប៉ុន្តែនៅក្នុងបទគម្ពីរសាវក ប៉ុល បានធ្វើការវែកញែកយ៉ាងម៉ឺងម៉ាត់ថា ជំនឿគឺជាអំណោយទានពិសេសមួយរបស់ព្រះ (អេភេសូរ ២:៨)។

ប៉ុន្តែខ្ញុំត្រូវតែត្រឡប់ទៅឯការវែកញែករបស់ខ្ញុំវិញថា Ecclesiasticus មិនបានបង្រៀនពី “ឆន្ទៈសេរី” ទេ។ វាពិតជាខុសឆ្គងណាស់ដែលវែកញែកពាក្យថា “ប្រសិនបើអ្នកចង់” ត្រូវតែមានន័យថា “ដូច្នេះអ្នកអាច”។ លោកអ័ដាមជាមនុស្សទីមួយដែលព្រះគុណរបស់ព្រះបានជួយ តែគាត់មិនបានស្តាប់បង្គាប់។ ប្រសិនបើលោកអ័ដាមមិនបានស្តាប់បង្គាប់ទៅហើយ តើយើងអាចធ្វើអ្វីបាន មុនពេលដែលយើងមានព្រះគុណណាមួយនោះ? “ឆន្ទៈសេរី” គ្មានអំណាចសោះ។ ប្រសិនបើអ្នកដាក់ស្ថានភាពរបស់លោកអ័ដាមនៅក្បែរ Ecclesiasticus ១៥:១៤-១៧ អ្នកនឹងឃើញថាអត្ថបទនេះមិនបានកាន់ជើង “ឆន្ទៈសេរី” នោះទេ តែជាការវែកញែកដ៏មានឥទ្ធិពលមួយដែលប្រឆាំងនឹង “ឆន្ទៈសេរី” វិញ។ អត្ថបទនេះបង្រៀនពីកាតព្វកិច្ចរបស់យើងក្នុងការធ្វើតាមព្រះហឫទ័យរបស់ព្រះ គឺមិនមែនជាសមត្ថភាព

របស់យើងដែលអាចស្តាប់បង្គាប់ព្រះឡើយ។

## ការរែកញែក ៧ : លោកុប្បត្តិ ៤:៧-ជាអត្ថបទមួយផ្សេងទៀតដែលបង្ហាញថា ការបង្គាប់មួយ មិនមានន័យថា ជាសមត្ថភាពក្នុងការស្តាប់ បង្គាប់នោះទេ

អត្ថបទនេះគឺថា “អំពើបាបកំពុងតែនៅឯមាត់ទ្វាររបស់អ្នក”។ វាចង់បានអ្នក ប៉ុន្តែអ្នកត្រូវតែធ្វើជាម្ចាស់របស់វា”។ អ្នកបានដកស្រង់ពាក្យទាំងនេះមកបង្ហាញថា អាចយកឈ្នះគំនិតអាក្រក់ ហើយមិនត្រូវបាននាំទៅធ្វើបាបឡើយ។ អ្នកបានប្រឆាំងនឹងខ្លួនឯងជាថ្មីម្តងទៀតហើយ។ អ្នកបាននិយាយហើយថា ទស្សនៈដែលទំនងជាពិត គឺជាទស្សនៈដែលនិយាយថា ឆន្ទៈរបស់មនុស្សមិនអាចចង់ធ្វើល្អបាន។ ប៉ុន្តែនៅទីនេះអ្នកបាននិយាយថា មនុស្សមិនអាចយកឈ្នះលើសេចក្តីប្រាថ្នាខាងការអាក្រក់ ដោយគ្មានជំនួយពីព្រះគ្រីស្ទ ឬព្រះវិញ្ញាណបរិសុទ្ធទៅវិញ។

ជាការពិតណាស់ អត្ថបទនេះគឺកំពុងតែមិនបង្រៀនអ្វីទាល់តែសោះ។ វាគឺជាគំរូមួយទៀតរបស់មនុស្ស ដែលកំពុងតែត្រូវបានបង្ហាញថា អ្វីដែលមនុស្សគួរធ្វើ ហើយអ្វីដែលមនុស្សមិនអាចធ្វើ។ គំរូមួយទៀតគឺជាបញ្ញត្តទីមួយគឺថា “កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ”។ អត្ថបទនានាគឺជាបញ្ញត្តិ ហើយបញ្ញត្តិមិនបង្ហាញឲ្យឃើញពីសមត្ថភាពដើម្បីស្តាប់បង្គាប់ឡើយ។ តែវាបង្ហាញពីអសមត្ថភាព ដូចជានៅក្នុងករណីកាអ៊ីនវិញ។

## ការវែកញែក ៨ : ចោទិយកថា ៣០:១៩- ក្រិត្យវិន័យត្រូវបានរៀបចំឡើង ដើម្បីផ្តល់ចំណេះដឹងពីអំពើបាប

នេះជាអត្ថបទទីបីដែលអ្នកឯកស្រង់ដោយមានទំនោរលើ “ឆន្ទៈសេរី”។ វាចែងថា៖ “អញបានដាក់សំណែងទាំងជីវិតនិងសេចក្តីស្លាប់ ទាំងព្រះពរនិងសេចក្តីបណ្តាសានៅមុខឯងរាល់គ្នា ដូច្នេះចូររើសយកជីវិតចុះ”។ អ្នកនិយាយថា៖ “តើមានអ្វីទៀតដែលអាចនឹងច្បាស់ជាង ដែលថាមនុស្សម្នាក់មានសេរីភាពរួចពីជំរើសនោះ? ប៉ុន្តែខ្ញុំសូមតបថា អ្នកកំពុងតែខ្វាក់ហើយ! នៅពេលដែលលោកម៉ូសេបាននិយាយថា៖ “ចូររើសជីវិតយកជីវិតចុះ” តើពួកមនុស្សម្នាបានជ្រើសរើសយកជីវិតដែរឬទេ? ប្រសិនបើពួកគេបានរើសយកមែននោះ ប្រហែលជាមិនបាច់ត្រូវការកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធទេ។

អ្នកនិយាយថា៖ វាជាការគួរឲ្យអស់សំណើចដែលនិយាយទៅមនុស្សម្នាក់ដែលកំពុងតែឈរត្រង់ផ្លូវពីរប្រសព្វគ្នាថា “ចូរទៅតាមផ្លូវណាមួយក៏បានដែរ តាមតែអ្នកចូលចិត្ត” នៅខណៈពេលដែលមានផ្លូវតែមួយប៉ុណ្ណោះដែលបើកឲ្យគាត់។ នេះគឺជាការបង្ហាញផ្លូវដ៏ល្ងីល្ងើណាស់! ជាការពិតដែលយើងឈរនៅឯផ្លូវប្រសព្វមួយ ប៉ុន្តែផ្លូវទាំងពីរ (មិនមែនតែមួយប៉ុណ្ណោះទេ) ត្រូវបានបិទ ហើយយើងមិនអាចដើរចូលបានឡើយ។ យើងមិនអាចឡើងលើផ្លូវដែលនាំទៅរកសេចក្តីល្អបានទេ ប្រសិនបើគ្មានព្រះគុណរបស់ព្រះ។ យើងកាន់តែមិនអាចសូម្បីតែដើរលើផ្លូវមួយទៀតបាន បើគ្មានការអនុញ្ញាតិរបស់ព្រះ! នៅក្នុងគម្ពីររ៉ូម ៣:២០ សាវក ប៉ុល មិនបាននិយាយថា៖ “ ក្រិត្យវិន័យសំដែងឲ្យស្គាល់ពីអំណាច

ឬក៏សេចក្ដីល្អ” ទេ ។ គាត់ក៏មិនបាននិយាយថា៖ “ក្រិត្យវិន័យជាអំណាចនៃឆន្ទៈ” នោះដែរ។ គាត់និយាយថា៖ “ក្រិត្យវិន័យសំដែងឲ្យស្គាល់អំពីអំពើបាប”។ ក្រិត្យវិន័យមិននិយាយពីអ្វីដែលមនុស្សអាចធ្វើនោះទេ ប៉ុន្តែនិយាយពីអ្វីដែលពួកគេគួរធ្វើវិញ។

បន្ទាប់មកអ្នកបានដកស្រង់ពីគម្ពីរចោទិយកថា ៣ អំពី “ការជ្រើសរើស” “ការបែរចេញ” និង “ការកាន់តាម”។ អ្នកនិយាយថា ប្រសិនបើមនុស្សមិនមានអំណាចដើម្បីធ្វើការទាំងអស់នេះបាន នោះក្រិត្យវិន័យនឹងទៅជាឥតន័យ។ ប៉ុន្តែបញ្ញត្តទាំងនេះនិយាយអំពីអ្វីដែលមនុស្សគួរធ្វើ។ ក្រិត្យវិន័យមិនមែនឥតន័យនោះទេ។ ក្រិត្យវិន័យត្រូវបានតាំងឡើងដើម្បីបង្រៀនមនុស្សដែលមានអំនួត ឲ្យស្គាល់ពីសេចក្តីកម្សោយរបស់ខ្លួន។ អ្នកព្យាយាមធ្វើឲ្យគោលជំហរនេះទៅជាគួរឲ្យអស់សំណើច ដោយការប្រដូចវាទៅនឹងមនុស្សម្នាក់ដែលត្រូវបានគេចងជាប់ទុកតែដៃខាងឆ្វេង។ ហើយគេប្រាប់អ្នកនោះថា នៅខាងស្តាំមានស្រាល្អ ហើយនៅខាងឆ្វេងមានថ្នាំពុល។ ហើយគេប្រាប់ឲ្យគាត់ជ្រើសរើសមួយក្នុងចំណោមរបស់ទាំងពីរនោះ។ តើអ្នកកំពុងតែព្យាយាមបង្ហាញពីអ្វី ដោយរូបភាពនេះ? តើអ្នកកំពុងតែព្យាយាមបង្ហាញពីសេរីភាពពេញលេញនៃឆន្ទៈរបស់មនុស្សឬ? អ្នកពូកែភ្លេចមែន! អ្នកបាននិយាយថា“ឆន្ទៈសេរី” មិនអាចធ្វើអ្វីបានដោយគ្មានព្រះគុណរបស់ព្រះបាន ។ អ្នកព្យាយាមធ្វើឲ្យគោលជំហររបស់ខ្ញុំគួរឲ្យអស់សំណើចដោយការបង្ហាញរបស់អ្នក ប៉ុន្តែសូមឲ្យខ្ញុំដាក់គោលជំហររបស់ខ្ញុំដោយការបង្ហាញដែលល្អជាងនេះវិញ។ នេះគឺជាមនុស្សម្នាក់ដែលដៃទាំងពីររបស់គាត់ត្រូវ

បានគេចង! បុរសនេះអួតថាគាត់មានសេរីភាពក្នុងការហុចដៃទៅស្ដាំទៅឆ្វេងបាន។ ដូច្នេះគេបង្គាប់ឲ្យគាត់ចូលមកក្នុងទិសដៅមួយ- មិនដើម្បីធ្វើឲ្យគាត់គួរឲ្យអស់សំណើចទេ ប៉ុន្តែដើម្បីបង្ហាញថា គាត់មិនអាចធ្វើវាបាន។ នៅក្នុងបទគម្ពីរយើងឃើញថាមនុស្សមិនត្រឹមតែជាប់ចំណងដោយអារក្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបាន ធ្វើឲ្យល្ងីល្ងើ ដែលគិតថាខ្លួនមានសេរីភាពក្នុងការធ្វើអ្វីដែលត្រឹមត្រូវទៀតផង។ ក្រិត្យវិន័យរបស់លោកម៉ូសេ ត្រូវបានផ្ដល់មកដើម្បីបង្ហាញថាមនុស្សត្រូវបានធ្វើឲ្យល្ងីល្ងើដោយសេរីភាពដ៏ស្រមើស្រមៃរបស់ពួកគេ។

## ការវែកញែក ៩ : ការភាន់ច្រឡំរបស់អេរ៉ាស្មឺសអំពីក្រិត្យវិន័យ និងដំណឹងល្អ

អ្នកលើកអត្ថបទជាច្រើនមកបង្ហាញពីករណីរបស់ពួកអ្នក ប៉ុន្តែអ្នកបរាជ័យទាំងស្រុង ក្នុងការបង្ហាញពីភាពខុសគ្នារវាងច្បាប់និងដំណឹងល្អ។ សូមឲ្យខ្ញុំបង្ហាញពីរបៀបដែលដំណឹងល្អត្រូវបានបង្រៀននៅក្នុងអត្ថបទនានាដែលអ្នកគិតថា វាសំដៅលើក្រិត្យវិន័យ។ ឧ៖ សូមមើលនៅក្នុងព្រះគម្ពីរយេរេមា ១៥:១៩ “បើឯងវិលមកវិញ នោះអញនឹងនាំឯងទៀត”, សាការី “ព្រះយេហូវ៉ា ជាព្រះនៃពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ ចូរវិលមកឯអញវិញ...នោះអញនឹងវិលមកឯឯងរាល់គ្នាវិញ”។ តើពាក្យថា “វិលបែរ” ពិតជាបង្ហាញថា មនុស្សម្នាក់មានសមត្ថភាពបែរ លើសពីពាក្យថា “ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ាជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំលាំងឯង” (ចោទិយកថា ៦:៥) បង្ហាញថា មនុស្សម្នាក់មានសមត្ថភាពក្នុងការស្រឡាញ់ព្រះឬអី? ពាក្យនេះមិនបានបង្ហាញថា មនុស្ស

អាចបែរមករកឯព្រះដោយកំលាំងផ្ទាល់របស់ខ្លួននោះទេ។ ប៉ុន្តែនៅពេលមនុស្ស បានស្គាល់ពីអ្វីដែលពួកគេគួរធ្វើ នោះពួកគេនឹងសួររកកន្លែងដែលពួកគេអាចរក ឃើញសមត្ថភាពក្នុងការស្តាប់បង្គាប់។ ពាក្យថា "វិលមកឯអញ" មិនមានន័យ ថា "ព្យាយាមបែរ" នោះទេ។ អ្នកនិយាយថាព្រះគុណគឺទំនេរសំរាប់ពួកអ្នកដែល ព្យាយាមបែរ។ ប៉ុន្តែនោះអាចនឹងធ្វើឲ្យផ្នែកទីពីរនៃខទាំងនោះមានន័យផងដែរថា "អញនឹងព្យាយាមវិលមកឯឯងរាល់គ្នាដែរ"! ការនោះអាចនឹងគួរឲ្យភ្ញាក់ផ្អើល! ប្រហែលជាព្រះគុណអាចនឹងទំនេរសំរាប់ព្រះដែរមើលទៅ!

ចូរចេញឲ្យឆ្ងាយពីការវែកញែកដែលឥតន័យទាំងអស់នេះ! ពាក្យថា "វិលបែរ" ត្រូវបានប្រើនៅក្នុងបទគម្ពីរទាំងនៅក្នុងរបៀប "ស្របច្បាប់" ទាំងនៅក្នុងរបៀប "ដំណឹងល្អ"។ នៅពេលវាត្រូវបានប្រើនៅក្នុងរបៀបស្របច្បាប់ វាជាការទាមទារមួយ មិនមែនគ្រាន់តែមនុស្សម្នាក់ព្យាយាមស្តាប់បង្គាប់នោះទេ ប៉ុន្តែជាការផ្លាស់ប្រែទាំងស្រុងមួយនៃជីវិតរបស់អ្នកនោះ (ឧ៖ យេរេមា ៤:១; ២៥:៥; ៣៥:១៥)។ នៅពេលដែលពាក្យថា "វិលបែរ" ត្រូវបានប្រើនៅក្នុងគំនិតខាងដំណឹងល្អ ដែលព្រះជាម្ចាស់បានមានបន្ទូលនោះ គឺជាសេចក្តីកំសាន្តចិត្ត និងសេចក្តីសន្យាមួយ ដែលគ្មានការទាមទារអ្វីទាំងអស់ពីយើងរាល់គ្នា ប៉ុន្តែជាព្រះគុណរបស់ព្រះដែលបានផ្តល់មកយើងរាល់គ្នាវិញ (ឧ៖ ទំនុកដំកើង ១៩:៧; ១១៦:៧; ១២៦:១)។ ហោរា សាការី បានដាក់បទគម្ពីរនេះនៅចំពោះយើងរាល់គ្នាទាំងក្រិត្យវិន័យ និងព្រះគុណ។ ក្រិត្យវិន័យទាំងមូលត្រូវបានសរុបមកក្នុងពាក្យថា "ចូរវិលមកឯអញ" ហើយព្រះគុណសរុបមកក្នុងពាក្យថា "អញនឹងវិលមកឯឯងរាល់គ្នា"។ អ្នកបាន

បកស្រាយចំពោះបទគម្ពីរអេសេគាល ១៨:២៣ តាមរបៀបដដែល។ “ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា តើអញមានសេចក្ដីអំណរដោយមនុស្សទុច្ចរិតស្លាប់ទៅ ឬតើមិនមែនអរដោយគេបែរចេញពីផ្លូវរបស់ខ្លួនវិលមក ឲ្យបានរស់នៅវិញទេឬអី”។ម្ដងទៀតហើយដែលអ្នកយកពាក្យថា “បែរចេញពីផ្លូវរបស់ខ្លួនវិល” មកសំដៅថា ជាសមត្ថភាពដែលអាចធ្វើដូច្នេះបាន។ អ្នកធ្វើឲ្យអត្ថបទនេះក្លាយជាក្រិត្យវិន័យជាជាងដំណឹងល្អទៅវិញ។ អ្នកធ្វើវាឲ្យក្លាយទៅជាការទាមទារមួយ ដែលយើងមិនគួរធ្វើបាប។ នោះឯងជាក្រិត្យវិន័យ។ ប៉ុន្តែព្រះយេហូវ៉ាបានមានបន្ទូលថា “តើអញមានសេចក្ដីអំណរដោយមនុស្សទុច្ចរិតស្លាប់ទៅឬ” ហើយមានបន្ទូលយ៉ាងច្បាស់ពីការដាក់ទណ្ឌកម្មអំពើបាប ដែលមនុស្សមានបាបសមនឹងទទួល ហើយភ្ញាក់រលឹក។ ព្រះកំពុងតែប្រទានឲ្យមនុស្សនូវសេចក្ដីសង្ឃឹមនៃការអត់ទោស និងសេចក្ដីសង្គ្រោះ។ ព្រះបន្ទូលនៃក្រិត្យវិន័យផ្ដោតសំខាន់លើពួកអ្នកដែលមិនមានអារម្មណ៍ និងមិនស្គាល់ពីអំពើបាបរបស់ខ្លួន។ ក្រឹត្យវិន័យបង្ហាញអោយពួកគេឃើញពីអ្វីដែលពួកគេត្រូវធ្វើ។ ប៉ុន្តែនៅពេលបន្ទាប់មក ដំណឹងត្រូវបានប្រកាសប្រាប់ទៅដល់ពួកអ្នកមានសេចក្ដីវេទនាដោយដឹងពីអំពើបាប និងពួកអ្នកដែលត្រូវបានល្បួងឲ្យធ្លាក់នៅក្នុងសេចក្ដីអស់សង្ឃឹម។

ដូច្នេះ ព្រះ បន្ទូល ក្នុង គម្ពីរ អេសេគាល ចែង ថា “តើ អញ មាន សេចក្ដី អំណរដោយមនុស្សទុច្ចរិតស្លាប់ទៅឬ” ខុសគ្នាឆ្ងាយពីការបង្ហាញពី “ឆន្ទៈសេរី” គឺមិនត្រឹមតែខុសគ្នាប៉ុណ្ណោះទេ គឺផ្ទុយគ្នាតែម្ដង។ ព្រះបន្ទូលនោះបង្ហាញថាពួកយើងជាមនុស្សអស់សង្ឃឹម ប្រសិនបើយើងរាល់គ្នាបានដាច់ចេញឆ្ងាយពីព្រះ

បន្ទូលនៃសេចក្តីសន្យារបស់ព្រះ។ ពិតមែនហើយ យើងកាន់តែអាក្រក់ទៅៗ រហូតទាល់តែព្រះបានប្រទានព្រះគុណមក។ ព្រះបន្ទូលអំពីសេចក្តីមេត្តាករុណា ពិតជាចាំបាច់ណាស់ក្នុងការសង្គ្រោះដល់មនុស្សមានបាប (លុះត្រាណាតែអ្នកគិតថាព្រះចូលចិត្តមានបន្ទូលច្រើន ដោយព្រោះទ្រង់សព្វព្រះទ័យ)។ គ្មានអ្នកណានឹងទទួលព្រះបន្ទូលនៃសេចក្តីសន្យានេះបានទេ លើកលែងតែពួកអ្នកដែលទ្រង់បង្ហាញឲ្យឃើញពីអំពើបាបរបស់ខ្លួនតាមរយៈក្រិត្យវិន័យប៉ុណ្ណោះ។ ពួកអ្នកដែលមិនស្គាល់ពីអំណាចនៃក្រិត្យវិន័យរបស់ព្រះ ហើយមិនមានសេចក្តីកោតខ្លាចដល់សេចក្តីស្លាប់ និងសេចក្តីជំនុំជំរះរបស់ព្រះ ជាពួកអ្នកដែលមិនចាប់អារម្មណ៍ដល់សេចក្តីសន្យាអំពីសេចក្តីមេត្តាករុណារបស់ព្រះ។

## ការវែកញែក ១០ : បំណងព្រះហឫទ័យបើកសំដែង និងបំណងព្រះហឫទ័យលាក់កំបាំង

បទគម្ពីរពីគម្ពីរអេសេគាលដែលយើងទើបតែពិចារណាអម្បាញ់មិញនេះ ហោរាអេសេគាល មិនមាននិយាយពាក់ព័ន្ធអ្វីទាំងអស់ទៅនឹងមូលហេតុដែលមនុស្សមួយចំនួនត្រូវបានកាត់ទោសដោយក្រិត្យវិន័យ ហើយអ្នកខ្លះទៀតមិនត្រូវបានកាត់ទោសទេ។ ហើយក៏មិនពាក់ព័ន្ធនឹងមូលហេតុដែលមនុស្សមួយចំនួនទទួលបានព្រះគុណរបស់ព្រះ ហើយអ្នកខ្លះមិនបានទទួលព្រះគុណដែរ។

យើង ត្រូវ ធ្វើ ឲ្យ មាន ការ បែង ចែក ដ៏ ច្បាស់ លាស់ មួយ រវាង បំណង

ព្រះហឫទ័យបើកសំដែងរបស់ព្រះ និងបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះ។ នៅក្នុងបំណងព្រះហឫទ័យលាក់កំបាំងរបស់ទ្រង់ ទ្រង់មានផែនការឲ្យពួកអ្នកដែលទ្រង់ជ្រើសរើសនឹងទទួលសេចក្តីមេត្តាករុណារបស់ទ្រង់។ យើងមិនត្រូវងឿងឆ្ងល់ពីរឿងនេះទេ តែយើងគួរស្រឡាញ់ទ្រង់ដោយគោរពវិញ។យើងត្រូវយកចិត្តទុកដាក់លើអ្វីដែលព្រះបានបើកសំដែងមកឯយើងរាល់គ្នាបានហើយ មិនបាច់យកចិត្តទុកដាក់លើអ្វីដែលទ្រង់ទុកសំរាប់ទ្រង់ផ្ទាល់នោះទេ។

អនុវត្តលើអត្ថបទរបស់យើង ការនេះមានន័យថា នៅក្នុងបំណងព្រះហឫទ័យដ៏លាក់កំបាំងរបស់ព្រះ ទ្រង់មិនបានមានវិប្បដិសារីនៃសេចក្តីស្លាប់របស់មនុស្សមានបាបទេ។ ប៉ុន្តែនៅក្នុងបំណងព្រះហឫទ័យបើកសំដែងរបស់ព្រះ ទ្រង់ព្រួយព្រះហឫទ័យចំពោះសេចក្តីស្លាប់ដែលទ្រង់បានឃើញនៅក្នុងរាស្ត្ររបស់ទ្រង់ ហើយដែលទ្រង់ធ្វើដូច្នោះ ដើម្បីអាចនឹងដកអំពើបាបនិងសេចក្តីស្លាប់ចេញ។ មិនអាចទៅរួចទេ ដែលបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះដឹកនាំផ្លូវយើងនោះ ដ្បិតយើងមិនដឹងថានោះជាអ្វីទេ។ វាគ្រប់គ្រាន់សំរាប់យើងហើយដោយគ្រាន់តែដឹងថា ពិតជាមានបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះមែនយ៉ាងនោះដើម្បីឲ្យយើងចេះកោតខ្លាចហើយស្រឡាញ់ទ្រង់។

ដូច្នេះវាពិតជាត្រឹមត្រូវដែលនិយាយថា វាជាកំហុសរបស់យើងប្រសិនបើយើងវិនាស បើយើងកំពុងនិយាយពីព្រះ តាមអ្វីដែលទ្រង់បង្ហាញអោយយើងដឹង ពីព្រោះកំហុសនោះ ពិតជានៅក្នុងឆន្ទៈរបស់មនុស្សមែន (ម៉ាថាយ ២៣:២៧)។ ប៉ុន្តែមូលហេតុថាព្រះមិនដកសេចក្តីកំហុសនេះពីគ្រប់មនុស្សទាំងអស់ ឬក៏មូល

ហេតុថាទ្រង់ឲ្យយើងទទួលខុសត្រូវ ចំពោះសេចក្តីកំហុសនេះនៅក្នុងពេលដែលយើងមិនអាចជៀសវាងវាបាន នោះមិនសំរាប់ឲ្យយើងសួរនោះទេ។ ទោះជាយើងសួរ យើងនឹងមិនអាចរកឃើញចម្លើយបានដែរ ដ្បិតសាវក ប៉ុល បាននិយាយនៅក្នុងគម្ពីររ៉ូម ៩:២០ ថា “ឱមនុស្សអើយ តើអ្នកជាអ្វី ដែលប៉ានឆ្លើយទាស់នឹងព្រះដូច្នេះ?”។

## ការវែកញែក ១១ : កាតព្វកិច្ច គឺគ្មានភស្តុតាងពីសមត្ថភាពក្នុងការស្តាប់បង្គាប់ទេ

អ្នកបានបន្តវែកញែកថា “ប្រសិនបើវាមិននៅក្នុងអំណាចនៃមនុស្សគ្រប់រូបដើម្បីឲ្យបានស្តាប់បង្គាប់នោះ គ្រប់ទាំងការលើកទឹកចិត្តនៅក្នុងបទគម្ពីរ គ្រប់ទាំងសេចក្តីសន្យា ការគំរាម ការស្តីបន្ទោស ព្រះពរ បណ្តាសា និងគំរូជាច្រើនទៀត នឹងមិនមានប្រយោជន៍សោះ”។ ប៉ុន្តែដូចជាខ្ញុំបានពន្យល់ជាច្រើនដងមកហើយថា អត្ថបទនៃបទគម្ពីរដែលតំរូវឲ្យមានកាតព្វកិច្ច មិនអាចយកមកប្រើដើម្បីបង្ហាញពីវត្តមាននៃ “ឆន្ទៈសេរី” ដូចដែលអ្នកបាននិយាយទេ។

អត្ថបទមួយនៃអត្ថបទនានាចុងក្រោយ ដែលអ្នកប្រើដើម្បីគាំទ្រគោលជំហររបស់អ្នកគឺគម្ពីរចោទិយកថា ៣០:១១-១៩ “ដ្បិតសេចក្តីបញ្ញត្តដែលអញបង្គាប់មកឯងនៅថ្ងៃនេះ មិនមែនហួសកំលាំងឯងទេ ក៏មិនមែននៅឆ្ងាយដែរ គឺមិនមែននៅលើស្ថានសួគ៌ ឲ្យឯងបានថា តើអ្នកណានឹងឡើងទៅស្ថានសួគ៌នាំយកព្រះបន្ទូលមកប្រាប់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបានប្រព្រឹត្តតាមនៅទេ ក៏មិន

មែននៅត្រើយសមុទ្រឯនាយ ឲ្យឯងបានថា តើអ្នកណានឹងឆ្លងសមុទ្រទៅនាំយកព្រះបន្ទូលមកប្រាប់យើងខ្ញុំ ដើម្បីឲ្យបានយើងខ្ញុំបានប្រព្រឹត្តតាមនោះដែរ គឺព្រះបន្ទូលនេះនៅជិតឯងណាស់ក៏នៅក្នុងមាត់ឯង និងក្នុងចិត្តឯងផង ដើម្បីឲ្យឯងអាចប្រព្រឹត្តតាមបាន"។

អ្នកនិយាយថាពាក្យទាំងនេះបង្ហាញថា មិនត្រឹមតែថាវាជាលទ្ធភាពសំរាប់យើងក្នុងការធ្វើអ្វីមួយដែលព្រះបានបង្គាប់ឲ្យធ្វើប៉ុណ្ណោះទេ វាថែមទាំងងាយស្រួលដូចជាបកចេកទៀតផង! ប៉ុន្តែប្រសិនបើនោះជាអត្ថន័យនៃអត្ថបទនេះ អញ្ចឹងយើងត្រូវនិយាយថា ព្រះគ្រីស្ទជាបុគ្គលល្ងីល្ងើដែលទ្រង់ធ្វើឲ្យខាតពេលវេលារបស់ទ្រង់។ ទ្រង់បានបង្ហូរព្រះលោហិតរបស់ទ្រង់ដើម្បីឲ្យបានព្រះវិញ្ញាណបរិសុទ្ធសំរាប់យើង នៅខណៈពេលដែលយើងមិនត្រូវការទ្រង់ ព្រោះយើងអាចធ្វើអ្វីៗដែលព្រះទាមទារបានទាំងអស់យ៉ាងងាយស្រួល និងដោយធម្មតា។ ប៉ុន្តែប្រសិនបើវាអញ្ចឹងមែន ចុះធ្វើដូចម្តេចឲ្យវាស្របនឹងការវែកញែករបស់អ្នកដែលថា ទស្សនៈដែលថា "ឆន្ទៈសេរី" មិនអាចធ្វើល្អដោយគ្មានព្រះគុណបាន? តើអ្នកពិតជាភ្លេចថាអ្នកបានសរសេរយ៉ាងដូច្នោះហើយឬ?

ដូច្នេះ ខ្ញុំមិនត្រូវការការពន្យល់នៃព្រះគម្ពីរចោទិយកថា ៣០:១១-១៤ របស់សាវក ប៉ុល នៅក្នុងគម្ពីររ៉ូម ១០:៨ ទេ។ ខ្ញុំត្រូវការមើលតែបទគម្ពីរនោះផ្ទាល់ប៉ុណ្ណោះ ដើម្បីឲ្យឃើញថា គ្មានពាក្យណាមួយដែលនិយាយអំពី "ឆន្ទៈសេរី"។ ឧ៖ តើពាក្យថា "មិនមែនហួសកំលាំងឯងទេ" និង"មិនមែននៅឆ្ងាយ" ហើយនិង"នៅលើស្ថានសួគ៌" ព្រមទាំង "នៅត្រើយសមុទ្រឯនាយ" មានន័យយ៉ាងដូចម្តេច?

ទាំងនោះគ្រាន់តែសំដៅលើអ្វីៗ ដែលយើងអាចនឹងព្យាយាមធ្វើប៉ុណ្ណោះ។ ទាំងនេះមិនបាននិយាយអ្វីទាំងអស់ពីសមត្ថភាពក្នុងការធ្វើការទាំងនេះ។ ទាំងនេះគ្រាន់តែសំដៅលើរយៈចំងាយប៉ុណ្ណោះ។ ខ្ញុំដឹងថាការទាំងអស់នេះជាហេតុផលរបស់កូនក្មេងប៉ុណ្ណោះ ប៉ុន្តែ តើអ្វីទៀត ដែលយើងអាចធ្វើនៅពេលដែលយើងប្រឈមមុខជាមួយនឹងការវែកញែកដ៏ល្ងីល្ងើបែបនេះ? ប្រាកដច្បាស់ណាស់ថា លោក ម៉ូសេ នៅក្នុងអត្ថបទនេះគឺជាអ្នកដែលផ្តល់ក្រឹត្យវិន័យដ៏ស្មោះត្រង់។ គាត់មិនលើកលែងឲ្យមនុស្សដែលខំដោះសាថាមិនស្គាល់ក្រិត្យវិន័យរបស់ព្រះជាអ្វីឡើយ។ ពួកគេមិនត្រូវការរកមើលកន្លែងផ្សេងទៀត ដើម្បីឲ្យស្គាល់ពីអ្វីដែលព្រះជាម្ចាស់ទាមទារពីពួកគេទេ។ ពួកគេមិនអាចនិយាយថាមិនដឹង ទុកជាការដោះសារក្នុងការដែលមិនកាន់តាមក្រិត្យវិន័យរបស់ព្រះ។ ពួកគេមិនអាចនិយាយថា វាសុទ្ធតែជាអាថ៌កំបាំងបានទេ។ វាត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់វិញ។ ដូច្នេះ “ឆន្ទៈសេរី” មានគ្រប់ទាំងការដោះសាររបស់វាដើម្បីឲ្យគ្រប់ទាំងការមិនស្តាប់បង្គាប់បានរួចខ្លួន។

ខ្ញុំសូមនិយាយម្តងទៀតថា អត្ថបទនេះគ្រាន់តែបង្ហាញយើងពីអ្វីដែលព្រះទាមទារប៉ុណ្ណោះ។ ពួកគេបង្ហាញយើងពីអ្វីដែលយើងគួរធ្វើ ប៉ុន្តែមិនអាចធ្វើបាន។ ក្រិត្យវិន័យទាំងនោះគ្រាន់តែមានបំណងដើម្បីបង្ហាញយើងថា យើងគ្មានអំណាច ហើយពោរពេញដោយតែអំពើបាបប៉ុណ្ណោះ។

## ការវែកញែក ១២ : មនុស្សមិនត្រូវខំបើកចូលទៅក្នុងបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះឡើយ

ឥឡូវនេះយើងមកឯអត្ថបទ "ភស្តុតាង" របស់អ្នកនៅក្នុងគម្ពីរសញ្ញាថ្មី។ អ្នកផ្តល់គម្ពីរម៉ាថាយ ២៣:៣៧ "ឱយេរូសាឡឹម! ក្រុងយេរូសាឡឹមអើយ! ...តើប៉ុន្មានដងទៀតដែលអញចង់ប្រមូលកូនឯងទាំងប៉ុន្មាន?...តែឯងមិនព្រមទេ"។ អ្នកវែកញែកថា ប្រសិនបើអ្វីៗកើតឡើងតាមព្រះហឫទ័យរបស់ព្រះ នោះក្រុងយេរូសាឡឹមអាចនឹងឆ្លើយតបដោយយុត្តិធម៌ថា៖ "ហេតុអ្វីបានទ្រង់ព្រះកន្សែងជាឥតប្រយោជន៍ធ្វើអី?" ប្រសិនបើព្រះអង្គមិនចង់ឲ្យយើងមិនស្តាប់តាមពួកហោរា ហេតុអ្វីបានជាទ្រង់បានចាត់ពួកគេមក? ហេតុអ្វីបានជាទ្រង់ឲ្យយើងទទួលខុសត្រូវ នៅពេលណាព្រះអង្គសំរេចព្រះហឫទ័យនូវអ្វីដែលពួកយើងគួរធ្វើ រួចទៅហើយនោះ។ ប៉ុន្តែដូចជាខ្ញុំបាននិយាយហើយថា មិនត្រូវខំបើកចូលទៅក្នុងបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះឡើយ ដ្បិតសេចក្តីលាក់កំបាំងនោះលើសពីការយល់ដឹងរបស់យើង (១ ធីម៉ូថេ ៦:១៦)។ យើងគួរចំណាយពេលពិចារណាពីព្រះដែលយកកំណើតជាមនុស្ស គឺជាព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ដែលនៅក្នុងទ្រង់ ព្រះបានបង្ហាញយើងយ៉ាងច្បាស់ពីអ្វីដែលយើងគួរដឹង និងមិនគួរដឹង (កូល៉ុស ២:៣)។ វាជាការពិតដែលព្រះមានរូបអង្គជាមនុស្ស បានមានបន្ទូលថា៖ "អញចង់ប្រមូល ...តែឯងមិនព្រមទេ" ។ ព្រះគ្រីស្ទយាងមកធ្វើ, រងទុក្ខ, ផ្តល់ឲ្យមនុស្សទាំងអស់នូវអ្វីដែលចាំចាច់សំរាប់សេចក្តីសង្គ្រោះ។ មនុស្សមួយចំនួន ដែលរឹងចចេសដោយបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះនោះ បានទាត់ទ្រង់ចោល (យ៉ូហាន

១:៥, ១១)។ ព្រះដែលមានរូបអង្គជាមនុស្សដដែលនេះ ទ្រង់ព្រះកន្សែង និងសោកសង្រេងចំពោះសេចក្តីវិនាសនៃពួកទមិឡល្មើស ទោះបីជានៅក្នុងភាពជាព្រះរបស់ទ្រង់ ដែលទ្រង់មានបំណងព្រះហឫទ័យឲ្យពួកគេធ្លាក់នៅក្នុងសេចក្តីវិនាសក៏ដោយ។យើងមិនត្រូវសួររកមូលហេតុនោះទេ ប៉ុន្តែត្រូវឈរនៅក្នុងការគោរពដល់ព្រះវិញ។

ឥឡូវនេះអ្នកខ្លះនឹងនិយាយថា នៅពេលដែលគេដឹកខ្ញុំទៅដល់កាច់ជ្រុងនៃអំណាចគ្រប់គ្រងរបស់ព្រះ ខ្ញុំបានគេចពីបញ្ហានេះ ដោយនិយាយថា មិនត្រូវខំបើកចូលទៅក្នុងបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះឡើយ។ ប៉ុន្តែនេះមិនមែនជាការបង្កើតរបស់ខ្ញុំទេ។ វាគឺជារបៀបដែលសាវក ប៉ុល បានវែកញែកនៅក្នុង ព្រះគម្ពីររ៉ូម ៩:១៩ និង ២១ ហើយនិងនៅក្នុងគម្ពីរអេសាយ មុនគាត់វិញ (អេសាយ ៥៨:២)។ នេះបង្ហាញយ៉ាងច្បាស់ណាស់ថា យើងមិនត្រូវខំបើកចូលទៅក្នុងបំណងព្រះហឫទ័យលាក់កំបាំងរបស់ព្រះឡើយ ជាពិសេសនៅពេលដែលយើងសំគាល់ឃើញថា មនុស្សទមិឡល្មើសត្រូវបានល្បួងឲ្យធ្វើដូច្នេះ។ យើងត្រូវតែទូន្មានពួកគេឲ្យនៅស្ងាត់ស្ងៀម ហើយគោរពកោតខ្លាច។ ប្រសិនបើអ្នកណាម្នាក់ចង់សួរឲ្យដឹងអំពីការនេះ មិនអីទេ តែការនោះនឹងបង្ហាញឲ្យឃើញថា អ្នកនោះកំពុងតែប្រឆាំងនឹងព្រះហើយ។ យើងនឹងចាំមើលថាអ្នកណានឹងឈ្នះ!

## ការ រែក ញែក ១៣ ៖ ក្រឹត្យវិន័យ បង្ហាញ ពី សេចក្ដី កម្សោយ របស់ មនុស្ស និង អំណាចសង្គ្រោះរបស់ព្រះ

បទមួយទៀតដែលអ្នកដកស្រង់ពីព្រះគម្ពីរម៉ាថាយ ១៩:១៧ មកថា៖ “តែបើអ្នកចង់ចូលទៅក្នុងជីវិត ចូរកាន់តាមបញ្ញត្តទាំងប៉ុន្មានចុះ”។ អ្នកបានសួរពីពាក្យថា “តែបើអ្នកចង់” អាចនឹងនិយាយយ៉ាងដូចម្ដេចទៅកាន់អស់អ្នកដែលមានឆន្ទៈមិនមានសេរីភាព។ ប៉ុន្តែនៅក្នុងចំនុចមួយ អ្នកបានឯកភាពថា “ឆន្ទៈសេរី” មិនអាចធ្វើល្អបានទេ ហើយថាបើគ្មានព្រះគុណទេ វាអាចបំរើតែអំពើបាបប៉ុណ្ណោះ។ ឥឡូវតើអ្នកអាចចង់នឹងបង្ហាញថា ឆន្ទៈមានសេរីភាពពេញទីយ៉ាងដូចម្ដេចបាន? តើវាពិតជាត្រឹមត្រូវឬ ដែលរាល់ពេលណាយើងនិយាយថា “តែបើអ្នកចង់” វាមានន័យថា មានសមត្ថភាពធ្វើការនោះ? ឧបមាយើងនិយាយថា ប្រសិនបើអ្នកចង់ប្រៀបធៀបខ្លួនអ្នកជាមួយនឹងស្ដេចដាវីឌ នោះអ្នកត្រូវតែសរសេរបទទំនុកដំកើងដូចជាគាត់ដែរ”។ តើវាមិនមានន័យថា វាមិនអាចទៅរួចសំរាប់យើងទេឬ ប្រសិនបើព្រះមិនជួយយើងនោះ? ដូច្នេះនៅក្នុងបទគម្ពីរ យើងរកឃើញពាក្យពេចន៍នានាដូចនេះ ដើម្បីបង្ហាញយើងពីអ្វីៗដែលអាចធ្វើបានដោយអំណាចព្រះចេស្ដារបស់ព្រះ និងអ្វីៗដែលយើងមិនអាចធ្វើដោយខ្លួនយើងបាន។ ពាក្យពេចន៍ទាំងនេះមិនត្រឹមតែបង្ហាញអ្វីៗដែលយើងមិនអាចធ្វើនៅក្នុងកំលាំងខាងសាច់ឈាមរបស់យើងប៉ុណ្ណោះទេ វាថែមទាំងផ្ដល់សេចក្ដីសន្យានៃពេលមួយដែលការទាំងអស់នេះនឹងត្រូវបានធ្វើដោយអំណាចព្រះចេស្ដារបស់ព្រះទៀតផង។ យើងអាចដាក់អត្ថន័យឲ្យបទគម្ពីរនេះយ៉ាងដូច្នេះថា “ប្រសិនបើអ្នកធ្លាប់មានឆន្ទៈចង់កាន់តាមបញ្ញត្តទាំង

នេះ (ដែលអ្នកនឹងមាន មិនមែនមកពីខ្លួនឯង ប៉ុន្តែមកពីព្រះដែលទ្រង់ប្រទានវាមកអ្នក ព្រោះទ្រង់សព្វព្រះហឫទ័យ) នោះបញ្ញត្តទាំងនោះនឹងការពារអ្នក”។

នៅក្នុងរបៀបនេះយើងអាចឃើញថា យើងមិនអាចធ្វើអ្វីបានទាំងអស់នូវអ្វីដែលព្រះបានបង្គាប់មកទេ ហើយប៉ុន្តែនៅពេលដំណាលគ្នានោះយើងអាចធ្វើបានទាំងអស់ គឺថាភាពកម្សោយជារបស់ពួកយើង រីឯសមត្ថភាពមកដោយសារព្រះគុណនៃព្រះវិញ។

## ការវែកញែក ១៩ : សេចក្ដីបង្រៀននៅក្នុងគម្ពីរសញ្ញាថ្មីត្រូវបានប្រទានមក ដើម្បីនាំផ្លូវដល់អ្នកដែលបានរាប់ជាសុចរិត

អ្នកប្រើការវែកញែកមួយដែលមានមូលដ្ឋានលើខយោងជាច្រើន នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលទាក់ទងនឹងការប្រព្រឹត្តិល្អ និងការប្រព្រឹត្តិអាក្រក់។ ឧ៖ “ចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នាបែបដូច្នោះដែរ (ម៉ាថាយ ៥:១២)។ អ្នកនិយាយថា ប្រសិនបើអ្វីមួយសំរេចបានដោយព្រោះព្រះសព្វព្រះហឫទ័យនឹងវា នោះប្រហែលជាមិនអាចមានការសមទទួលណាមួយនៅក្នុងការប្រព្រឹត្តិល្អឡើយ។ ដូច្នេះ អ្នកចង់ឲ្យអត្ថបទនេះមានន័យថា មនុស្សអាចធ្វើល្អដើម្បីនឹងទទួលបានរង្វាន់នៅឯស្ថានសួគ៌ ដោយមិនបាច់មានជំនួយ។ មែនហើយ “ឆន្ទៈសេរី” បានបង្កើតឲ្យមានជំហានខ្លះ ដូចជាសៀវភៅអ្នកបានសរសេរ

អញ្ជឹង! “ឆន្ទៈសេរី” មិនត្រឹមតែអាចចង់ធ្វើល្អ ហើយអាចធ្វើល្អប៉ុណ្ណោះទេ ប៉ុន្តែអ្នកថែមទាំងចង់ឲ្យវាស័ក្តិសមទទួលជីវិតអស់កល្បជានិច្ចទៀតផង។ ដូច្នេះ តើយើងត្រូវការអ្វីពីព្រះគ្រីស្ទ ឬក៏ព្រះវិញ្ញាណបរិសុទ្ធទៀត?

មនុស្ស “ឆ្លាត” អាចនឹងខ្វាក់ចំពោះអ្វីៗដែលមនុស្សធម្មតា អាច “ឃើញច្បាស់” វិញ។ អ្នកមិនបានយល់ពីភាពខុសគ្នា រវាងគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មីទេ។ នៅក្នុងគម្ពីរសញ្ញាចាស់មានក្រឹត្យវិន័យ និងការគំរាមនានា ដែលព្រះរៀបចំមក ដើម្បីធ្វើឲ្យយើងរត់មកឯសេចក្តីសន្យាដែលឃើញនៅក្នុងគម្ពីរសញ្ញាថ្មី។ យើងអាចរកឃើញព្រះគុណ និងសេចក្តីអត់ទោសបាបដែលព្រះគ្រីស្ទរកបានមកដោយការដែលគេឆ្កាងទ្រង់ នៅក្នុងដំណឹងល្អនៃព្រះគម្ពីរសញ្ញាថ្មី។ បន្ទាប់មកក៏មានការលើកទឹកចិត្ត និងការបង្ហាត់បង្រៀន សំរាប់ជាសេចក្តីដាស់តឿនដល់ពួកអ្នកដែលបានរាប់ជាសុចរិត ជាពួកអ្នកដែលបានទទួលព្រះគុណនិងការសេចក្តីអត់ទោស ឲ្យបានបង្កើតផលផ្លែខាងព្រលឹងវិញ្ញាណ ហើយលីឈើឆ្កាងដោយសេចក្តីក្លាហាន។

អ្នកមើលមិនឃើញពីការងារបង្កើតជាថ្មីរបស់ព្រះវិញ្ញាណបរិសុទ្ធទេ អ្នកមើលឃើញតែក្រិត្យវិន័យនៅក្នុងបទគម្ពីរដែលមនុស្សត្រូវរស់នៅតាមប៉ុណ្ណោះ។ នេះគឺជាការដ៏គួរឲ្យភ្ញាក់ផ្អើលមែនទែន ចំពោះអ្នកដែលបានចំណាយពេលវេលាដ៏ច្រើនក្នុងការសិក្សាព្រះគម្ពីរ។ អត្ថបទនេះ (ម៉ាថាយ ៥:១២) មានការទាក់ទងនឹង “ឆន្ទៈសេរី” ដូចជាពន្លឺមានការទាក់ទងនឹងសេចក្តីងងឹតយ៉ាងដូច្នោះដែរ។ អត្ថបទនេះត្រូវបានរៀបចំឡើង សំរាប់តែជាការលើកទឹកចិត្តដល់ពួកសាវកដែលបាននៅ

“ក្នុងព្រះគុណ” រួចហើយប៉ុណ្ណោះ ដើម្បីឲ្យពួកគេអាចទ្រាំទ្រនឹងសេចក្ដីទុក្ខលំបាកនៃលោកិយនេះ។

## ការវែកញែកទី ១៥ : មូលដ្ឋាននៃការប្រទានរង្វាន់ គឺជាសេចក្ដីសន្យារបស់ព្រះ មិន មែនដោយបុណ្យកុសលរបស់មនុស្សទេ

“រង្វាន់” នៅក្នុងគម្ពីរម៉ាថាយ ៥:១២ គឺជាប្រភេទមួយនៃសេចក្ដីសន្យា។ ប៉ុន្តែសេចក្ដីសន្យាមួយមិនបញ្ជាក់ថា ទាល់តែយើងអាចធ្វើអ្វីមួយនោះទេ។ វាគ្រាន់តែបញ្ជាក់ថា ប្រសិនបើយើងធ្វើការងារជាក់លាក់ណាមួយ នោះយើងនឹងបានរង្វាន់ ប៉ុណ្ណោះ។ ចម្ងល់គឺថា តើយើងអាចធ្វើការងារជាក់លាក់នោះដើម្បីឲ្យបានរង្វាន់ដែរឬទេ។ អ្នកខ្លះនិយាយថា រង្វាន់ត្រូវបានរៀបចំសំរាប់អស់អ្នកណាដែលរត់ ដូច្នេះមនុស្សទាំងអស់អាចរត់ ហើយអាចយករង្វាន់នោះបាន។ តើនោះមិនមែនជាការដឹកួរឲ្យអស់សំណើចទេឬអី? (វាអាចនឹងមានប្រយោជន៍ ប្រសិនបើ “ឆន្ទៈសេរី” ត្រូវបានបង្កើតឡើងដោយការវែកញែកយ៉ាងដូច្នោះ!)

អ្នកព្យាយាមវែកញែកថា ប្រសិនបើព្រះសំរេចព្រះបាទច័យគ្រប់ការទាំងអស់ នោះយើងមិនអាចនិយាយពីរង្វាន់បានទេ។ ប្រសិនបើអ្នកចង់និយាយថា អ្នកនឹងមិនផ្ដល់ “រង្វាន់” ដល់មនុស្សដែលមិនចង់ធ្វើការ នោះខ្ញុំឯកភាព។ ប៉ុន្តែនៅពេលមនុស្សធ្វើល្អ ឬធ្វើអាក្រក់ដោយស្ម័គ្រចិត្តចង់ធ្វើ នោះរង្វាន់ឬក៏ទណ្ឌកម្ម នឹងមកតាមយ៉ាងដូច្នេះដែរ។ ការនេះជាការពិត ទោះបីជាពួកគេមិនអាចផ្លាស់ប្ដូរឆន្ទៈ

របស់ខ្លួន ដោយកំលាំងខ្លួនឯងបាន ក៏ដោយ។ ប៉ុន្តែ ប្រសិនបើយើងអាចចង់ធ្វើល្អ ដោយសារតែព្រះគុណ នោះវាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ភាពសមទទួល និងរង្វាន់ មកតែពីព្រះគុណតែមួយប៉ុណ្ណោះ។

ប៉ុន្តែយើងមិនគួរនិយាយអំពីភាពសមទទួលទេ។ ប៉ុន្តែយើងគួរនិយាយអំពីលទ្ធផលនៃអ្វីដែលយើងធ្វើវិញ។ គ្មានការល្អឬអាក្រក់ណា ដែលគ្មានរង្វាន់របស់ខ្លួននោះទេ។ ជាការពិតណាស់ ស្ថាននរក និងការជំនុំជំរះនៃព្រះ កំពុងតែរង់ចាំមនុស្សអាក្រក់ ដូចគ្នានឹងនគរស្ថានសួគ៌ ដែលកំពុងតែរង់ចាំដល់ពួកអ្នកដែលកោតខ្លាចព្រះយ៉ាងដូច្នោះដែរ ពីព្រោះនោះជាកន្លែងដែលព្រះវរបិតារបស់ពួកគេបានរៀបចំទុកឲ្យ (ម៉ាថាយ ២៥:៣៤)។ ប្រសិនបើយើងព្យាយាមធ្វើល្អដើម្បីឲ្យទទួលបាននគររបស់ព្រះ នោះយើងនឹងបរាជ័យ ហើយនោះសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា យើងជាមនុស្សទមិឡល្មើស។ កូនរបស់ព្រះធ្វើល្អមិនដើម្បីស្វែងរករង្វាន់នោះទេ តែស្វែងរកសិរីល្អរបស់ព្រះវិញ។

អញ្ចឹង តើអ្វីទៅជាអត្ថន័យនៃបទគម្ពីរដែលសន្យាពីនគរស្ថានសួគ៌ និងបទគម្ពីរដែលគំរាមពីស្ថាននរក? (លោក ១៥:១; ២របា ១៥:៧; យ៉ូប ៣៤:១១; រ៉ូម ២:៧)។ បទគម្ពីរទាំងនេះគ្រាន់តែបង្ហាញពីលទ្ធផលនៃជីវិតល្អ ឬជីវិតអាក្រក់ប៉ុណ្ណោះ។ បទគម្ពីរទាំងនេះត្រូវបានរៀបចំមកដើម្បីបង្ហាត់បង្រៀន និងដើម្បីដាស់តឿន។ បទគម្ពីរទាំងនេះមិនបាននិយាយពីការសមទទួល ប៉ុន្តែបង្រៀនយើងពីអ្វីដែលយើងគួរធ្វើ និងលើកទឹកចិត្តយើងឲ្យបានខ្ជាប់ខ្ជួនដល់ទីបំផុតវិញ (លោក ១៥:១; ១កូរិន ១៥:៥៨; ១៦:១៣)។ វាប្រៀបដូចជា យើងត្រូវកំសាន្តចិត្តនរណា

ម្នាក់ ដោយនិយាយថា គាត់បានគាប់គួរចំពោះព្រះហើយ ឬព្រមានដល់គាត់ថា អ្វីដែលគាត់ធ្វើនោះមិនគាប់គួរនៅចំពោះព្រះទេ។

ប៉ុន្តែអ្នកបានវែកញែកថា “ហេតុអ្វីបានជាព្រះអំពល់មានបន្ទូលប្រាប់យើងពីការទាំងនេះទៀត បើការទាំងនេះត្រូវបានរៀបចំជាមុនហើយនោះ? ចម្លើយគឺថា ព្រះបង្កើតគោលបំណងរបស់ទ្រង់នៅក្នុងយើង តាមរយៈព្រះបន្ទូលរបស់ទ្រង់។ ទ្រង់អាចនឹងធ្វើការនេះដោយគ្មានព្រះបន្ទូលនោះក៏បានដែរ ប៉ុន្តែទ្រង់សព្វព្រះហឫទ័យឲ្យយើងដែលជាបាវបំរើបានរួមមកជាមួយទ្រង់។ ដូច្នេះ ទ្រង់មានបន្ទូលប្រាប់យើងពីការទាំងនេះ ជាព្រះបន្ទូលដើម្បីទំនាក់ទំនងមកឯយើង។ ដូច្នេះយើងឃើញថា ព្រះសំដែងពីបំណងព្រះហឫទ័យរបស់ទ្រង់មកនៅក្នុងយើង ប៉ុន្តែទ្រង់ក៏បានប្រទានព្រះបន្ទូលទ្រង់ទៅដល់លោកិយទាំងមូលដើម្បីប្រាប់ពីសេចក្តីពិតអំពីរង្វាន់ និងទណ្ឌកម្មដែរ យ៉ាងនោះព្រះចេស្តា និងសិរីល្អរបស់ទ្រង់ ហើយនិងសេចក្តីកម្សោយ និងសេចក្តីអាក្រក់ នឹងបានប្រកាសដល់លោកិយទាំងមូល។ ប៉ុន្តែសេចក្តីពិតទាំងនេះ ដែលជាសេចក្តីពិតដែលអ្នកឯទៃទៀតមិនចូលចិត្ត នឹងត្រូវបានទទួលដោយពួកកោតខ្លាចព្រះនៅក្នុងចិត្តវិញ។

## ការវែកញែកទី ១៦ : អំណាចគ្រប់គ្រងរបស់ព្រះមិនបំផ្លាញទំនួលខុសត្រូវរបស់យើងទេ

អ្នកវែកញែកពីឃ្លាថា “អ្នករាល់គ្នានឹងស្គាល់គេបាន ដោយសារផលគេបង្កើត”

(ម៉ាថាយ ៧:១៦) ថា ជាផលផ្លែនោះនិយាយសំដៅទៅផលផ្លែរបស់យើង ហើយដូច្នេះ វាមិនអាចជាអ្វីដែលព្រះប្រទានមកយើង ដោយព្រះវិញ្ញាណរបស់ទ្រង់នោះទេ។ នេះគឺជាការវែកញែកដ៏ល្ងីល្ងើបំផុត! គេនិយាយថា ទោះជាយើងបានទទួលព្រះគ្រីស្ទក៏ដោយ តែទ្រង់ជារបស់យើងរួចទៅហើយ។ ភ្នែករបស់យើងជារបស់យើង ទោះជាយើងមិនបានបង្កើតវាក៏ដោយ! បន្ទាប់មកអ្នកប្រើការវែកញែកមួយទៀតពីគម្ពីរលូកា ២៣:៣៤ "ឱព្រះវរបិតាអើយ! សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ"។ អ្នកនិយាយថា បើឆន្ទៈរបស់យើងមិនមានសេរីភាពទេ នោះប្រហែលជាការល្អជាងដែលព្រះគ្រីស្ទត្រូវអត់ទោសដល់អ្នកសម្លាប់ទ្រង់ ពីព្រោះពួកគេមិនមាន "ឆន្ទៈសេរី" ហើយមិនអាចធ្វើអ្វីផ្សេងពីហ្នឹងបាន។ ប៉ុន្តែចម្លើយនៅក្នុងព្រះបន្ទូលផ្ទាល់របស់ព្រះអម្ចាស់យើងគឺ៖ "គេមិនដឹងជាគេធ្វើអ្វីទេ"។ តើវាអាចមានន័យថា ព្រះគ្រីស្ទកំពុងតែមានបន្ទូលថា ពួកគេមិនអាចចង់ធ្វើអ្វីដែលល្អបានឬ? តើពួកគេចង់ធ្វើអ្វីដែលពួកគេមិនដឹងឬ? គ្មានពាក្យសំដីដ៏ខ្លាំងណាដែលកើតចេញពីភាពកម្សោយនៃឆន្ទៈនោះបានឡើយ។ ឆន្ទៈមិនត្រឹមតែមិនអាចធ្វើល្អប៉ុណ្ណោះទេ សូម្បីតែការអាក្រក់ដែលវាកំពុងតែធ្វើច្រើនប៉ុណ្ណា ឬអ្វីដែលជាការល្អ ក៏វាមិនដឹងផង!

បន្ទាប់មកជាថ្មីម្តងទៀត អ្នកបានប្រើគម្ពីរយ៉ូហាន ១:១២ "ប៉ុន្តែ អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ"។ អ្នកវែកញែកថា "តើព្រះប្រទានអំណាចដល់ពួកគេ ឲ្យបានត្រឡប់ជាកូនព្រះដោយរបៀបណា ប្រសិនបើគ្មានសេរីភាពនៃឆន្ទៈ

ផងនោះ?” ប៉ុន្តែសូមមើលដោយប្រុងប្រយ័ត្ននៅខនេះ។ សាវក យ៉ូហាន និយាយពីការផ្លាស់ប្តូរទាំងស្រុងពីភាពជាកូនអារក្សសាតាំងមកភាពជាកូនរបស់ព្រះវិញ។ មនុស្សមិនបានធ្វើអ្វីទាំងអស់ ប៉ុន្តែបានក្លាយជាអ្វីម្យ៉ាងទៅវិញ! យើងក្លាយជាកូនរបស់ព្រះដោយកិច្ចការនៃព្រះ មិនមែនដោយកិច្ចការណាមួយនៃ “ឆន្ទៈសេរី” ដែលនៅក្នុងយើងនោះទេ។ សាវក យ៉ូហាន កំពុងតែប្រាប់យើងថា ដំណឹងល្អនៃព្រះគុណដែលមិនតំរូវឲ្យមនុស្សធ្វើនោះ បង្កើតនូវឱកាសដ៏អស្ចារ្យនៃការត្រឡប់ជាកូនព្រះដល់មនុស្សទាំងអស់ ប្រសិនបើពួកគេជឿ។ ប៉ុន្តែឆន្ទៈ និងជំនឿនេះ គឺជាធាតុសំខាន់ដែលពួកគេមិនស្គាល់ពីមុនមក។ យ៉ាងនោះវាមិនអាចទៅរួចទេ ដែលពួកគេអាចធ្វើការទាំងនេះដោយកំលាំងខ្លួនឯងនោះ។ មនុស្សមិនអាចគិតដោយប្រុងប្រយ័ត្នសំរាប់ខ្លួនឯង ពីដំណឹងល្អដែលទាក់ទងនឹងសេចក្តីជំនឿ អំពីព្រះគ្រីស្ទជាព្រះរាជបុត្រានៃព្រះផងនិងជាកូនមនុស្សផងឡើយ។ តើពួកគេអាចនឹងមានចិត្តចង់ទទួលដំណឹងល្អនោះដោយរបៀបណា? សាវក យ៉ូហាន មិនកំពុងតែប្រកាសពីគុណតំលៃរបស់ “ឆន្ទៈសេរី”ទេ ប៉ុន្តែគាត់កំពុងតែនិយាយពីគុណតំលៃនៃនគរព្រះដែលត្រូវបានធ្វើឲ្យមនុស្សក្នុងលោកិយទាំងមូលបានស្គាល់ នៅក្នុងដំណឹងល្អវិញ។ សាវក យ៉ូហាន ក៏បង្ហាញផងដែរថា មានមនុស្សតិចតួចណាស់ដែលទទួលដំណឹងល្អ នោះគឺដោយព្រោះថា “ឆន្ទៈសេរី” ប្រឆាំងនឹងដំណឹងល្អ។ អំណាចនៃ “ឆន្ទៈសេរី” គឺយ៉ាងនេះ៖ សាតាំងគ្រប់គ្រងលើវា អញ្ចឹងហើយបានជាវាបដិសេធព្រះគុណរបស់ព្រះ។ វាក៏បដិសេធព្រះវិញ្ញាណដែលសំរេចក្រឹត្យវិន័យនៅក្នុងយើងផងដែរ ពីព្រោះ “ឆន្ទៈសេរី” គិតថា វាអាចស្តាប់បង្គាប់តាមក្រឹត្យវិន័យដោយការប្រឹងប្រែងរបស់វាបាន។

បន្ទាប់មកអ្នកក៏បន្តឯកស្រេង់សំដីសាវក ប៉ុល មកគាំទ្រករណីរបស់អ្នក។ (តាមពិតទៅ សាវក ប៉ុល គឺជាសត្រូវដ៏ធំនៃ "ឆន្ទៈសេរី"!) អ្នកអាចប្រើគម្ពីររ៉ូម ២:៤ "ឬអ្នកមើលងាយសេចក្តីសប្បុរសដ៏ឥតគណនាព្រមទាំងសេចក្តីទ្រាំទ្រ និង សេចក្តីអត់ធន់របស់ទ្រង់ដោយមិនដឹងថា សេចក្តីសប្បុរសនៃព្រះទាញនាំឲ្យអ្នក បានប្រែចិត្តឬអី"។ អ្នកសួរថា៖ "តើពួកអ្នកដែលគ្មាន "ឆន្ទៈសេរី" អាចនឹងមាន ទោសក្នុងការមើលងាយចំពោះសេចក្តីនៃព្រះដោយរបៀបណា? បើព្រះជាចៅក្រម ដែលជំរុញឲ្យធ្វើការអាក្រក់ តើទ្រង់អាចនឹងជំនុំជំរះដោយរបៀបណា? តើអ្នកមិន អាចឃើញពីការព្រមាននៅក្នុងគម្ពីររ៉ូម ២:៤ ទេឬអី? ខនេះត្រូវបានរៀបចំឡើង ដើម្បីឲ្យមនុស្សទមិឡល្មើស បានឃើញថាពួកគេពុំមានអំណាចអ្វីទាំងអស់។ ព្រះ បានរៀបចំមនុស្សដែលទ្រង់បានបន្ទាបចុះទាំងនេះ ឲ្យបានទទួលនូវព្រះគុណរបស់ ទ្រង់។

# ជំពូក ៣

## អ្វីដែលលោក លូសើរ បានគិតពីការបង្រៀនរបស់ អេរ៉ាស្មឹស

*ការវែកញែកទី ១ : វិធីសាស្ត្ររបស់ អេរ៉ាស្មឹស*

*ការវែកញែកទី ២ : ការបំប្លែងអត្ថបទ របស់ អេរ៉ាស្មឹស*

*ការវែកញែកទី ៣ : "ការពន្យល់" អំពី ការធ្វើឲ្យមានភាពរឹងរូសដល់ ចិត្តរបស់ស្ដេចផារ៉ោន របស់ អេរ៉ាស្មឹស*

*ការវែកញែកទី ៤ : ការប្រើប្រាស់និស្ស័យជាមនុស្ស របស់ព្រះ*

*ការវែកញែកទី ៥ : វិធីសាស្ត្រនៃការធ្វើឲ្យមនុស្សរឹងរូស របស់ព្រះ*

*ការវែកញែកទី ៦ : ការធ្វើឲ្យមានភាពរឹងរូសរបស់ព្រះ ដល់ ចិត្តរបស់ស្ដេចផារ៉ោន*

*ការវែកញែកទី ៧ : ការនិយាយអំពីគម្ពីររ៉ូម ៩:១៥-៣៣ របស់ អេរ៉ាស្មឹស*

*ការវែកញែកទី ៨ : ហេតុផលនៃធម្មជាតិ ត្រូវតែយល់ទទួលស្គាល់អំណាច គ្រប់គ្រងនៃបំណងព្រះហឫទ័យរបស់ព្រះ*

*ការរែកញែកទី ៩ : គម្ពីររ៉ូម ៩:១៥-៣៣ (បន្ត)*

*ការរែកញែកទី ១០ : អំណាចគ្រប់គ្រងរបស់ព្រះ និង "ឆន្ទៈសេរី" មិនអាចរស់នៅជាមួយគ្នាបានទេ។*

*ការរែកញែកទី ១១ : ការបកស្រាយអំពីព្រះគម្ពីរម៉ាឡាគី១:២-៣របស់ អ៊ែរ៉ាស្មឹស*

*ការរែកញែកទី ១២ : ជាងស្មូន និងដីឥដ្ឋ*

*ការរែកញែកទី ១៣ : សេចក្តីសុចរិតរបស់ព្រះ*

*ការរែកញែកទី ១៤ : សាវក ប៉ុល ទទួលស្គាល់ថា សេចក្តីសង្គ្រោះនៃមនុស្ស គឺដោយសារព្រះតែមួយប៉ុណ្ណោះ*

## ការវែកញែកទី ១ : វិធីសាស្ត្ររបស់ អែរ៉ាស្មឹស

អ្នកព្យាយាមបំភ័យគូរបដិបក្ខរបស់អ្នក ដោយប្រមូលអត្ថបទជាច្រើនមកគាំទ្រ "ឆន្ទៈសេរី"។ បន្ទាប់មកអ្នកព្យាយាមធ្វើឲ្យគេអស់សំណើចចំពោះយើង ដោយការលើកឡើងថា យើងមានអត្ថបទនៅក្នុងដៃតែពីរប៉ុណ្ណោះគឺ និក្ខមនំ ៩:១២ និង ម៉ាឡាគី ១:២-៣។ អ្នកហាក់ដូចជាមិនចាប់អារម្មណ៍ចំពោះដំណោះស្រាយរបស់សាវក ប៉ុល នៃអត្ថបទទាំងនេះ នៅក្នុងគម្ពីររ៉ូម ៩ ទាល់តែសោះ!

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំនឹងលើកអត្ថបទទាំងពីរនេះឡើង ហើយបង្ហាញពីជំហរដ៏រឹងមាំរបស់យើង។

## ការវែកញែកទី ២ : ការបំប្លែងអត្ថបទ របស់ អែរ៉ាស្មឹស

អ្នកបានបង្កើតរបៀបថ្មីមួយក្នុងការបំបាត់អត្ថន័យនៃអត្ថបទ។ អ្នកទទូចថា អត្ថបទដែលប្រឆាំងនឹង "ឆន្ទៈសេរី" ទាំងនោះ ត្រូវតែមាន "ការពន្យល់" មួយដែលចេញពីអត្ថន័យពិតប្រាកដរបស់អត្ថបទទាំងនោះ។ យើងត្រូវតែទាមការពន្យល់នេះថា វាចាំបាច់នៅតែពេលណាដែលវាគួរឲ្យអស់សំណើច ដើម្បីរក្សាន័យដ៏ងាយស្តាប់នៃអត្ថបទប៉ុណ្ណោះ។ គ្រប់កន្លែងផ្សេងទៀត យើងគួរផ្តោតទៅលើអត្ថន័យធម្មតានៃពាក្យពេចន៍ទាំងនោះ ដោយពិនិត្យលើទំរង់វេយ្យាករណ៍ និងទម្លាប់នៃការនិយាយដែលព្រះបង្កើតមកក្នុងចំណោមមនុស្ស។ ប្រសិនបើយើងមិនធ្វើដូច្នោះទេ នោះនឹងគ្មានអ្វីដែលយើងអាចប្រាកដប្រជានៅកន្លែងណាមួយបានឡើយ។ វាមិនគ្រប់

គ្រាន់ទេ ដែលគ្រាន់តែប្រកាសថា ត្រូវការ “ការពន្យល់” មួយ ជាចាំបាច់នោះ។ ក្នុងករណីណាក៏ដោយ យើងត្រូវសួរថាតើ វាចាំបាច់ត្រូវតែឲ្យមាន “ការពន្យល់” មួយឬក៏អត់។ ប្រសិនបើយើងមិនអាចបង្ហាញថា វាពិតជាចាំបាច់ នោះយើងមិនទទួលបានអ្វីទាំងអស់។ ឧទាហរណ៍មួយនៃការពន្យល់របស់អ្នក គឺការបកស្រាយគម្ពីរនិក្ខមនំ ៩:២១ “អញនឹងធ្វើឲ្យផារ៉ោនមានចិត្តរឹងទទឹង”។ អ្នកនិយាយថា វាគួរតែមានន័យ “អញនឹងអនុញ្ញាតឲ្យវាទៅជារឹងទទឹង” ពីព្រោះជួនកាលយើងនិយាយអ្វីមួយដូចជា៖ “អញបានបំផ្លាញឯង” វាមានន័យថា “អញមិនបានកែតម្រង់ឯងទេ នៅពេលដែលឯងធ្វើខុស”។ ប៉ុន្តែអត្ថន័យនៃពាក្យទាំងនោះ គឺច្បាស់លាស់ស្រួលយល់ហើយ។ ឃ្លានេះមិនត្រូវការការពន្យល់ទេ។ ព្រះបន្ទូលរបស់ព្រះគួរត្រូវបានគេយកចិត្តទុកដាក់នឹងអត្ថន័យដ៏ងាយយល់របស់វា។ យើងមិនត្រូវសរសេរព្រះបន្ទូលរបស់ព្រះជាថ្មីម្តងទៀតតាមតែចិត្តយើងចង់នោះទេ។ យើងប្រហែលជាអាចនឹង “ពន្យល់” នៃឃ្លា “ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី” ឲ្យមានន័យថា “ទ្រង់បានបង្កើតពួកវាមែន ប៉ុន្តែទ្រង់មិនបានបង្កើតពួកវាចេញពីគ្មានអ្វីសោះនោះទេ!”។ បើធ្វើយ៉ាងនោះ មានន័យថា អ្នកណាក៏ដោយនៅក្នុងលោកនេះ សុទ្ធតែជាអ្នកសិក្សាព្រះគម្ពីរទាំងអស់ ឲ្យតែអ្នកនោះបើកព្រះគម្ពីររបស់ខ្លួន!

## ការកែកញ្ចែកទី ៣ : "ការពន្យល់" អំពីការធ្វើឲ្យមានភាពរឹងរូសដល់ចិត្តរបស់ស្ដេចផារ៉ោន របស់ អែរ៉ាស្មីស

អ្នកបកស្រាយឃ្លា "អញនឹងធ្វើឲ្យផារ៉ោនមានចិត្តរឹង" ថា "ការអត់ធ្មត់ដែលអញស៊ូទ្រាំនឹងមនុស្សមានបាប ហើយនាំឲ្យអ្នកដទៃបានមកឯការប្រែចិត្ត ទើបទ្រង់ធ្វើឲ្យស្ដេចផារ៉ោនកាន់តែរឹងរូសក្នុងសេចក្ដីអាក្រក់"។ អ្នកបានបកស្រាយគម្ពីររ៉ូម ៩:១៨ និងគម្ពីរអេសាយ ៦៣:១៧ តាមរបៀបដដែលនេះ។ មានតែពាក្យសំដីរបស់អ្នកប៉ុណ្ណោះ ដែលថាការទាំងនេះ ជាការពន្យល់ដ៏ត្រឹមត្រូវ។ ជាការពិត អ្នកបានដកស្រង់ពីលោក អ័រិជិន និងលោកចៀរ៉ូម ប៉ុន្តែតើអ្នកណាមួយដែលធ្វើឲ្យខ្ញុំជឿជាក់ថា ពួកគេពិតជាត្រឹមត្រូវបាន?

និយាយឲ្យខ្លីទៅ លទ្ធផលនៃ "ការពន្យល់" របស់អ្នក ធ្វើឲ្យអត្ថន័យនៃអត្ថបទទាំងនេះ ក្លាយជាផ្ទារជើងឡើងលើតែប៉ុណ្ណោះ។ ព្រះមានបន្ទូលថា "អញនឹងធ្វើឲ្យផារ៉ោនមានចិត្តរឹង"។ អ្នកបែរជាធ្វើឲ្យព្រះជាម្ចាស់មានបន្ទូលថា "ស្ដេចផារ៉ោននឹងធ្វើឲ្យចិត្តខ្លួនឯងរឹង"។ អ្នកបែរជាគិតបញ្ជើភាពរឹងចចេសរបស់ស្ដេចផារ៉ោនពីមេត្តាករុណារបស់ព្រះទៅវិញ។ ប្រសិនបើអ្នកនៅតែបន្តធ្វើអញ្ចឹងទៀត អ្នកនឹងធ្វើឲ្យសេចក្ដីមេត្តាករុណារបស់ព្រះត្រឡប់ជាសេចក្ដីក្រោធ ហើយធ្វើឲ្យសេចក្ដីក្រោធទៅជាសេចក្ដីមេត្តាករុណាហើយ។ ជាការពិតណាស់ អ្នកដឹងថា សេចក្ដីមេត្តាករុណារបស់ព្រះ អាចនាំឲ្យមនុស្សខ្លះក្លាយជាមានចិត្តរឹងចចេស ប៉ុន្តែសេចក្ដីក្រោធរបស់ទ្រង់ក៏អាចធ្វើយ៉ាងដូច្នេះបានដែរ។ យើងដឹងថា សេចក្ដីមេត្តាករុណារបស់ព្រះនឹងធ្វើឲ្យចិត្តខ្លះត្រឡប់ជាទន់ ប៉ុន្តែសេចក្ដីក្រោធរបស់ទ្រង់ក៏នឹង

ធ្វើយ៉ាងដូច្នេះដែរ។ ប៉ុន្តែ មិនមានការដោះសាណាមួយសំរាប់ការភាន់ច្រឡំចំពោះសេចក្តីមេត្តាករុណារបស់ព្រះ និងសេចក្តីក្រោធរបស់ព្រះបានឡើយ។ ព្រះបានមានបន្ទូលថា ទ្រង់នឹងធ្វើឲ្យចិត្តរបស់ផារ៉ោនទៅជារឹង ហើយព្រះបានធ្វើឲ្យគាត់មានបញ្ហា ហើយដាក់ទោសគាត់ដោយគ្រោះកាចទាំងដប់។ ប៉ុន្តែអ្នកបែរជាធ្វើឲ្យគ្រោះកាចទាំងនេះដើរតួជាសេចក្តីមេត្តាករុណារបស់ព្រះទៅវិញ! នេះពិតជាគំនិតដែលហួសហេតុមែន! សេចក្តីមេត្តាករុណារបស់ព្រះក៏មានសកម្មភាព នៅពេលណាទ្រង់ពន្យារគ្រោះកាចទាំងនោះម្តងហើយម្តងទៀត នៅពេលដែលស្តេចផារ៉ោនហាក់ដូចជាប្រែចិត្ត ប៉ុន្តែគ្រោះកាចទាំងនោះ គឺជាមធ្យោបាយដែលទ្រង់បានប្រើដើម្បីដាក់ទណ្ឌកម្មស្តេចផារ៉ោន និងដើម្បីធ្វើឲ្យចិត្តរបស់គាត់រឹងចចេសវិញ។

ចូរយើងឧបមាថា ព្រះធ្វើឲ្យចិត្តមនុស្សរឹងចចេស នៅពេលដែលទ្រង់ប្រើសេចក្តីអត់ធ្មត់របស់ទ្រង់ ដោយការខំទប់មិនឲ្យមានការដាក់ទណ្ឌកម្មភ្លាមៗ។ ចិត្តមនុស្សនឹងនៅតែមិនទន់ដែរ លុះត្រាតែដោយព្រះវិញ្ញាណរបស់ព្រះបានបន្ទន់។ ដូច្នេះ ទោះជាប្រើដំណើរការណាក៏ដោយ ចិត្តមនុស្សរឹងចចេសចំពោះព្រះហឫទ័យនៃព្រះ ហើយបានត្រឡប់ជាទន់វិញដោយសារការបង្គាប់នៃបំណងព្រះហឫទ័យដដែលនោះ។

អ្នកនិយាយថា “ដោយព្រះអាទិត្យដដែលនោះ ភក់ត្រឡប់ជារឹង ហើយទៀនបានរលាយ។ ដូចជាបន្ទាប់ពីភ្លៀងដដែលនោះ ដីដែលបានភ្ជួររាស់បានបង្កើតផលផ្លែ ហើយដីដែលមិនបានភ្ជួររាស់វិញដុះសុទ្ធតែបន្លា។ នោះដូចគ្នាដែរ គឺដោយសេចក្តីអត់ធ្មត់របស់ព្រះ មនុស្សខ្លះមានចិត្តរឹងចចេស ហើយអ្នក

ខ្លះបានផ្លាស់ប្រែវិញ”។ ប៉ុន្តែការនេះពុំមានជំនួយណាមួយជួយដល់អ្នកសោះ។ អ្នកនៅតែនិយាយថា មនុស្សទាំងអស់ដូចគ្នាដដែល គឺថា មនុស្សទាំងអស់មាន “ឆន្ទៈសេរី”។ ប៉ុន្តែ វាជាការជ្រើសរើសរបស់ព្រះវិញ ដែលការជ្រើសរើសនោះ ធ្វើឲ្យមានការបែងចែករវាងមនុស្ស។ បើគ្មានការជ្រើសរើសនេះទេ មនុស្សទាំង អស់ មានសេរីភាពដើម្បីតែ មិនស្តាប់បង្គាប់ព្រះប៉ុណ្ណោះ។ ប៉ុន្តែ អ្នកនិយាយថា គ្មានការជ្រើសរើស។ លទ្ធផលគឺថា អ្នកត្រូវបានទុកចោលជាមួយនឹងព្រះដ៏ជួយ មិនបាន ហើយមនុស្សប្រុសនិងមនុស្សស្រីត្រូវបានផ្តន្ទាទោស ឬបានសង្គ្រោះ ដោយព្រោះព្រះមិនស្គាល់។ ទ្រង់គ្រាន់តែដាក់សេចក្តីល្អរបស់ទ្រង់នៅចំពោះមុខ ពួកគេតែប៉ុណ្ណោះ។ បន្ទាប់មកទ្រង់មិនអាចធ្វើអ្វីទៀតបាន ប្រហែលជាទ្រង់យាង ទៅពិធីជប់លៀងវិញ។ នេះគឺជាការដ៏ប្រសើរបំផុតដែលហេតុផលមនុស្សអាចធ្វើ បាន។ ប៉ុន្តែ អ្នកយល់ច្រឡំពីប្រធានបទ ដោយការបង្កើតឲ្យ “ឆន្ទៈសេរី” ពីរ គឺ ទៀន និងដីឥដ្ឋ, ដីដែលបានភ្ជួររាស់ និងដីដែលមិនបានភ្ជួររាស់។ ការបង្ហាញទាំង នេះ មិនមែនជាការប្រើប្រាស់ពិតប្រាកដចំពោះអ្នកនោះទេ។ ការបង្ហាញទាំងនេះ សមហេតុផល ប្រសិនបើ យើងហៅដំណឹងល្អថា ភ្លៀងនិងព្រះអាទិត្យ ហើយ ហៅដីឥដ្ឋ និងដីដែលមិនបានភ្ជួររាស់ថា ជាពួកមិនត្រូវបានរើសតាំង ហើយហៅ ទៀន និងដីដែលបានភ្ជួររាស់ ថាជា ពួករើសតាំង។ ពួកអ្នកដែលព្រះមិនបានរើស តាំង ត្រូវបានធ្វើឲ្យកាន់តែអាក្រក់ទៅ ដោយសារដំណឹងល្អ។ រីឯពួករើសតាំង ត្រូវបានធ្វើឲ្យកាន់តែល្អប្រសើរឡើង ដោយដំណឹងល្អវិញ។

អ្នកបានបង្កើត “ការពន្យល់”នេះថា ស្តេចផារ៉ោនធ្វើឲ្យចិត្តខ្លួនឯងរឹង

ចចេស នៅចំពោះសេចក្តីល្អរបស់ព្រះ ពីព្រោះអ្នកនិយាយថា ព្រះទ្រង់ល្អហើយទ្រង់បានសំរេចការនេះ គឺជាគំនិតដ៏ល្ងីល្ងើ។ តើអ្នកណានិយាយថា នោះជាគំនិតល្ងីល្ងើ? មានតែហេតុផលមនុស្សប៉ុណ្ណោះដែលគិតថាការនេះមិនត្រឹមត្រូវ។ តើយើងត្រូវវិនិច្ឆ័យកិច្ចការរបស់ព្រះដោយហេតុផលដ៏ងងឹតងងល់ ថ្លង់ មិនស្គាល់ព្រះរបស់មនុស្សឬ? លើមូលដ្ឋានទាំងនេះ ជំនឿគ្រីស្ទានទាំងមូល នឹងទៅជាសេចក្តីល្ងីល្ងើ។ ដូចជាសាវក ប៉ុល និយាយនៅក្នុង ១កូរិនថូស ១:២៣ ថា វាជាសេចក្តីល្ងីល្ងើដល់សាសន៍ក្រិក ហើយជាថ្មជំពប់ដល់សាសន៍យូដា ដែលថា ព្រះគួរជាមនុស្ស កូនរបស់ស្ត្រីព្រហ្មចារីម្នាក់ ហើយទ្រង់ត្រូវបានគេឆ្កាង ហើយកំពុងគង់ខាងស្តាំព្រះវរបិតា។ ដោយហេតុផលរបស់មនុស្ស វាជាសេចក្តីល្ងីល្ងើក្នុងការដែលយើងជឿលើការទាំងអស់នេះ។

ប៉ុន្តែរាល់ករណីទាំងអស់ អ្នកមិនបានបញ្ជាក់បញ្ហាដោយការនិយាយថា មនុស្សត្រូវទទួលខុសត្រូវចំពោះការដែលធ្វើឲ្យចិត្តខ្លួនឯងរឹងរូស នោះឡើយ។ អ្នកនៅតែពន្យល់ពីរបៀបដែលព្រះអាចទាមទារ “ឆន្ទៈសេរី” ឲ្យធ្វើការដែលមិនអាចទៅរួចទាំងនោះ ដដែល។ ទោះបីជា “ឆន្ទៈសេរី” មិនអាចធ្វើអ្វីផ្សេងទៀតក៏ដោយ ប៉ុន្តែ តើព្រះចោទ “ឆន្ទៈសេរី” ដោយព្រោះអំពើបាបដោយរបៀបណា? អ្នកកំពុងតែស្មើហេតុផល។ ការទាំងនេះ ជាសេចក្តីល្ងីល្ងើ ដូចហេតុផលរបស់មនុស្សដែរ។

ការពិតនៅតែដដែលថា ការប្រើប្រាស់ “ឆន្ទៈសេរី” នៅក្នុងលោកិយនេះ មិនដែលអាចបញ្ឈប់ចិត្តរឹងរូសរបស់មនុស្សបានទេ ប្រសិនបើគ្មានប្រតិបត្តិការ

របស់ព្រះវិញ្ញាណបរិសុទ្ធនោះ។

អ្នកបាននិយាយថា ព្រះមិនអាចធ្វើឲ្យស្តេចផារ៉ោនក្លាយទៅជាអញ្ចឹងទេ ពីព្រោះទ្រង់បានទតឃើញថា អ្វីដែលទ្រង់បានបង្កើតសុទ្ធតែល្អ។ ប៉ុន្តែ ជាការពិតណាស់ នោះជាព្រះបន្ទូលមួយចំពោះសណ្ឋានដើមដំបូងនៃការបង្កើតរបស់ព្រះ មុនពេលធ្លាក់ក្នុងអំពើបាបប៉ុណ្ណោះ។ តាំងពីហ្នឹងមក មនុស្សយើងទាំងអស់ រួមទាំងស្តេចផារ៉ោនដែរនោះ បានកើតចេញពីសាសន៍ដ៏ទមិឡល្មើស និងពុករលួយមួយ។ ទោះបីជាព្រះបន្ទូលត្រង់នេះ សំដៅទៅកិច្ចការរបស់ព្រះក្រោយការធ្លាក់ក្នុងអំពើបាបក៏ដោយ ក៏ព្រះបន្ទូលត្រង់នេះសំដៅពីរបៀបដែលទតមើលអ្វីៗដែរ មិនមែនសំដៅពីរបៀបដែលមនុស្សមើលអ្វីៗនោះឡើយ។ មានការល្អជាច្រើននៅក្នុងព្រះនេត្ររបស់ព្រះ ដែលជាការអាក្រក់នៅក្នុងភ្នែករបស់យើង។ ឧទាហរណ៏៖ ជំងឺ ឈឺ ចាប់, សេចក្តីទុក្ខ ព្រួយ, កំហុស, ស្ថាននរក និង ការ ដ៏ប្រសើរទាំងអស់របស់ព្រះ សុទ្ធតែអាក្រក់នៅក្នុងភ្នែករបស់លោកិយ។ ដំណឹងល្អគឺល្អប្រសើរជាងគេទាំងអស់ ប៉ុន្តែ លោកិយនៅតែស្អប់។

## ការវែកញែកទី ៩ : ការប្រើប្រាស់និស្ស័យមនុស្ស របស់ព្រះ

មនុស្សមួយចំនួន អាចនឹងចង់ដឹងពីរបៀបដែលព្រះធ្វើឲ្យការអាក្រក់កើតឡើងនៅក្នុងយើង ការធ្វើឲ្យយើងមានចិត្តរឹងរូស ការបណ្តោយឲ្យយើងធ្លាក់ក្នុងសេចក្តីប៉ងប្រាថ្នារបស់យើង ហើយនិងការបណ្តាលឲ្យយើងដើរផ្លូវខុស។ យើងគួរតែស្តាប់

ចិត្តនឹងអ្វីដែលព្រះគម្ពីរប្រាប់យើង។

ចម្លើយរបស់ខ្ញុំគឺថា ក្រៅពីព្រះគុណរើសតាំង ព្រះពាក់ព័ន្ធនឹងមនុស្សទៅតាមនិស្ស័យរបស់ពួកគេ។ ដោយព្រោះតែនិស្ស័យរបស់ពួកគេអាក្រក់និងផ្ទុយពីសេចក្តីល្អ នៅពេលព្រះជំរុញឲ្យពួកគេចាប់ផ្តើមធ្វើសកម្មភាពអ្វីមួយ សកម្មភាពនោះក៏អាក្រក់ហើយផ្ទុយពីសេចក្តីល្អដែរ។ ឧបមាថា បើបុរសម្នាក់ជិះសេះ ហើយសេះនោះមានតែជើងពីឬបីប៉ុណ្ណោះដែលល្អ យ៉ាងនោះការជិះរបស់គាត់ក៏អាស្រ័យទៅតាមលក្ខណៈនៃសេះរបស់គាត់នោះដែរ។ ប្រសិនបើសេះរត់មិនបានល្អ តើអ្នកជិះអាចធ្វើអ្វីបាន? គាត់កំពុងតែជិះសេះនេះជាមួយនឹងសេះល្អៗដទៃទៀត។ ហើយទោះជាសេះដទៃទៀតរត់បានល្អក៏ដោយ ក៏សេះរបស់បុរសនោះមិនអាចរត់បានល្អដែរ ប្រសិនបើវាមិនទាន់ជានៅឡើយនោះ។

ដូច្នេះអ្នកឃើញហើយ នៅពេលណាព្រះធ្វើអ្វីមួយតាមរយៈមនុស្សអាក្រក់ នោះសេចក្តីអាក្រក់នឹងកើតឡើងជាមិនខាន។ ប៉ុន្តែ ព្រះទ្រង់ផ្ទាល់មិនអាចធ្វើអាក្រក់បានទេ។ ព្រះមានអំណាចគ្រប់គ្រង។ មនុស្សទមិឡល្មើសគឺជាការបង្កើតរបស់ព្រះ ហើយត្រូវចុះចូលនឹងការគ្រប់គ្រងរបស់ព្រះ។ ព្រះមិនបង្អាក់អំណាចគ្រប់គ្រងរបស់ទ្រង់ឡើយ គឺពីព្រោះតែសេចក្តីអាក្រក់របស់មនុស្ស។ មនុស្សទមិឡមិនផ្លាស់ប្តូរសណ្ឋានរបស់ខ្លួនឡើយ។ ជាលទ្ធផល មនុស្សមិនអាចបញ្ឈប់អំពើបាបនិងការវង្វេងរបស់ខ្លួនបានទេ រហូតទាល់តែព្រះវិញ្ញាណនៃព្រះបានដាក់សេចក្តីសុចរិតនៅក្នុងអ្នកនោះ ទើបបាន។

## ការវែកញែកទី ៥ : វិធីសាស្ត្រនៃការធ្វើឲ្យមនុស្សរឹងរូស របស់ព្រះ

មនុស្សទមិឡល្មើសមិនខ្វល់ខ្វាយក្នុងការផ្គាប់ព្រះហឫទ័យដល់ព្រះឡើយ។ ពួកគេចាប់អារម្មណ៍តែការផ្គាប់តែចិត្តខ្លួនឯងប៉ុណ្ណោះ។ ពួកគេស្អប់ ហើយនិងប្រឆាំងនឹងអ្វីៗ ដែលរារាំងមិនឲ្យពួកគេសប្បាយរីករាយចំពោះសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមរបស់ពួកគេ។ ជាពិសេសនៅពេលដំណឹងល្អបានទៅដល់មនុស្សទមិឡល្មើស។ នៅក្នុងដំណឹងល្អ ព្រះបានកាត់ផ្តាច់សេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម និងទំនុកចិត្តដែលមានមូលដ្ឋានលើមនុស្សរបស់ពួកគេ ដូច្នេះបានជាពួកគេត្រឡប់ជាជូរល្វីង ហើយរឹងទទឹងប្រឆាំងនឹងព្រះ និងព្រះបន្ទូលរបស់ទ្រង់។

ព្រះមិនបានបង្កើតសេចក្តីអាក្រក់ថ្មីនៅក្នុងចិត្តរបស់មនុស្សឡើយ។ ទ្រង់ប្រើសេចក្តីអាក្រក់ដែលមាននៅទីនោះស្រាប់ ដើម្បីគោលបំណងដ៏ល្អនិងប្រកបដោយប្រាជ្ញាញាណរបស់ទ្រង់។ នៅក្នុង ២សាំយូអែល ១៦:១០ ស្តេចដាវីឌបាននិយាយពីស៊ីម៉ាយថា៖ “វាជេរប្រមាថដូច្នេះ នោះគឺដោយព្រោះព្រះយេហូវ៉ាទ្រង់បានប្រាប់ឲ្យវាជេរប្រមាថ”។ ព្រះមិនបានចេញបង្គាប់ថា គួរឲ្យស៊ីម៉ាយគួរតែជេរស្តេចដាវីឌនោះទេ។ ជំនួសមកវិញ ដើម្បីឲ្យសកម្មភាពគ្រប់គ្រងរបស់ព្រះធានាថាឆន្ទៈដ៏អាក្រក់ដែលមានស្រាប់របស់ស៊ីម៉ាយ នឹងធ្វើអ្វីមួយទៅតាមនិស្ស័យនៃឆន្ទៈនោះ នៅពេលមួយហើយនៅទីកន្លែងមួយ ដែលព្រះសព្វព្រះហឫទ័យ។

## ការរែកញែកទី ៦ : ការធ្វើឲ្យមានភាពរឹងរូសរបស់ព្រះ ដល់ចិត្តរបស់ស្តេចផារ៉ោន

ចូរចាំការទាំងអស់នេះនៅក្នុងគំនិត ហើយយើងត្រឡប់ទៅករណីស្តេចផារ៉ោនវិញ។ ព្រះមិនបានផ្លាស់ប្តូរនិស្ស័យរបស់ស្តេចផារ៉ោន ដោយព្រះវិញ្ញាណបរិសុទ្ធទេ។ ឆន្ទៈរបស់ស្តេចផារ៉ោននៅតែទមិឡល្មើសហើយអាក្រក់ដដែល។ គាត់បានពោរពេញទៅដោយភាពអស្ចារ្យនិងអំណាចផ្ទាល់ខ្លួនរបស់គាត់។ ដូច្នេះនៅពេលដែលព្រះបានប្រទានឲ្យគាត់នូវអ្វីដែលធ្វើឲ្យគាត់អត់ចិត្តហើយក្រេវក្រោធ គាត់មិនអាចជៀសវាងប្រតិកម្មនៅក្នុងរបៀបអាក្រក់មួយបាន។ គាត់កាន់តែរឹងចចេសឡើងៗ ហើយបដិសេធមិនព្រមស្តាប់ហេតុផល។

គេត្រូវតែយល់ព្រះបន្ទូលនៃបទគម្ពីរ ទៅតាមអត្ថន័យដ៏ងាយយល់របស់វា។ នៅពេលដែលព្រះមានបន្ទូលថា៖ “អញនឹងធ្វើឲ្យផារ៉ោនមានចិត្តរឹង” គឺទ្រង់កំពុងតែមានបន្ទូលថា៖ “ទ្រង់នឹងបណ្តាលឲ្យចិត្តរបស់ផារ៉ោនត្រឡប់ជារឹងរូស”។ ដោយភាពជាក់ច្បាស់ពេញលេញដែលទ្រង់បានជ្រាប ហើយទ្រង់បានប្រកាសថា ស្តេចផារ៉ោនគួរតែមានចិត្តរឹង។ ព្រះបានជ្រាបយ៉ាងច្បាស់ថា ស្តេចផារ៉ោនមិនអាចបញ្ឈប់សកម្មភាពរបស់ព្រះដែលត្រូវកើតឡើង ចំពោះគាត់បានឡើយ។ ហើយទ្រង់បានជ្រាបថា ជាលទ្ធផល ស្តេចផារ៉ោននឹងកាន់តែអាក្រក់ឡើងៗ។ ឆន្ទៈអាក្រក់ចង់តែធ្វើការអាក្រក់ប៉ុណ្ណោះ។ សូម្បីតែការល្អខ្លះដែលព្រះនាំមកឯពួកគេដូចជាដំណឹងល្អ ដើម្បីឲ្យមានការទាក់ទងគ្នាក៏ដោយ ក៏ឆន្ទៈអាក្រក់ ចង់តែធ្វើការអាក្រក់ប៉ុណ្ណោះ។ ហើយវាក៏ក្លាយជារឹងចចេស។

ហេតុអ្វីបានជាព្រះមិនបញ្ឈប់ឆន្ទៈដែលបង្កើតការអាក្រក់នោះទៅ? ការនេះត្រូវសូមព្រះឲ្យឈប់ធ្វើជាព្រះ។ យើងមិនអាចស្រមើស្រមៃថា ព្រះនឹងឈប់ធ្វើការល្អ ដោយព្រោះតែឆន្ទៈទមិទ្បល្មើសមានប្រតិកម្មអាក្រក់នោះឡើយ។

ហេតុអ្វីបានជាព្រះមិនផ្លាស់ប្តូរឆន្ទៈអាក្រក់របស់មនុស្ស ដូចជាស្តេចផារ៉ោននេះទៅ? សំនួរនេះវាប៉ះពាល់ទៅនឹងព្រះហឫទ័យដ៏លាក់កំបាំងរបស់ព្រះដែលមិនអាចវាស់ស្ទង់បាន (រ៉ូម ១១:៣៣)។ ប្រសិនបើនរណាម្នាក់ដែលប្រកាន់ខ្ជាប់នឹងហេតុផលមនុស្ស ហើយមានការអាក់អន់ចិត្តដោយសារការនេះ ក៏អត់ចិត្តទៅ។ ការទទូរទាំនឹងមិនផ្លាស់ប្តូរអ្វីទាំងអស់ ហើយរាស្ត្រជ្រើសរើសរបស់ព្រះនៅតែប្រកាន់ខ្ជាន់ខ្ជួនវិញ។ យើងប្រហែលជាអាចឆ្ងល់ដែរថា ហេតុអ្វីបានជាព្រះអនុញ្ញាតឲ្យលោក អ័ដាម ធ្លាក់ក្នុងអំពើបាប! យើងមិនត្រូវព្យាយាមបង្កើតច្បាប់សំរាប់ព្រះនោះទេ។ អ្វីដែលព្រះធ្វើ មិនមែនត្រឹមត្រូវដោយព្រោះយើងគាំទ្រនោះទេ ប៉ុន្តែដោយព្រោះទ្រង់សព្វព្រះហឫទ័យនឹងការនោះវិញ។ បើចង់ផ្លាស់ប្តូរការនេះ មានតែមួយប៉ុណ្ណោះ គឺត្រូវបង្កើតព្រះអាទិករមួយទៀតដែលធំលើសជាងព្រះជាម្ចាស់!

សូមយើងត្រឡប់ទៅកាន់អត្ថបទវិញ។ អ្នកមិនយកចិត្តទុកដាក់ចំពោះអត្ថន័យត្រង់ៗនៃអត្ថបទនេះទេ ពីព្រោះអ្នកមិនចូលចិត្តវា ហើយបន្ទាប់មកអ្នកបានដាក់ "ការពន្យល់" ផ្ទាល់ខ្លួនរបស់អ្នកលើអត្ថបទនេះវិញ។ ប៉ុន្តែ យើងត្រូវពិនិត្យលើអត្ថបទមួយនៅក្នុងបរិបទរបស់វា ដើម្បីស្វែងរក គោលដៅ និងគោលបំណងរបស់អ្នកនិពន្ធ។ អត្ថន័យត្រង់ៗគឺថា ព្រះធ្វើឲ្យផារ៉ោនមានចិត្តរឹង

ដោយមធ្យោបាយនៃគ្រោះកាចនានា។ ប៉ុន្តែ អ្នកនិយាយថា ដោយមធ្យោបាយនៃការអត់ធ្មត់របស់ព្រះ ហើយនិងដោយការមិនដាក់ទណ្ឌកម្មភ្លាមដល់ផារ៉ោនទៅវិញ។ ប៉ុន្តែ សូមមើលមកឯបរិបទរបស់វា។ ព្រះបានរង់ចាំដោយសេចក្តីអត់ធ្មត់ជាយូរណាស់មកហើយ នៅខណៈពេលដែលផារ៉ោន ធ្វើឲ្យពួកកូនចៅអ៊ីស្រាអែលបានឈឺចាប់នោះ។ ជាការពិតណាស់ នៅពេលដែលព្រះបានមានបន្ទូលថា ទ្រង់នឹងធ្វើឲ្យចិត្តរបស់ផារ៉ោនរឹង គឺទ្រង់ចង់ធ្វើអ្វីមួយដែលផ្សេងវិញពោលគឺជាការផ្លាស់ប្តូរពីការអត់ធ្មត់របស់ទ្រង់ មានន័យថា ការអត់ធ្មត់មិននៅតែបន្តទៀតទេ ។ យើងដឹងពីមូលហេតុ ដែលមានភាពខុសគ្នាមួយ។ ព្រះកំពុងតែមានបំណងរំដោះរាស្ត្រទ្រង់ឲ្យរួចពីប្រទេសអេស៊ីព្ទ។ ទ្រង់មានបំណងព្រះហឫទ័យផ្តល់ហេតុផលបន្ថែមទៀតដល់រាស្ត្រទ្រង់ ដើម្បីឲ្យមានទំនុកចិត្តនៅក្នុងទ្រង់។ ការរឹងទទឹងរបស់ស្តេចផារ៉ោនបានធ្វើឲ្យមានគ្រោះកាចកាន់តែច្រើនឡើងហើយ គ្រោះកាចថ្មីៗនិមួយៗសុទ្ធតែបង្ហាញពីអំណាចព្រះចេស្តារបស់ទ្រង់។ មិនត្រឹមតែប៉ុណ្ណោះ បន្ទាប់ពីគ្រោះកាចនិមួយៗ លោកម៉ូសេ បានកត់ត្រាទុកថា "ផារ៉ោនមានចិត្តរឹង ដូចជាព្រះយេហូវ៉ាបានមានបន្ទូល"។ ត្រង់នេះជាចំនុចដែលកំពុងតែធ្វើឲ្យជំនឿរបស់ពួកអ៊ីស្រាអែល កាន់តែខ្លាំងឡើង ក្នុងព្រះជាម្ចាស់។

អ្នកចង់ឲ្យស្តេចផារ៉ោនមានឆន្ទៈមួយដែលមានសេរីភាពដើម្បីចុះចូលឬដើម្បីបះបោរប្រឆាំង ដូច្នេះអ្នកទាមទារអោយអត្ថបទនេះមានន័យថា ផារ៉ោនធ្វើឲ្យចិត្តគាត់រឹងដោយខ្លួនឯង ជាជាងព្រះធ្វើឲ្យរឹង។ ប៉ុន្តែសូមមើលពីអត្ថន័យដែលវាគួរមាន។ ព្រះអាចនឹងពឹងលើ "ឆន្ទៈសេរី" របស់ផារ៉ោន ហើយទ្រង់

អាចនឹងមិនបាច់ប្រាប់លោក ម៉ូសេ និងរាស្ត្ររបស់ទ្រង់ជាមុននូវអ្វីដែលនឹងកើតឡើង។ ប៉ុន្តែទ្រង់បានធ្វើការទាំងអស់នេះវិញ គឺព្រះបានធ្វើឲ្យចិត្តផារ៉ោនរឹងទទឹង។ ព្រះបានធ្វើឲ្យផារ៉ោនធ្វើសកម្មភាព ហើយផារ៉ោនមិនអាចធ្វើអ្វីក្រៅពីកិច្ចការតាមនិស្ស័យរបស់គាត់នោះឡើយ។ ដូច្នេះយើងឃើញថា អត្ថបទនេះមិនអាចយកមកគាំទ្រ "ឆន្ទៈសេរី" បានទេ តែផ្ទុយទៅវិញបែរជាប្រឆាំងនឹងវា (ឆន្ទៈសេរី) តែប៉ុណ្ណោះ។

## ការរែកញែកទី ៧ : ការនិយាយអំពីគម្ពីររ៉ូម៩:១៥-៣៣របស់ អែរ៉ាស្មឹស

អ្នកត្រូវបានរងការឈឺចាប់យ៉ាងដំណំដោយសារអត្ថបទនេះ។ អ្នកប្ដេជ្ញាប្រកាន់ខ្ជាប់ចំពោះ "ឆន្ទៈសេរី" ទោះជាយ៉ាងណាក៏ដោយ ដូច្នេះ អ្វីដែលអ្នកនិយាយសុទ្ធតែជាការដែលផ្ទុយទាំងអស់ ជាពិសេសអំពីបុព្វញ្ញាណរបស់ព្រះ។ សូមឲ្យយើងយល់ឲ្យច្បាស់អំពីការនេះ។ ឧទាហរណ៍៖ ព្រះបានជ្រាបជាមុនថា យូដាសនឹងក្លាយជាជនក្បត់។ ដូច្នេះ យូដាស ត្រូវតែក្លាយជាជនក្បត់។ យូដាស គ្មានអំណាចដើម្បីនឹងធ្វើសកម្មភាពណាមួយបានដោយសេរីនិងដោយស្ម័គ្រពីចិត្តទៅតាមនិស្ស័យរបស់គាត់បានឡើយ។ ព្រះបានជ្រាបជាមុនពីរបៀបដែល យូដាស ត្រូវធ្វើសកម្មភាព ហើយព្រះទ្រង់បាននាំឲ្យមានសកម្មភាពនៅក្នុងការសំដែងនោះនៅពេលដែលទ្រង់សំរេចព្រះហឫទ័យឲ្យកើតឡើង។

វាគ្មានប្រយោជន៍ទេ ដែលអ្នកជជែកអំពីការដឹងជាមុនរបស់មនុស្សនោះ

ពីព្រោះខ្វះមិនដល់បុព្វញ្ញាណរបស់ព្រះឆ្ងាយណាស់។ ឧទាហរណ៍៖ យើងដឹងថា បាតុភូតចន្ទគ្រាសនឹងកើតឡើង។ ប៉ុន្តែ វាមិនបានកើតឡើងដោយព្រោះតែយើងព្យាករនោះទេ។ ប៉ុន្តែ ព្រះនៅពេលដែលទ្រង់ព្យាករអ្វីមួយ ហើយការនោះកើតឡើង ដោយព្រោះទ្រង់ព្យាករវា។ ប្រសិនបើអ្នកមិនទទួលស្គាល់ការនេះទេ នោះមានន័យថា អ្នកមើលងាយគ្រប់ទាំងសេចក្តីសន្យា និងការព្រមានរបស់ព្រះហើយ។ អ្នកបដិសេធព្រះផ្ទាល់តែម្តង។

នៅកន្លែងមួយអ្នកមានគំនិតត្រឹមត្រូវ ក្នុងការទទួលស្គាល់ថា សាវក ប៉ុល បង្រៀនថា ព្រះសព្វព្រះហឫទ័យនឹងអ្វីដែលទ្រង់ជ្រាបជាមុន ដូច្នេះវាត្រូវតែកើតឡើង។ ប៉ុន្តែ បន្ទាប់មកអ្នកបែរជាធ្វើឲ្យវាខូច ដោយការនិយាយថា អ្នក ពិបាករកការនេះទៅវិញ។ បន្ទាប់មកអ្នកព្យាយាមគេចវេសដោយនិយាយថា សាវក ប៉ុល មិនបានពន្យល់ពីអត្ថន័យទេ ប៉ុន្តែគាត់គ្រាន់តែស្តីបន្ទោសដល់ពួកអ្នកដែលប្រកែកនឹងគាត់ប៉ុណ្ណោះ (រ៉ូម ៩:២០) ។ ការនេះគឺគ្មានផ្លូវជួយដល់អត្ថបទដ៏បរិសុទ្ធនេះឡើយ។ នៅពេលដែលយើងក្រឡេកមើលអត្ថបទនេះមួយភ្លែត នឹងឃើញថា សាវក ប៉ុល ពិតជាពន្យល់ពីបញ្ហាប្រាកដមែន។ តាមពិតទៅនឹងមិនមានហេតុផលដែលធ្វើឲ្យមានការស្តីបន្ទោសនោះទេ ប្រសិនបើគ្មានអ្នកណាប្រកែកប្រឆាំងនឹងការពន្យល់របស់គាត់នោះ។ សាវក ប៉ុល បានដកស្រង់ ពីគម្ពីរនិក្ខមនំ ៣៣:១៩ “រួចទ្រង់មានបន្ទូលតបថា អញនឹងឲ្យអស់ ទាំងសេចក្តីសប្បុរសរបស់អញដើរនៅកាត់មុខឯង ព្រមទាំងប្រកាសពីព្រះនាម “យេហូវ៉ា” នៅមុខឯងផង អញនឹងប្រោសហើយនឹងផ្សាយសេចក្តីមេត្តាករុណាដល់អ្នក

ណាដែលអញចង់ផ្សាយឲ្យ”។ បន្ទាប់មក សាវក ប៉ុល ពន្យល់ថា សកម្មភាពរបស់ព្រះ ទាំងសេចក្តីមេត្តាករុណា ឬទាំងការធ្វើឲ្យចិត្តរឹង គឺមិនអាស្រ័យលើឆន្ទៈសេរីរបស់មនុស្សណាទាំងអស់ ប៉ុន្តែអាស្រ័យលើតែព្រះជាម្ចាស់ផ្ទាល់ប៉ុណ្ណោះ។ សាវក ប៉ុល បានបង្ហាញយ៉ាងច្បាស់ថា បុព្វញាណរបស់ព្រះ ធានានូវសកម្មភាពដែលមនុស្សធ្វើ។ ជាការពិតណាស់ ប្រសិនបើយើងព្យាយាមបង្ហាញពីបុព្វញាណរបស់ព្រះ និងឆន្ទៈសេរីរបស់មនុស្សជាមួយគ្នា នោះយើងនឹងមានបញ្ហា - គឺប្រៀបដូចជាបង្ហាញថា លេខ ៩ និងលេខ ១០ ជាលេខដូចគ្នា យ៉ាងអញ្ចឹង!

ការស្តីបន្ទោសរបស់សាវក ប៉ុល គឺសំរាប់ពួកអ្នកដែលបដិសេធនឹងគំនិតដែលថាពួកគេមិនមាន “ឆន្ទៈសេរី” ហើយការទាំងអស់នោះគឺពឹងផ្អែកលើតែបំណងព្រះហឫទ័យទ្រង់តែមួយប៉ុណ្ណោះ។ នេះគឺជាកន្លែង ដើម្បីឲ្យយើងបានស្រឡាញ់ភាពឧត្តុង្គឧត្តមនៃព្រះ នៅក្នុងគំនិតដែលគួរឲ្យស្ញប់ស្ញែង អស្ចារ្យរបស់វា ហើយ ដើម្បីឲ្យយើងបាននិយាយថា “សូមឲ្យរាជ្យទ្រង់បានមកដល់ សូមឲ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដីដូចនៅស្ថានសួគ៌ដែរ” (ម៉ាថាយ ៦:១០)។

## ការរែកញែកទី ៨ : ហេតុផលនៃធម្មជាតិ ត្រូវតែយល់ទទួលស្គាល់អំណាចគ្រប់គ្រងនៃបំណងព្រះហឫទ័យរបស់ព្រះ

ប្រសិនបើបុព្វញាណរបស់ទ្រង់មិនអាចទុកចិត្តបាន ហើយអាចនឹងត្រឡប់ត្រឡិន

ដោយព្រឹត្តិការណ៍នានា នោះហេតុផលធម្មជាតិត្រូវតែទទួលស្គាល់ថា ព្រះជាព្រះដែលខ្សោយហើយឥតប្រយោជន៍។ ជាការពិតណាស់ មនុស្សនឹងបដិសេធចំពោះគំនិតដែលថា ព្រះទ្រង់ល្អ ទ្រង់គួរចាកចោលគេ ធ្វើឲ្យគេរឹងរូស និងជំនុំជំរះពួកគេប្រៀបដូចជាទ្រង់សប្បាយព្រះហឫទ័យនឹងអំពើបាបរបស់ពួកគេ និងទារុណកម្មអស់កល្បជានិច្ច។ ខ្ញុំផ្ទាល់ធ្លាប់ជំពប់ដួលនឹងការនេះម្តងពីរដងដែរ។ ខ្ញុំបានធ្លាក់ទៅក្នុងរណ្តៅដ៏ជ្រៅបំផុតនៃការអស់សង្ឃឹម អញ្ចឹងហើយបានខ្ញុំធ្លាប់គិតថា ខ្ញុំមិនគួរកើតមកជាមនុស្សទេ។ (ពេលនោះគឺនៅពេលមុនដែលខ្ញុំបានស្គាល់ថា សេចក្តីអស់សង្ឃឹមបានផ្តល់សុខភាពឲ្យខ្ញុំ ហើយតើខ្ញុំនៅជិតព្រះគុណ យ៉ាងណា)។ នេះហើយជាមូលហេតុដែលមនុស្សព្យាយាមរក “ការពន្យល់” ហើយមានការត្រិះរិះពិចារណាផ្ទាល់របស់ខ្លួនគេ មុនពេលដែលបានឃើញការនោះត្រូវបានបង្រៀនយ៉ាងច្បាស់នៅក្នុងព្រះបន្ទូលរបស់ព្រះវិញ។

ទោះបីជាការត្រិះរិះពិចារណានៃការដែលមិនជឿលើព្រះ ត្រូវបានខកចិត្តក៏ដោយ ប៉ុន្តែវានឹងត្រូវបានបង្ខំឲ្យទទួលស្គាល់អំណាចគ្រប់គ្រងនៃបំណងព្រះហឫទ័យនៃព្រះ ទោះជាគ្មានព្រះគម្ពីរក៏ដោយ ដ្បិតមានការពីរដែលត្រូវបានកត់ត្រានៅក្នុងបញ្ញាចិត្តរបស់មនុស្ស- គឺថា ព្រះគឺជាស្តេចគ្រប់គ្រង ហើយទ្រង់ជ្រាបជាមុនចំពោះការទាំងអស់ដោយគ្មានការលើកលែង ឬកំហុសឡើយ។

## ការវែកញែកទី ៩ : គម្ពីររ៉ូម ៩:១៥-៣៣ (បន្ត)

នៅក្នុងព្រះគម្ពីររ៉ូម ៩:២០, ២១ សាវក ប៉ុល បាននិយាយថា មនុស្សប្រៀបដូចជាដីឥដ្ឋ ហើយព្រះប្រៀបដូចជាជាងស្មូន។ គ្មានអ្វីច្បាស់ជាងការដែលគោលបំណងទាំងស្រុងរបស់សាវក ប៉ុល បានបដិសេធ “ឆន្ទៈសេរី” នៅក្នុងមនុស្ស ទៀតទេ។ ករណីទាំងស្រុងរបស់សាវក ប៉ុល នៅក្នុងសំបុត្រនេះគឺថា ប្រសិនបើមានអំណាចនៅក្នុងមនុស្សដើម្បីជួយសង្គ្រោះខ្លួនឯងមែន នោះព្រះគុណរបស់ព្រះទៅជាឥតប្រយោជន៍។ រីឯនៅក្នុងជំពូក ១១:២០-២៣ ជាពេលដែលសាវក ប៉ុល កំពុងតែបង្ហាញថា សាសន៍ដទៃនឹងបានសង្គ្រោះដែរ។ គាត់មិនបានរាប់ការនេះថា ដោយព្រោះ “ឆន្ទៈសេរី” របស់ពួកគេនោះទេ ប៉ុន្តែដោយកិច្ចការរបស់ព្រះវិញ ដែលទ្រង់បានផ្សាំពួកគេវិញ។

## ការវែកញែកទី ១០ : អំណាចគ្រប់គ្រងរបស់ព្រះ និង “ឆន្ទៈសេរី” មិនអាចរស់នៅ ជាមួយគ្នាបានទេ។

ត្រង់នេះគឺជាឧទាហរណ៍មួយនៃការត្រិះរិះពិចារណារបស់អ្នក។ អ្នកនិយាយ “ទាក់ទងនឹងបុព្វញាណដ៏មិនអាចបំបែកបាននៃព្រះ គឺថាយូដាសត្រូវតែក្លាយជាអ្នកក្បត់ព្រះអង្គ ទោះជាអញ្ចឹងក៏ដោយ ក៏យូដាសអាចផ្លាស់ប្រែឆន្ទៈរបស់គាត់បានដែរ”។ តើការដែលអ្នកកំពុងតែនិយាយនេះ អ្នកលើកវាមកដោយខ្លួនឯងឬ? ប្រសិនបើវាដូចជាអ្នកនិយាយមែននោះ មានន័យថា យូដាសមានអំណាចដើម្បីផ្លាស់ប្តូរ

បុព្វញ្ញាណរបស់ព្រះ ហើយធ្វើឲ្យបុព្វញ្ញាណរបស់ព្រះមិនគួរឲ្យទុកចិត្តបាន។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនបានដោះស្រាយបញ្ហានេះទាល់តែសោះ។ អ្នកប្រៀបដូចជាមេបញ្ជាការម្នាក់ដែលដឹកនាំកងទ័ពទៅច្បាំង ហើយបន្ទាប់មកបែរជារត់ចោលពួកគេ ក្នុងខណៈដែលពួកគេកំពុងតែត្រូវការជំនួយដ៏ចាំបាច់ពីអ្នកទៅវិញ! អ្នកក៏ស្ទុះទៅចាប់យកការមួយផ្សេងទៀតមកនិយាយថា ឆន្ទៈរបស់មនុស្សត្រូវបានរំខានដោយអំណាចគ្រប់គ្រងរបស់ព្រះទៅវិញ។ ខ្ញុំសួរអំពីគោ តែអ្នកបែរជាឆ្លើយអំពីក្របីទៅវិញ! ប៉ុន្តែខ្ញុំនឹងមិនឲ្យអ្នករួចពីផ្លែសន្ទូចដោយស្រួលនោះទេ។ អ្នកត្រូវតែប្រឈមមុខនឹងស្ថានភាពដែលរារែកជាមិនខាន។ “យូដាសអាចមានឆន្ទៈក្នុងការមិនក្បត់បាន” និង “យូដាសត្រូវតែមានឆន្ទៈក្នុងការក្បត់ជាពុំខាន”។ តើការទាំងពីរនេះអាចត្រូវគ្នាបានដោយរបៀបណា? តើការទាំងពីរនេះមិនប្រឆាំងគ្នា ហើយផ្ទុយពីគ្នាទេឬអី?

## ការរែកញែកទី ១១ : ការបកស្រាយអំពីគម្ពីរម៉ាឡាគី ១:២-៣ របស់ អេរ៉ាស្មឹស

ឥឡូវនេះយើងត្រូវតែបែរទៅអត្ថបទទីពីរដែលអ្នកលើកឡើង អាចនឹងគាំទ្រដល់ជំហររបស់ខ្ញុំអំពី “ឆន្ទៈសេរី” ទោះបីជាការពិតអ្នកបដិសេធថា វាមិនគាំទ្រក៏ដោយ។ តើអ្វីទៅជាការរែកញែករបស់អ្នក? នៅក្នុងគម្ពីរលោកុប្បត្តិ ២៥:២៣ ចែងថា “កូនច្បងនឹងត្រូវបំរើប្អូន”។ “ការពន្យល់” របស់អ្នក ពន្យល់យ៉ាងដូច្នេះថា៖ “វាមិនទាក់ទងនឹងការសង្គ្រោះរបស់មនុស្សនោះទេ ដ្បិតព្រះអាចនឹងមានព្រះហឫទ័យ ឲ្យមនុស្សម្នាក់គួរក្លាយជាបាវបំរើផង និងជាអ្នកក្រីក្រផង ដោយ

គ្មានការបដិសេធពីសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ចទេ”។

នោះជាគំនិតដែលមិនអាចទុកចិត្តបានដែលអ្នកមាន ដើម្បីព្យាយាមគេចពីសេចក្ដីពិត! តែអ្នកមិនអាចគេចបានទេ។ ចូរគិតអំពីការប្រើប្រាស់អត្ថបទនេះនៅក្នុងគម្ពីររ៉ូម ៩:១២-១៣។ តើសាវក ប៉ុល កំពុងតែប្រើបទគម្ពីរច្រឡំ ក្នុងខណៈពេលដែលគាត់លាតត្រដាងពីមូលដ្ឋានគ្រឹះនៃគោលលទ្ធិរបស់គ្រីស្ទានឬ? ទេ គាត់មិនបានប្រើប្រាស់វាច្រឡំទេ! ចេរ៉ូម ហ៊ាននិយាយថា “ការជាច្រើនសុទ្ធតែមានកំលាំងមួយនៅក្នុងសាវក ប៉ុល ដែលពួកវាមិនមាននៅក្នុងបរិបទដើមរបស់ពួកគេ។ ចេរ៉ូមអាចនិយាយអញ្ចឹងបាន ប៉ុន្តែការនោះគឺជាការដែលគ្មានភស្តុតាងបញ្ជាក់។ មនុស្សដូចចេរ៉ូមនេះ គឺជាមនុស្សដែលមិនយល់ពីសាវក ប៉ុល ឬអត្ថបទដែលគាត់ដកស្រង់មកនិយាយនោះឡើយ។ ខ្ញុំមិនអាចឯកភាពថា លោកុប្បត្តិ ២៥:២១-២៣ សំដៅលើតែម្នាក់ដែលត្រូវបំរើម្នាក់ទៀតនោះទេ ប៉ុន្តែសូមឲ្យយើងឧបមាមួយភ្លែតសិនថា វាដូចជាអ្វីដែលចេរ៉ូមនិយាយចុះ។ យើងនៅតែអាចឃើញថា សាវក ប៉ុល ដកស្រង់យ៉ាងត្រឹមត្រូវ ដើម្បីបង្ហាញថា មានការល្អណានៅក្នុងយ៉ាកុប ឬអេសាវឡើយ។ សាវក ប៉ុល កំពុងតែពិភាក្សាថាតើ អ្វីដែលពួកគេទទួលបានដោយការល្អនៃ “ឆន្ទៈសេរី” ឬយ៉ាងណា។ រួចហើយគាត់បង្ហាញថា ពួកគេមិនមានការល្អយ៉ាងដូច្នោះទេ។ ការទាំងអស់ត្រូវបានកំណត់ឡើងតាំងពីមុនដែលពួកគេបានកើតមកទៅទៀត។

យោបល់របស់សាវក ប៉ុល អំពីលោកុប្បត្តិ ២៥:២៣ ថា មិនត្រូវលើកមកនិយាយគ្រាន់តែសំដៅទៅកិច្ចការតូចតាចមួយនោះទេ។ បទគម្ពីរនេះពិតជាមាន

ឥទ្ធិពលមួយអំពីសេចក្ដីសង្គ្រោះដ៏អស់កល្បវិញ។ លោក យ៉ាកុប គឺជារាស្ត្រជ្រើសរើសម្នាក់របស់ព្រះ។ សេចក្ដីសន្យាចំពោះគាត់ និងការទាំងអស់ដែលជាកម្មសិទ្ធិរបស់រាស្ត្រទ្រង់ គឺព្រះពរ, ព្រះបន្ទូល, ព្រះវិញ្ញាណ, សេចក្ដីសន្យាពីព្រះគ្រីស្ទ និងនគរដ៏អស់កល្បរបស់ទ្រង់។ ការនេះត្រូវបានបញ្ជាក់នៅក្នុងលោកុប្បត្តិ ចាប់ពី ២៧:២៧ ទៅ។ ដូច្នេះការឆ្លើយតបរបស់យើងទៅកាន់ចេរ៉ូម គឺថា គ្រប់ទាំងអត្ថបទដែលបានដកស្រង់ដោយពួកសាវក មានកំលាំងខ្លាំងជាងនៅក្នុងអត្ថបទដើមរបស់ពួកវា និងខ្លាំងជាងនៅក្នុងសំណេររបស់ចេរ៉ូម!

សំរាប់អត្ថបទពីគម្ពីរម៉ាឡាគី ១:២-៣ សាវក ប៉ុលក៏បានដកស្រង់ផងដែរថា "ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញបានស្រឡាញ់ឯងរាល់គ្នា ប៉ុន្តែឯងរាល់គ្នាថា ទ្រង់មានស្រឡាញ់យើងឯណា ព្រះយេហូវ៉ាទ្រង់តបថា ឯអេសាវ តើមិនមែនជាបងរបស់យ៉ាកុបទេឬអី ទោះបីយ៉ាងនោះ គង់តែអញបានស្រឡាញ់យ៉ាកុប តែចំណែកអេសាវនោះ អញបានស្អប់វិញ ហើយបានធ្វើឲ្យស្រុកភ្នំរបស់គេបានស្ងាត់ច្រៀប ក៏ឲ្យមរតករបស់គេដល់ពួកស្វាននៅទីរហោស្ថាន"។ អ្នក អែរ៉ាស្មឹស មានវិធីបីយ៉ាងដើម្បីព្យាយាមគេចចេញពីអត្ថន័យដ៏ច្បាស់លាស់នៃព្រះបន្ទូលទាំងនេះ។

វិធីទីមួយគឺថា យើងមិនអាចពន្យល់ការនេះជាន័យដ៏ងាយយល់បានឡើយ ពីព្រោះសេចក្ដីស្រឡាញ់ និង សេចក្ដីសំអប់របស់ព្រះ ខុសពីសេចក្ដីស្រឡាញ់និងសេចក្ដីសំអប់របស់មនុស្ស គឺគ្មានអារម្មណ៍មនុស្សនៅក្នុងសេចក្ដីទាំងនេះឡើយ។ ឥឡូវនេះយើងរាល់គ្នាដឹងហើយថា សេចក្ដីស្រឡាញ់ និង

សេចក្តីសំអប់របស់ព្រះមិនមែនជាអារម្មណ៍របស់មនុស្សទេ ប៉ុន្តែសំនួរដែលយើងប្រឈមមុខ តំរូវមិនឲ្យយើងសួរ ពីរបៀបដែលព្រះស្រឡាញ់ និងស្អប់ទេ ប៉ុន្តែតំរូវឲ្យសួរពីមូលហេតុដែលព្រះស្រឡាញ់និងស្អប់វិញ។ ប៉ុន្តែដោយព្រោះអ្នកចង់ទាញចំណាប់អារម្មណ៍មកឯរបៀបដែលព្រះស្រឡាញ់ និងស្អប់វិញនោះ សូមយើងមើលមួយភ្លែតសិន ថាតើការនេះជួយដល់ករណីរបស់អ្នកដែរឬយ៉ាងណា។ វាមិនបានជួយអ្វីទាល់តែសោះ។ សេចក្តីស្រឡាញ់ និងសេចក្តីស្អប់របស់ព្រះមិនមែនចេះតែផ្លាស់ប្រែដូចជាសេចក្តីស្រឡាញ់ និងសេចក្តីសំអប់របស់យើងនោះទេ។ នៅក្នុងព្រះ សេចក្តីស្រឡាញ់ និងសេចក្តីសំអប់ ស្ថិតស្ថេរនៅអស់កល្ប និងមិនចេះផ្លាស់ប្រែ។ សេចក្តីស្រឡាញ់ និងសេចក្តីសំអប់ ត្រូវបានកំណត់ឡើងមុនពេល "ឆន្ទៈសេរី" កើតឡើងទៅទៀត ដូច្នេះយើងឃើញថា សេចក្តីស្រឡាញ់ និងសេចក្តីសំអប់ មិនរង់ចាំការឆ្លើយតបរបស់មនុស្សឡើយ។ ការនេះកាន់តែច្បាស់លាស់ជាង នៅពេលដែលយើងសួរថា ហេតុអ្វីបានជាព្រះស្រឡាញ់និងស្អប់។ តើគេបានធ្វើអ្វីដើម្បីឲ្យព្រះស្រឡាញ់ដល់យ៉ាកុប ឬស្អប់អេសាវ? ជាការពិតណាស់ពួកគេមិនបានធ្វើអ្វីទាំងអស់ ពីព្រោះសេចក្តីស្រឡាញ់ និងសំអប់ចំពោះពួកគេ គឺតំរូវតាំងពីពួកគេមិនទាល់កើតមកម្ល៉េះ។ នៅកន្លែងនេះ "ឆន្ទៈសេរី" ពុំមានតួនាទីអ្វីសោះ!

របៀបទីពីរដែលព្យាយាមគេចចេញពីអត្ថន័យដ៏ងាយយល់នៃពាក្យគឺៈ អ្នកនិយាយថា លោក ម៉ាឡាគី ហាក់ដូចជាមិនកំពុងតែនិយាយពីនៃសេចក្តីសំអប់ដែលយើងរាល់គ្នាត្រូវផ្តន្ទាទោសដ៏នៅអស់កល្បជានិច្ចនោះទេ។ អ្នកលើកការនោះឡើងថា លោកម៉ាឡាគី គ្រាន់តែនិយាយពីការទុក្ខលំបាកដែលគេជួបប្រទះនៅលើ

ផែនដីនេះប៉ុណ្ណោះ។ ជាថ្មីម្តងទៀត ការនេះគឺជាការលើកឡើងដ៏បង្ខូចថា សាវក ប៉ុល កំពុងតែប្រើបទគម្ពីរខុស។ សូមយើងមើលម្តងទៀត ថាតើការព្យាយាមរត់គេចពីអត្ថន័យដ៏ងាយយល់នៃពាក្យនេះ អាចជួយករណីរបស់អ្នកឬយ៉ាងណា។ ជាការពិតណាស់គំនិតរបស់សាវក ប៉ុល នៅក្នុងខគម្ពីរទាំងនេះគឺដើម្បីសង្កត់ធ្ងន់លើភាពអវត្តមាននៃការល្អ ឬអំណាចនៃ "ឆន្ទៈសេរី"។ ទោះបីជាសាវក ប៉ុល កំពុងនិយាយទាក់ទងតែអ្វីៗដែលជាបទពិសោធន៍លើផែនដីនេះក៏ដោយ ប៉ុន្តែគាត់នៅតែកំពុងប្រើប្រាស់រូបភាពសមរម្យមួយនៅក្នុងរឿងយ៉ាកុបនិងអេសាវដែរ។ នៅក្នុងករណីណាក៏ដោយ វាជាការមិនពិតទេដែលគេលើកឡើងថា លោក ម៉ាឡាគី គ្រាន់តែនិយាយសំដៅតែអ្វីៗដែលជាបទពិសោធន៍លើផែនដីប៉ុណ្ណោះនោះ។ បរិបទនៃបទគម្ពីរនេះបង្ហាញថា គោលបំណងរបស់គាត់គឺដើម្បីស្តីបន្ទោសដល់ប្រជាជនអ៊ីស្រាអែល ពីព្រោះពួកគេមិនបានឆ្លើយតបនឹងសេចក្តីស្រឡាញ់របស់ព្រះដែលទ្រង់មានចំពោះពួកគេ។ សេចក្តីស្រឡាញ់របស់ព្រះចំពោះពួកគេ មានន័យធំធេងជាងការប្រទានពរខាងផែនដីនេះ ដ្បិតបទគម្ពីរនេះបង្ហាញថា ព្រះរបស់យើងគឺជាព្រះលើគ្រប់ទាំងអស់។ ទ្រង់នឹងមិនជាព្រះនៃពួកអ៊ីស្រាអែលដែលថ្វាយបង្គំទ្រង់តែចិត្តពាក់កណ្តាល ជាមួយនឹងដង្វាយសត្វដែលខ្វិចជើងនិងសត្វឈឺ នោះទេ (ម៉ាឡាគី ១:១៣)! ការថ្វាយបង្គំព្រះដ៏ពិត គឺត្រូវថ្វាយបង្គំទ្រង់ឲ្យអស់ពីចិត្ត និងអស់ពីកំលាំង ដ្បិតទ្រង់ជាព្រះទាំងនៅក្នុងបច្ចុប្បន្ននិងបរលោកនាយ ជាព្រះនៅក្នុងគ្រប់ការទាំងអស់ នៅកាលៈទេសៈទាំងអស់ នៅគ្រប់ពេលវេលាទាំងអស់ ហើយនិងនៅក្នុងអ្វីៗទាំងអស់ដែលពួកគេធ្វើ។

ការព្យាយាមទីបីរបស់អ្នកក្នុងការគេចចេញពីអត្ថន័យងាយយល់ នៃបទគម្ពីរម៉ាឡាគី ១:២-៣ គឺអ្នកនិយាយថា លោក ម៉ាឡាគី ចង់សំដៅថា ព្រះស្រឡាញ់ពួកសាសន៍យូដាមួយចំនួន ហើយពួកយូដាខ្លះទៀតទ្រង់ស្អប់។ ការដែលអ្នកគិត ជាការបើកផ្លូវ សំរាប់ការមិនជឿ ដោយពួកយូដាខ្លះដែលស័ក្តិសមឲ្យទ្រង់កាត់ចេញទៅវិញ។ ហើយអ្នកគិតថា "ការបកស្រាយ" របស់អ្នក បើកផ្លូវសំរាប់សេចក្តីជំនឿនៃពួកយូដាខ្លះ ដែលស័ក្តិសមទទួលបាននូវការតភ្ជាប់មកវិញ។

អ្នកមិនដឹងពីអ្វីដែលអ្នកកំពុងនិយាយនោះទេ! ខ្ញុំដឹងថា មនុស្សត្រូវបានកាត់ចេញដោយការមិនជឿ ហើយតភ្ជាប់មកវិញដោយសេចក្តីជំនឿ ហើយនឹងដឹងថា ពួកគេត្រូវតែទទួលការលើកទឹកចិត្ត ហើយជំរុញឲ្យជឿ។ ប៉ុន្តែការនេះគ្មានអ្វីពាក់ព័ន្ធនឹងការជឿ និងការមិនជឿ ដោយអំណាចនៃ "ឆន្ទៈសេរី" នោះឡើយ។

## ការរែកញែកទី ១២ : ជាងស្មូន និងដីឥដ្ឋ

អត្ថបទទីបីដែលអ្នកនិយាយ អាចនឹងគាំទ្រដល់ជំហររបស់ខ្ញុំ គឺគម្ពីរអេសាយ ៤៥:៩ "វេទនាដល់អ្នកណាដែលតតាំងនឹងព្រះ ដែលបានបង្កើតខ្លួនមក គេជាអំបែងឆ្នាំងមួយនៅក្នុងអស់ទាំងអំបែងនៅលើផែនដី តើដីឥដ្ឋប្រកែកចំពោះជាងស្មូនថា តើធ្វើអ្វីដូច្នេះ"។ ហើយនៅក្នុងគម្ពីរយេរេមា ១៨:៦ ផងដែរថា "ឱពួកវង្សអ៊ីស្រាអែលអើយ ដីឥដ្ឋនៅក្នុងដៃរបស់ជាងស្មូនយ៉ាងណា នោះឯងរាល់គ្នាក៏នៅក្នុងដៃអញយ៉ាងនោះដែរ"។ អត្ថបទទាំងនេះពិតជាគាំទ្រករណីរបស់ខ្ញុំយ៉ាងជាក់

ច្បាស់ណាស់ ប៉ុន្តែអ្នកព្យាយាមគេចចេញពីកំលាំងរបស់បទគម្ពីរទាំងនោះ ដោយធ្វើឲ្យ កិច្ចការរបស់ជាងស្មូន ទៅជាបទពិសោធន៍របស់យើងនៅក្នុងជីវិតនេះទៅវិញ។ អ្នកលើកឡើងថា នៅពេលសាវក ប៉ុល ប្រើបទគម្ពីរទាំងនេះ នៅក្នុងគម្ពីររ៉ូម ជំពូក ៩ គាត់បានបន្ថែមអត្ថន័យដើមរបស់បទគម្ពីរទាំងនេះ ដោយធ្វើឲ្យបទគម្ពីរទាំងនេះ សំដៅទៅការជ្រើសរើសផ្ទាល់ខ្លួនវិញ។ នេះគឺជានិយាយមិនពិតពីសាវក ប៉ុល ហើយ។ បន្ទាប់មកអ្នកបានបន្ថែមការវង្វេងវង្វាន់របស់អ្នក ដោយលើកពី ២ធីម៉ូថេ ២:២០-២១ ថា “នៅក្នុងផ្ទះធំ មិនមែនមានសុទ្ធតែគ្រឿងប្រដាប់មាសប្រាក់ម្យ៉ាងទេ គឺមានប្រដាប់ធ្វើពីឈើ ហើយពីដីដែរ ខ្លះសំរាប់ការប្រសើរ ខ្លះសំរាប់ការអាប់ឱនវិញ ដូច្នេះបើអ្នកណាបានសំអាតខ្លួនពីសេចក្តីទាំងនោះ អ្នកនោះនឹងបានជាប្រដាប់សំរាប់ការប្រសើរ ដោយបានញែកជាបរិសុទ្ធហើយ ក៏មានប្រយោជន៍ដល់ម្ចាស់ផង ទុកជាប្រដាប់ដែលបានរៀបចំ សំរាប់ការល្អគ្រប់ជំពូក”។ អ្នកនិយាយថា នៅត្រង់នេះសាវក ប៉ុល កំពុងតែសរសេរពីប្រធានបទដូចគ្នានៅក្នុងគម្ពីរអេសាយ ៤៥:៩; យេរេមា ១៨:៦ ហើយនិងគម្ពីររ៉ូម ៩ ដែរ។ អ្នកអស់សំណើចនឹងគំនិតនៃឆ្នាំងដី ដែលចេះបន្សុទ្ធដោយខ្លួនឯង។ ប៉ុន្តែអ្នកនិយាយថា សាវក ប៉ុល ពិតជាបានបង្គាប់ឲ្យឆ្នាំងនោះធ្វើអញ្ចឹង ហើយបង្ហាញចំពោះការស្តាប់ចិត្តផ្ទាល់របស់អ្នកថា ឆ្នាំងនោះត្រូវតំណាងឲ្យមនុស្សដែលមាន “ឆន្ទៈសេរី”។

ចម្លើយរបស់ខ្ញុំគឺថា សាវក ប៉ុល នៅក្នុង ២ធីម៉ូថេ ២:២០-២១ គឺមិនសំដៅទៅប្រធានបទដូចគ្នានឹងអត្ថបទផ្សេងទៀតនោះទេ។ គាត់កំពុងតែប្រើរូបភាពធម្មតាដើម្បីបង្ហាញប្រធានបទផ្សេងមួយទៀត គឺការគោរពប្រតិបត្តិដល់ព្រះរបស់

អ្នកជឿ។ លើសពីនេះទៅទៀត វាមិនមែនជាចានឆ្នាំងទេ តែជាពួកអ្នកជឿ ដែលព្រះបង្គាប់ឲ្យពួកគេធ្វើវិញ។ ពួកគេត្រូវតែសំអាតខ្លួនរបស់ពួកគេពីគ្រប់ការដែលបង្អាប់បង្អោនដល់ព្រះ។ ដូចជាឆ្នាំងដីអញ្ចឹង ខ្លះល្អស្អាត ហើយខ្លះទៀតមិនល្អស្អាត យ៉ាងនេះគឺអាស្រ័យនឹងម្ចាស់ មិនមែនជាគ្រឿងប្រដាប់ទាំងនោះទេ ដែលត្រូវសំរេចលើការប្រើប្រាស់របស់និមួយៗនោះ។

## ការរែកញែកទី ១៣ : សេចក្ដីសុចរិតរបស់ព្រះ

ឥឡូវនេះ អ្នកប្រើការពិចារណាខាងមនុស្សវិញ។ អ្នកមិនអាចទទួលយកសេចក្ដីសុចរិតរបស់ព្រះ ដើម្បីឲ្យបានបោះចោលសេចក្ដីអាក្រក់ទៅក្នុងភ្លើងដ៏នៅអស់កល្បទេ។ ការដែលអ្នកលើកឡើង នោះមិនសមហេតុផលទាល់តែសោះ ដ្បិតព្រះបានបង្កើតពួកគេតាមរបៀបនៃពួកគេម្នាក់។ ដូច្នេះវាចាកពីសេចក្ដីពិត! អ្នកបានដាក់ខ្លួនរបស់អ្នកនៅក្នុងស្បែកជើងនៃពួកជាន់ឈ្លី ដែលសាវក ប៉ុល កំពុងតែឯកស្រង់នៅក្នុងគម្ពីររ៉ូម ៩:១៩ ថា “ហេតុអ្វីបានជាទ្រង់នៅតែបន្ទោសទៀត ដ្បិតតើអ្នកណាបានទទឹងនឹងព្រះហឫទ័យទ្រង់?” ដូច្នេះហេតុផលខាងមនុស្សទាមទារថា ព្រះគួរតែធ្វើការទៅតាមគំនិតរបស់មនុស្ស ពីអ្វីដែលត្រឹមត្រូវ និងពីអ្វីដែលមិនត្រឹមត្រូវ។ តើព្រះអាទិករដែលបង្កើតអ្វីៗគ្រប់ទាំងអស់ ត្រូវតែចុះចូលនឹងរបស់ដែលជាស្នាព្រះហស្តទ្រង់ឬអី! តើគេត្រូវដាក់ច្បាប់ដល់ព្រះថា ព្រះអាចផ្ដន្ទាទោសតែពួកអ្នកដែលស័ក្ដិសមនឹងទទួល *ដោយតាមការស្មានរបស់យើងឬ!* នៅពេលព្រះសង្គ្រោះដល់ពួកអ្នកដែលមិនស័ក្ដិសមវិញ នោះគ្មានអ្នកណាតវ៉ាបានឡើយ។ ប៉ុន្តែនៅពេល

ដែលព្រះផ្តន្ទាទោសពួកគេ នោះនឹងមានការតវ៉ាដ៏ធំមួយ។ សេចក្តីអាក្រក់នៃចិត្ត មនុស្សគឺត្រូវបង្ហាញនៅត្រង់នេះហើយ។ នៅពេលមនុស្សបានរិះគិតដូចនេះ ពួកគេកំពុងតែបរាជ័យក្នុងការសរសើរដំកើងព្រះទុកជាព្រះហើយ។ ពួកគេប្លន់សិទ្ធិជាស្តេចគ្រប់គ្រងពីព្រះ។ យើងនឹងមិនដែលយល់ពីរបៀបដែលព្រះដ៏សុចរិតមួយអង្គ អាចសង្គ្រោះមនុស្សទមិឡល្មើស រហូតដល់យើងបានទៅដល់ស្ថានសួគ៌។ ដូច្នេះ តើយើងអាចនឹងយល់ពីរបៀបដែលព្រះដ៏សុចរិតមួយអង្គ អាចផ្តន្ទាទោសដល់មនុស្សទមិឡល្មើសដោយរបៀបណា? ប៉ុន្តែសេចក្តីជំនឿនឹងបន្តជឿថាវាអញ្ចឹងមែន ទាល់តែកូនមនុស្សបានលេចមក។

## ការវែកញែកទី ១៨ : សាវក ប៉ុល ទទួលស្គាល់ថា សេចក្តីសង្គ្រោះនៃមនុស្ស គឺដោយសារព្រះតែមួយប៉ុណ្ណោះ

មិនមានការប្រឆាំងគ្នាណាមួយនៅក្នុងបទគម្ពីរទេ លុះត្រាតែអ្នកទាមទារនូវ “ការពន្យល់” របស់អ្នក។ ពេលនោះការវង្វេងវង្វាន់នោះនឹងផើបឡើង។ ឧទាហរណ៍៖ មានការប្រឆាំងគ្នារវាង “បើអ្នកណាបានសំអាតខ្លួន” (២ធីម៉ូថេ ២:២០-២១) និង “ទ្រង់ធ្វើគ្រប់ទាំងអស់” (១កូរិនថូស ១២:៦)។ ចំនុចទីមួយ គ្រាន់តែដាក់ចុះនូវអ្វីដែលមនុស្សគួរធ្វើប៉ុណ្ណោះ។ ការនេះមិនមានន័យថា មនុស្សមានសមត្ថភាពធ្វើវាដោយ “ឆន្ទៈសេរី” ទេ បើគ្មានព្រះគុណនោះ។ ខ្ញុំដឹង អ្នកជឿថា នៅពេលដែលការបង្គាប់មួយត្រូវបានប្រទានមក នោះវាសឲ្យឃើញពីសមត្ថភាពមួយដើម្បីឲ្យបានស្តាប់បង្គាប់។ ប៉ុន្តែការនោះគ្មានន័យសោះ។ អត្ថបទទីពីរវិញនិយាយយ៉ាងច្បាស់

ថា គ្រប់ទាំងអស់ជាកិច្ចការរបស់ព្រះ។ នោះមិនមានការប្រឆាំងគ្នាទេ។ សាវក ប៉ុល តែងតែមានជំហរដដែលនៅក្នុងគ្រប់ទាំងការបង្រៀនរបស់គាត់ គឺថាសេចក្ដី សង្គ្រោះរបស់មនុស្សគឺដោយសារអំណាចព្រះចេស្ដានៃព្រះតែមួយប៉ុណ្ណោះ។

# ជំពូក ៤

## មតិរបស់លោក លូស៊ើរ លើការបកស្រាយអត្ថបទរបស់អ៊ីរ៉ាស្មឺស ដែលបដិសេធនឹង "ឆន្ទៈសេរី"

*ការវែកញែកទី ១ : លោកុប្បត្តិ ៦:៣*

*ការវែកញែកទី ២ : លោកុប្បត្តិ ៨:២១ និងលោកុប្បត្តិ ៦:៥*

*ការវែកញែកទី ៣ : អេសាយ ៤០:១-២*

*ការវែកញែកទី ៤ : អេសាយ ៤០:៦-៧*

*ការវែកញែកទី ៥ : យេរេមា ១០:២៣*

*ការវែកញែកទី ៦ : សុភាសិត ១៦:១*

*ការវែកញែកទី ៧ : យ៉ូហាន ១៥:៥*

*ការវែកញែកទី ៨ : ការសហប្រតិបត្តិការជាមួយព្រះរបស់មនុស្ស មិនបង្ហាញពី "ឆន្ទៈសេរី" ទេ*

*សេចក្តីសន្និដ្ឋាន*

នៅចុងបញ្ចប់ យើងអាចមកឯចំនុចដែលអ្នកដោះស្រាយជាមួយនឹងអត្ថបទ ដែលខ្ញុំប្រើដើម្បីបង្ហាញថា “ឆន្ទៈសេរី” មិនពិត។

## ការវែកញែកទី ១ : លោកុប្បត្តិ ៦::៣ “វិញ្ញាណអញនឹងមិនតវ៉ានឹងមនុស្សជាដរាបទេ ពីព្រោះគេជាសាច់ឈាមប៉ុណ្ណោះ”

មុនដំបូងអ្នកបានវែកញែក “សាច់ឈាម” នៅទីនេះថា ជាភាពកម្សោយមនុស្ស។ ប៉ុន្តែអត្ថន័យនៅទីនេះដូចគ្នានឹង ១កូរិនថូស ៣:១-៣ ត្រង់កន្លែងដែលសាវក ប៉ុល ហៅពួកកូរិនថូសថា “មនុស្សខាងឯសាច់ឈាម” ឬ “តាមបែបមនុស្សលោក”។ សាវក ប៉ុល មិនកំពុងតែនិយាយសំដៅទៅភាពកម្សោយនោះទេ ប៉ុន្តែសំដៅទៅភាពពុករលួយវិញ។ លោក ម៉ូសេ កំពុងតែនិយាយសំដៅទៅមនុស្សដែលរៀបការដោយសារតែអារម្មណ៍ស្រើបស្រាល ហើយនិងពួកអ្នកដែលពោរពេញដោយលោកិយដែលសាហាវយង់ឃ្នងនេះ យ៉ាងនេះហើយបានជាព្រះវិញ្ញាណនៃព្រះមិនអាចបន្តជាមួយពួកគេបាន។ អ្នកនឹងកត់សំគាល់ឃើញថា នៅក្នុងបទគម្ពីរនៅត្រង់កន្លែងណាក៏ដោយឲ្យតែមានពាក្យថា “សាច់ឈាម” សុទ្ធតែប្រឆាំងនឹង “វិញ្ញាណ” មានន័យថា វាទាស់នឹងព្រះវិញ្ញាណនៃព្រះ។ មានតែនៅពេលដែល “សាច់ឈាម” ត្រូវបានប្រើតែឯងប៉ុណ្ណោះ ទើបវាសំដៅថា រូបកាយខាងសាច់ឈាម។ ដូច្នេះ បទគម្ពីរនេះ មានន័យថា “វិញ្ញាណរបស់អញ ដែលមាននៅក្នុងណូអេ និងមនុស្សបរិសុទ្ធឯទៀត ដាស់តឿនមនុស្សទមិឡល្មើស តាមរយៈព្រះបន្ទូលដែលមនុស្សទាំងនេះប្រកាសប្រាប់ និងតាមរយៈជីវិតដែលគោរពប្រតិបត្តិដល់ព្រះរបស់ផង

ពួកគេ។ ប៉ុន្តែវាជាអាសាឥតការ ដ្បិតមនុស្សទមិឡល្មើសត្រូវបានខ្វាក់ ហើយមានចិត្តរឹងរូសដោយសារសាច់ឈាមនោះឯង ហើយកាន់តែអាក្រក់ទៅៗ ហើយកាន់តែជាប់ជំនុំជំរះទៅៗ”។ ការនេះតែងតែកើតឡើង ហើយវាបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ប្រសិនបើមនុស្សកាន់តែអាក្រក់ទៅៗ សូម្បីតែនៅក្នុងខណៈពេលព្រះវិញ្ញាណកំពុងតែធ្វើការក្នុងចំណោមពួកគេក៏ដោយ នោះពួកគេពិតជាគ្មានជំនួយអ្វីទាំងអស់ បើគ្មានព្រះវិញ្ញាណជួយទេនោះ។ “ឆន្ទៈសេរី” មិនអាចធ្វើអ្វីបានទាំងអស់ក្រៅពីធ្វើបាប។

បន្ទាប់មកអ្នកបានប្រាប់យើងថា អត្ថបទនេះមិនសំដៅលើមនុស្សទាំងអស់ទេ គឺសំដៅលើតែពួកដែលបានរស់នៅសម័យនោះប៉ុណ្ណោះ។ ការនេះមិនសំដៅអញ្ចឹងឡើយ ដ្បិតព្រះគ្រីស្ទបានមានបន្ទូលពីមនុស្សទាំងអស់ថា “របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ” (យ៉ូហាន ៣:៦)។ រួចមកទ្រង់បានបង្ហាញពីភាពម៉ឺងម៉ាត់នៃលក្ខខ័ណ្ឌនេះដោយមានបន្ទូលថា “បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ” (យ៉ូហាន ៣:៣)។

បន្ទាប់មកអ្នកនិយាយថា អត្ថបទនេះមិនមានន័យសំដៅទៅកាជំនុំជំរះរបស់ព្រះនោះទេ ប៉ុន្តែសំដៅទៅសេចក្តីមេត្តាករុណារបស់ទ្រង់វិញ។ ប៉ុន្តែអ្វីដែលអ្នកត្រូវធ្វើនោះគឺ ត្រូវអានខាងដើមនិងខាងចុងនៃអត្ថបទនោះវិញ។ នោះអាចនឹងគ្មានការសង្ស័យថា ទាំងនោះជាព្រះបន្ទូលនៃព្រះដ៏មានសេចក្តីក្រោធមួយអង្គឬយ៉ាងណា។ ដូច្នេះអត្ថបទនេះឈរទាស់ប្រឆាំងនឹង “ឆន្ទៈសេរី”។ អត្ថបទនេះបង្ហាញថា គ្មានអំណាចនៅក្នុងមនុស្ស ដើម្បីឲ្យបានធ្វើការល្អឡើយ ប៉ុន្តែធ្វើ

អោយបានតែការជំនុំជំរះរបស់ព្រះប៉ុណ្ណោះ។

**ការវែកញែកទី ២ : លោកុប្បត្តិ ៨::២១ “ចិត្តមនុស្សនោះអាក្រក់តាំងពីក្មេងមក”។ ហើយសូមមើលផងដែរនៅក្នុងលោកុប្បត្តិ ៦:៥ “គំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ច”។**

អ្នកព្យាយាមគេចពីអត្ថន័យដ៏ងាយយល់នៃអត្ថបទនេះ ដោយនិយាយថា មានភាពទំនងជាកើតឡើងនៃសេចក្តីអាក្រក់នៅក្នុងមនុស្សភាគច្រើន ប៉ុន្តែភាពទំនងជាកើតឡើងនេះមិនឯកយកសេរីភាពនៃឆន្ទៈចេញពីពួកគេទេ។

ប៉ុន្តែព្រះមានបន្ទូលនៅត្រង់នេះថា អំពីមនុស្សទាំងអស់ មិនមែនគ្រាន់តែមនុស្សភាគច្រើននោះទេ។ បន្ទាប់ពីទឹកជំនន់ ព្រះមានបន្ទូលថា ទ្រង់នឹងមិនប្រព្រឹត្តិចំពោះមនុស្សតាមការដែលគេសមទទួលនោះទៀតទេ។ ប្រសិនបើទ្រង់ធ្វើយ៉ាងដូច្នេះ នោះគ្មានអ្នកណាអាចទទួលបានសេចក្តីសង្គ្រោះឡើយ។ ទាំងមុនទាំងក្រោយទឹកជំនន់ ព្រះបានប្រកាសថា មនុស្សទាំងអស់សុទ្ធតែអាក្រក់ មិនគ្រាន់តែមនុស្សខ្លះប៉ុណ្ណោះទេ។ អ្នកហាក់ដូចជាគិតអំពើបាបនៅក្នុងមនុស្ស ថាជារឿងតិចតួច ជារឿងដែលអាចជួសជុលបានដ៏ងាយស្រួល។ ប៉ុន្តែអត្ថបទនិយាយថា គ្រប់ទាំងថាមពលនៃឆន្ទៈរបស់មនុស្ស គឺដើម្បីធ្វើតែការអាក្រក់ប៉ុណ្ណោះ។ ហេតុអ្វីបានជាអ្នកមិនសួរយោបល់ពីគម្ពីរហេព្រើរ? តាមការពិតលោក ម៉ូសេ និយាយថា៖ “ការអាក្រក់របស់មនុស្ស បានចំរើនជាច្រើនឡើងនៅផែនដី ហើយអស់ទាំង

គំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ច” (លោកុប្បត្តិ ៦:៥)។ នេះមិនមែនជាភាពទំនងជាកើតឡើងនៃសេចក្តីអាក្រក់ទេ។ ព្រះមានបន្ទូលអ្វីទាំងអស់ ប៉ុន្តែសេចក្តីអាក្រក់ត្រូវបានគិត និងស្រមើស្រមៃ ដោយមនុស្សពេញមួយជីវិតរបស់ពួកគេ។ ប៉ុន្តែអ្នកនឹងឆ្លើយតបថាៈ “អញ្ចឹងហេតុអ្វីបានជាព្រះទុកពេលឲ្យសំរាប់ការប្រែចិត្ត បើអំណាចរបស់មនុស្សមិនអាចប្រែចិត្តបានផងនោះ?” ចម្លើយគឺដូចអ្វីដែលយើងបាននិយាយជាញឹកញាប់មកហើយ គឺថា ការបង្គាប់របស់ព្រះ មិនមានន័យសំដៅពីអំណាចក្នុងការធ្វើតាមនោះទេ។ ព្រះមានបន្ទូលប្រាប់ពីកាតព្វកិច្ចរបស់យើង មិនមែនបង្ហាញថា យើងអាចធ្វើវាបាននោះទេ ប៉ុន្តែដើម្បីឲ្យយើងបន្ទាបខ្លួន ហើយសារភាពថា យើងមិនអាចធ្វើបានវិញ!

## ការវែកញែកទី ៣ : គម្ពីរអេសាយ ៤០:១-២

“ចូរកំសាន្តទុក្ខ ចូរកំសាន្តទុក្ខរាស្ត្រចុះ ត្រូវឲ្យលួងលោមចិត្តនៃក្រុងយេរូសាឡិម ហើយស្រែកប្រាប់គេថា គ្រាធ្វើសឹកសង្គ្រាមរបស់គេបានសំរេចហើយ អំពើទុច្ចរិតរបស់គេក៏បានអត់ទោសឲ្យ ហើយគេបានទទួលមួយជាពីរពីព្រះហស្តនៃព្រះយេហូវ៉ា ឲ្យស្នងនឹងអំពើបាបគេដែរ”

អត្ថបទនេះមានន័យថា ការអត់ទោសរបស់ព្រះត្រូវបានប្រទានមកដល់ពួកអ្នកដែលគ្មានសមត្ថភាពរកឲ្យបានការអត់ទោសនោះទាល់តែសោះ ឬដើម្បី

ធ្វើល្អនៅក្នុងរបៀបណាមួយបានទាល់តែសោះ។ តែអ្នកមិនយល់ព្រមអញ្ចឹងទេ។ អ្នកនិយាយថា អត្ថបទនេះមានន័យថា ការសងសឹករបស់ព្រះលើអំពើបាបយើង មិនមែនព្រះគុណទ្រង់ទេ។ ប៉ុន្តែនៅពេលដែលខ្ញុំត្រឡប់ទៅឯគម្ពីរសញ្ញាថ្មីវិញ ខ្ញុំឃើញថា អត្ថបទនេះនិយាយអំពីការអត់ទោសរបស់ព្រះសំរាប់អំពើបាប ត្រូវបានប្រកាសប្រាប់ដោយដំណឹងល្អ! ចូរយើងក្រឡេកមើលអត្ថបទនេះទាំងអស់គ្នា។

ខ្ញុំគិតថាពាក្យ "ចូរកំសាន្តទុក្ខ" មិនមានន័យសំដៅថា ជាដំណើរការជំនុំជំរះរបស់ព្រះនោះទេ! បន្ទាប់មកខនេះចែងថា "ត្រូវឲ្យលួងលោមចិត្តនៃក្រុងយេរូសាឡិម"។ ពាក្យនេះចង់និយាយថា "ចូរនិយាយទៅកាន់ចិត្តនៃក្រុងយេរូសាឡឹម គឺនិយាយពាក្យនៃសេចក្តីស្រឡាញ់ ជាពាក្យផ្អែមល្ហែម ពាក្យដ៏សប្បុរស។ បន្ទាប់មក "គ្រាធ្វើសឹកសង្គ្រាម" មានន័យថា ជាបន្ទុកដ៏ធ្ងន់នៃការតស៊ូខំឲ្យបានទទួលការអត់ទោស ដោយការស្តាប់បង្គាប់តាមក្រិត្យវិន័យ (សូមមើលគម្ពីរកិច្ចការ ១៥:៧-១០)។ គ្រាធ្វើសឹកសង្គ្រាមនោះត្រូវបានបញ្ចប់ដោយព្រោះតែការអត់ទោសដោយឥតគិតថ្លៃរបស់ព្រះ។ មនុស្សបានទទួល "មួយជាពីរ" ពីព្រះហស្តរបស់ព្រះ នោះមានន័យសំដៅពីជំងឺនៃអំពើបាប និងការដោះលែងឲ្យរួចពីបន្ទុកដ៏ធ្ងន់នៃក្រិត្យវិន័យ។ ហើយជំងឺ និងការដោះលែងនេះគឺមកពី "អំពើបាប" របស់ពួកគេ មានន័យថា ពួកគេទាំងអស់សុទ្ធតែមានអំពើបាប ហើយមិនអាចធ្វើអ្វីទាំងអស់ក្រៅពីធ្វើបាប។ ព្រះគុណមិនមែនជារង្វាន់នៃការខំប្រឹងប្រែងរបស់ "ឆន្ទៈសេរី" ទេ។ ព្រះគុណត្រូវបានប្រទានមក ទោះបីជាមានបញ្ហាអំពើបាបក៏ដោយ ហើយពួកគេទាំងអស់សមទទួល។

**ការកែតម្រូវទី ៩ : គម្ពីរអេសាយ៤០:៦-៧"មនុស្សជាតិ (សាច់ឈាម) ទាំងឡាយ ប្រៀបដូចជាស្មៅ ហើយអំពើល្អទាំងប៉ុន្មាន របស់គេក៏ដូច ជាផ្កានៅទីវាល ឯស្មៅក៏ស្វិតក្រៀមទៅ ហើយផ្ការោយរុះចុះ ដោយព្រោះខ្យល់ "វិញ្ញាណនៃព្រះយេហូវ៉ាបក់មកត្រូវ"**

អ្នកនិយាយថា "វិញ្ញាណ" នៅក្នុងអត្ថបទនេះមានន័យថា កំហឹង ហើយថា "សាច់ឈាម" គឺជាសេចក្ដីកម្សោយរបស់មនុស្សដែលគ្មានអំណាចប្រឆាំងនឹងព្រះ។ ប៉ុន្តែតាមពិតទៅ សេចក្ដីកម្សោយរបស់មនុស្សមានសេចក្ដីក្រោធរបស់ព្រះ គ្មានអ្វីណាផ្សេងទៀតដើម្បីធ្វើឲ្យស្វិតក្រៀម តើវាត្រូវប្រព្រឹត្តិដោយគ្មានការអាណិតចំពោះសេចក្ដីកម្សោយរបស់មនុស្សឬ? តើមិនគួរនឹងលើកវាឡើងទេឬអី?

បន្ទាប់មកអ្នកនិយាយថា "ផ្កានៅទីវាល" តំណាងឲ្យ សិរីល្អដែលមកពីភាពចំរុងចំរើនខាងផ្នែកសំភារៈ។ ប៉ុន្តែការនេះមិនអាចត្រឹមត្រូវបានទេ។ ពួកយូដាថ្វាយសេរីល្អដល់ព្រះវិហារ ដល់ការកាត់ស្បែក និងយញ្ញបូជា។ ពួកក្រិក គេថ្វាយសិរីល្អដល់ប្រាជ្ញារបស់ពួកគេ។ ដូច្នេះហើយបានជាហៅវាថា សេចក្ដីសុចរិតនៃការប្រព្រឹត្តិ និងប្រាជ្ញាមនុស្ស ដែលត្រូវបានខ្ចាត់ខ្ចាយ ដោយព្រះវិញ្ញាណបក់ផាត់។ ការនេះត្រូវបានអះអាងដោយគម្ពីរអេសាយ ដែលទាក់ទងនឹង "មនុស្សទាំងឡាយ" (សាច់ឈាមទាំងអស់)។ មានមនុស្សតែមួយចំនួនប៉ុណ្ណោះថ្វាយសិរីល្អនៅក្នុងការរីកចំរើនខាងសំភារៈ ប៉ុន្តែជាធម្មតា មនុស្សទាំងអស់ថ្វាយសិរីល្អនៅក្នុងទង្វើ និងប្រាជ្ញាមនុស្ស។

នៅចំនុចនេះ វាមានសារៈសំខាន់ណាស់ក្នុងការកត់សំគាល់ គម្ពីរយ៉ូហាន ៣:៦ “របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ”។ អត្ថបទនេះបង្ហាញយ៉ាងច្បាស់ថា អ្វីៗក៏ដោយ ដែលមិនកើតមកពីព្រះវិញ្ញាណរបស់ព្រះ គឺជាសាច់ឈាម។ នេះមិនមានន័យថា សូម្បីតែផ្នែកមួយដ៏ធំរបស់មនុស្សខាងសាច់ឈាម គឺជាសាច់ឈាមទេ។ តាមពិតទៅវាមានន័យថា ការដ៏ល្អបំផុតនៅក្នុងមនុស្សគឺសាច់ឈាម។ វាមានន័យយ៉ាងច្បាស់ថា មនុស្សទាំងឡាយណាដែលគ្មានព្រះវិញ្ញាណគឺជា “សាច់ឈាម” ដូច្នេះហើយបានជានាំទៅរកការជំនុំជំរះរបស់ព្រះ។

អ្នកគិតថា ការនេះមិនពិត។ អ្នកគិតថា មានមនុស្សខ្លះសុខចិត្តស្លាប់មួយពាន់ដងជាជាងប្រព្រឹត្តិការដ៏អាក្រក់ម្តង ទោះបីជាគ្មានអ្នកណាទៀតដឹងពីវាក៏ដោយ ហើយព្រះនឹងអត់ទោសឲ្យវា។ ប៉ុន្តែអ្នកនៅតែមើលកិច្ចការខាងក្រៅដដែល។ អ្នកត្រូវតែមើលចិត្តវិញ។ ទោះបីជាមានមនុស្សប្រភេទនេះក៏ដោយ តែអាកប្បកិរិយារបស់ពួកគេនាំសិរីល្អដល់តែខ្លួនឯង ពីព្រោះតែដាច់ចេញពីព្រះវិញ្ញាណ ពួកគេគ្មានបំណងចិត្តដើម្បីនឹងថ្វាយសិរីល្អដល់ព្រះ ដោយសកម្មភាពរបស់ពួកគេឡើយ។

អ្នកក៏សួរផងដែរថា អ្វីៗដែលហៅថា “សាច់ឈាម” តើចាំបាច់ត្រូវហៅវាថា ទមិឡល្មើស បានដែរឬទេ។ ខ្ញុំឆ្លើយថា បាទ។ មនុស្សម្នាក់ជាមនុស្សទមិឡប្រសិនបើគ្មានព្រះវិញ្ញាណរបស់ព្រះ។ បទគម្ពីរចែងថា ព្រះវិញ្ញាណត្រូវបានប្រទានមក ដើម្បីរាប់មនុស្សទមិឡល្មើសជាសុចរិត។ ព្រះយេស៊ូវបានមានបន្ទូលថា អ្វីដែលកើតពីសាច់ឈាម មិនអាចឃើញនគរព្រះបានទេ។ គ្មានទីកដីកណ្តាល រវាង

នគរព្រះ និងនគររបស់សាតាំងទេ។ ប្រសិនបើមនុស្សម្នាក់មិននៅក្នុងនគររបស់ព្រះ នោះគាត់ច្បាស់ជានៅក្នុងនគររបស់សាតាំងហើយ។

បន្ទាប់មកអ្នកសួរថា៖ តើខ្ញុំអាចបង្រៀនថា មនុស្សគ្មានអ្វីក្រៅពីសាច់ឈាមដោយរបៀបណា សូម្បីតែពួកគេកើតពីព្រះវិញ្ញាណហើយនោះ? តើអ្នកយល់សប្តិពីការនេះនៅត្រង់ណា? ខ្ញុំទាញភាពផ្សេងគ្នាដ៏ជាក់ច្បាស់មួយរវាង “សាច់ឈាម” និង “ព្រះវិញ្ញាណ”។ មនុស្សម្នាក់ដែលមិនកើតពីព្រះវិញ្ញាណគឺជាសាច់ឈាម។ មនុស្សម្នាក់ដែលកើតពីព្រះវិញ្ញាណគឺជាវិញ្ញាណវិញ លើកលែងតែសមាសធាតុនានានៃសាច់ឈាមដែលជាប់នៅប៉ុណ្ណោះ ដែលធ្វើឲ្យគាត់មានបញ្ហា។

## ការវែកញែកទី ៥ : គម្ពីរយេរេមា ១០:២៣ “ឱព្រះយេហូវ៉ាអើយ ទូលបង្គំដឹងថា ផ្លូវរបស់មនុស្សមិនស្រេចនៅខ្លួនគេទេ ហើយដែលដំរង់ជំហាន របស់ខ្លួន នោះក៏មិនស្រេចនៅមនុស្សដែល ដើរដែរ”។

នៅត្រង់នេះអ្នកបានមូលបង្កុសពីអត្ថន័យដ៏ងាយយល់នៃអត្ថបទនេះម្តងទៀត។ អ្នកនិយាយថា វាមានន័យថា ព្រះ គឺមិនមែនមនុស្សទេ ដែលបណ្តាលឲ្យព្រឹត្តិការណ៍នានា មានលទ្ធផលសប្បាយរីករាយ ហើយថា គ្មានអ្វីទាក់ទងជាមួយនឹង “ឆន្ទៈសេរី”។ តើពាក្យរបស់លោកយេរេមា ត្រូវការពន្យល់ដែរឬទេ? តាមពិតទៅ លោក យេរេមា គ្រាន់តែនិយាយសំដៅថា ការរឹងចចេសរបស់មនុស្សក្នុងការបដិសេធមិនទទួលព្រះបន្ទូលព្រះធ្វើឲ្យគាត់ជឿថា មនុស្សមិនអាចធ្វើល្អដោយ

អំណាចខ្លួនឯងបានឡើយ។

ប៉ុន្តែឧបមាថា គំនិតរបស់អ្នកត្រូវចុះ។ អញ្ចឹង តើការល្អអ្វីដែលវាធ្វើ? ប្រសិនបើ មនុស្សម្នាក់មិនអាចធ្វើឲ្យព្រឹត្តិការណ៍តាមធម្មជាតិត្រឡប់ជាសប្បាយរីករាយផង តើគាត់អាចធ្វើអ្វីមួយ អំពីវាសនាខាងព្រលឹងវិញ្ញាណរបស់គាត់បានដោយរបៀបណា?

អ្នកបានវែកញែកថា មនុស្សជាច្រើនដឹងពីតំរូវការរបស់ពួកគេ គឺជាព្រះគុណរបស់ព្រះ ដើម្បីរស់នៅដោយត្រឹមត្រូវ ហើយពួកគេប្រដេញតាមការនេះដោយការអធិស្ឋានជារៀងរាល់ថ្ងៃ ដើម្បីសូមជំនួយពីព្រះ។ ហើយអ្នកថា ដោយការធ្វើអញ្ចឹង មានន័យថា ពួកគេប្រើការប្រឹងប្រែងរបស់មនុស្ស។ ប៉ុន្តែអ្នកមិនកំពុងតែបង្ហាញពីអំណាចនៃ “ឆន្ទៈសេរី” ទេ។ ក្រៅពីពួកអ្នកដែលមានព្រះវិញ្ញាណរបស់ព្រះគង់ជាមួយ តើអ្នកណានឹងចង់សូមជំនួយពីព្រះ? អ្នកដែលអធិស្ឋាន ជាអ្នកដែលអធិស្ឋានដោយព្រះវិញ្ញាណ (រ៉ូម ៨:២៦-២៧)។

## ការវែកញែកទី ៦ : គម្ពីរសុភាសិត ១៦:១ “គំនិតដែលចាត់ចែងនៅក្នុងចិត្ត នោះស្រេចនៅមនុស្ស តែគឺព្រះយេហូវ៉ាដែលឆ្លើយសំរេចការនោះ វិញ”

អ្នកត្រូវការការនេះម្តងទៀត ដើម្បីនិយាយមានន័យសំដៅទៅព្រឹត្តិការណ៍ធម្មតានៃជីវិត។ ជាថ្មីម្តងទៀតខ្ញុំសូមឆ្លើយថា ទោះបីជាអ្នកនិយាយត្រូវក៏ដោយ តែវាធ្វើឲ្យកាន់តែមិនទំនងឡើង ដែលយើងអាចសំរេចជោគវាសនាខាងព្រលឹងវិញ្ញាណ

សំរាប់ខ្លួនឯង នោះ។ តាមការពិតទៅ អ្វីៗគ្រប់យ៉ាងនៅពេលអនាគត ដែលព្រះនឹងសំរេច គួរបង្កើតឲ្យមានការភ័យខ្លាចមួយដល់ព្រះនៅក្នុងយើង។

អ្នកភ្ជាប់អត្ថបទនេះជាមួយអត្ថបទពីរទៀត ដែលដកស្រង់មកពីគម្ពីរសុភាសិតគឺ៖ សុភាសិត ១៦:៤ “ព្រះយេហូវ៉ាទ្រង់បានធ្វើគ្រប់របស់ទាំងអស់ ឲ្យសមនឹងប្រយោជន៍នឹងរបស់នោះឯង អើ ទោះទាំងមនុស្សអាក្រក់ក៏បានកើតមកសំរាប់ថ្ងៃនៃសេចក្តីអាក្រក់ដែរ”។ អ្នកធ្វើបានយ៉ាងល្អ ក្នុងការចង្អុលបង្ហាញថាការនេះមិនមានន័យថា ព្រះបានបង្កើតអ្វីៗមកឲ្យអាក្រក់ទេ។ អ្នកនិយាយបានល្អមែន! តែខ្ញុំមិនដែលនិយាយថា ទ្រង់ធ្វើអញ្ចឹងទេ!

សុភាសិត ២១:១ “ព្រះទ័យនៃស្តេច នោះនៅក្នុងព្រះហស្តព្រះយេហូវ៉ាដូចជាផ្លូវនៃទឹកហូរទាំងឡាយ ទ្រង់ឲ្យបែរហូរទៅខាងណាក៏តាមតែព្រះហឫទ័យ”

អ្នកនិយាយថា ពាក្យថា “បែរឲ្យហូរទៅ” មិនមានន័យថា “បង្ខំ” នោះទេ។ អ្នកនិយាយថា ស្តេចនោះត្រូវបានបំបែរទៅក្នុងសេចក្តីអាក្រក់ ដោយព្រះអនុញ្ញាតឲ្យ ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ប៉ុន្តែវាមិនមែនជាបញ្ហា ដែលអ្នកគិតថា ជាការអនុញ្ញាតរបស់ព្រះ ឬជាបំណងព្រះហឫទ័យរបស់ព្រះនោះទេ វានៅតែជាពិតដែលថា គ្មានអ្វីណាមួយដែលកើតឡើងក្រៅពីបំណងព្រះហឫទ័យ និងកិច្ចការនៃព្រះឡើយ។ អត្ថបទនេះសំដៅទៅមនុស្សម្នាក់ គឺជាស្តេចនោះឯង។ ប្រសិនបើវាពិតអំពីមនុស្សម្នាក់ វាក៏ពិតសំរាប់មនុស្សទាំងអស់ដែរ។

**ការរែកញែកទី ៧ : យ៉ូហាន ១៥:៥ "ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើត ផលឡើងជាច្រើន ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាច នឹងធ្វើអ្វីបានទេ"**

នេះគឺជាអត្ថបទដែលខ្ញុំបាននិយាយថា គ្មានអ្នកណាម្នាក់អាចគេចវេសបាន ប៉ុន្តែអ្នកតោងជាប់នឹងពាក្យដ៏តូចមួយ "គ្មានអ្វីណាមួយ" ហើយកាត់បំពង់ករបស់វា! អ្នកនិយាយថា វាអាចមានន័យថា "គ្មានអ្វីឲ្យគ្រប់លក្ខណ៍" ដូច្នេះហើយក៏និយាយថា "ដាច់ចេញពីខ្ញុំ អ្នកមិនអាចធ្វើអ្វីឲ្យគ្រប់លក្ខណ៍បានទេ"។ សំនួរគឺ មិនថាតើអត្ថបទនេះអាចមានន័យអញ្ចឹងនោះទេ ប៉ុន្តែ ថាតើអត្ថបទនេះពិតជាមានន័យអញ្ចឹងមែនទេ។ អ្នកនិយាយថា អត្ថបទនេះ មានន័យថា បើគ្មានព្រះគ្រីស្ទ យើងអាចធ្វើ "ការដែលមិនគ្រប់លក្ខណ៍តូចមួយ"។ ដូច្នេះ នៅពេលដែលគម្ពីរយ៉ូហាន ១:៣ ចែងថា "គ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ" នោះវាមានន័យថា "ក្រៅពីទ្រង់ ការដែលមិនគ្រប់លក្ខណ៍តូចមួយកើតមក" ហើយអញ្ចឹង! នេះគឺជាការល្ងីល្ងើមែន! វាពិតជាមានគ្រោះថ្នាក់មែន ដែលបកស្រាយបទគម្ពីរបែបនេះ។ ហើយវាគ្មានផ្លូវទៅដល់បញ្ញាចិត្តរបស់មនុស្សបានទេ។ សូមបកស្រាយឲ្យវាមានន័យយ៉ាងដូច្នេះវិញគឺ ពាក្យថា "គ្មានអ្វីណាមួយ" មានន័យថា "គ្មានអ្វីណាមួយ"។ នៅក្រោមការគ្រប់គ្រងរបស់អារក្សសាតាំង បំណងចិត្ត (ឆន្ទៈ) របស់មនុស្សមិនមានសេរីភាពទៀតទេ ហើយក៏មិននៅក្នុងអំណាចរបស់វាផ្ទាល់ដែរ ប៉ុន្តែជាទាសកររបស់អំពើបាប និងរបស់អារក្សសាតាំងវិញ ហើយមានបំណងចិត្តចង់តែធ្វើតាមអ្វីដែលស្តេចរបស់វាចង់ធ្វើប៉ុណ្ណោះ។ អ្នកមិនបានអើពើនូវអ្វីដែលនៅ

ពីក្រោយអត្ថបទនេះ គឺថា "បើអ្នកណាមិននៅជាប់នឹងខ្ញុំ អ្នកនោះត្រូវបោះចោលទៅខាងក្រៅ ហើយក៏នៅក្រៀមទៅ ដូចជាខ្នែងដែរ រួចគេប្រមូលបោះទៅក្នុងភ្លើងឆេះអស់ទៅ" (ខ ៦)។ មនុស្សដែលមិនមែនជារបស់ព្រះគ្រីស្ទ គឺមិនអាចទទួលយកបាននៅចំពោះព្រះ ហើយមិនតែប៉ុណ្ណោះអ្នកនោះត្រូវបោះទៅក្នុងភ្លើងទៀត។

ខ្ញុំមិនអាចយល់ពីមូលហេតុ ដែលអ្នកដកស្រង់ពី ១កូរិនថូស ១៣:២ ដើម្បីគាំទ្រករណីរបស់អ្នកបានទេ។ "បើខ្ញុំចេះអធិប្បាយ ហើយស្គាល់អស់ទាំងសេចក្តីអាថ៌កំបាំង និងគ្រប់ទាំងចំណេះវិជ្ជា ហើយបើខ្ញុំមានគ្រប់ទាំងសេចក្តីជំនឿល្មមនឹងឲ្យភ្នំរើចេញបាន តែគ្មានសេចក្តីស្រឡាញ់ នោះខ្ញុំមិនជាអ្វីទេ"។ បើអ្នកណាមួយគ្មានសេចក្តីស្រឡាញ់ អ្នកនោះពិតជាគ្មានន័យអ្វីទាំងអស់នៅចំពោះព្រះ ដ្បិតសេចក្តីស្រឡាញ់ជាអំណោយទាននៃព្រះគុណ។ សរុបសេចក្តីមកគឺយ៉ាងនេះថា "គ្មានអ្វីណាមួយ" មានន័យថា គ្មានអ្វីណាមួយ ហើយ "គ្មានអ្វីណាមួយ" អាចផ្លាស់ប្តូរការនោះឬ! បើគ្មានព្រះគុណ មនុស្សម្នាក់មិនអាចធ្វើអ្វីបានទាំងអស់។ "ឆន្ទៈសេរី" មិនអាចធ្វើអ្វីបានទាំងអស់ ហើយវាគ្មានអ្វីទាំងអស់។

## ការរែកញែកទី ៨ : ការសហការរបស់មនុស្សជាមួយនឹងព្រះ មិនបង្ហាញពី "ឆន្ទៈសេរី" ទេ

អ្នកប្រើរូបភាពជាច្រើន ដែលពិពណ៌នាពីការសហការរបស់មនុស្សជាមួយនឹងប្រតិបត្តិការរបស់ព្រះ។ ឧទាហរណ៍៖ "កសិករប្រមូលផល តែព្រះបានប្រទានឲ្យ

វិញ”។ ពិតមែនហើយខ្ញុំដឹងពីការសហការរបស់មនុស្សជាមួយព្រះ តែការនេះ គ្មានអ្វីណាមួយ បង្ហាញពី “ឆន្ទៈសេរី” ទេ។ ព្រះទ្រង់មានសព្វានុភាព។ ទ្រង់គ្រប់គ្រងអ្វីៗទាំងអស់ដែលព្រះបានបង្កើតមក។ ហើយការនេះ រាប់បញ្ចូលទាំងពួកទមិឡល្មើស និងពួកអ្នកដែលព្រះបានរាប់ជាសុចរិត ហើយនាំមកនគររបស់ទ្រង់ផងដែរ ដែលពួកគេសហការជាមួយព្រះនៅផែនដីនេះ។ មនុស្សទាំងអស់ត្រូវតែធ្វើតាម និងស្តាប់បង្គាប់នូវអ្វីដែលព្រះសព្វព្រះហឫទ័យឲ្យពួកគេធ្វើ។

មនុស្សគ្មានចំណែកណាមួយក្នុងការបង្កើតរបស់ខ្លួនឡើយ។ ហើយជាអ្នកដែលព្រះបានបង្កើតមក មនុស្សគ្មានចំណែកណាមួយក្នុងការបន្តការរស់នៅ ក្នុងនាមជាស្នាព្រះហស្តបង្កើតរបស់ព្រះទេ។ ទាំងការបង្កើត និងការធ្វើឲ្យការបង្កើតនោះមានជីវិត គឺជាទំនួលខុសត្រូវទាំងស្រុងនៃអំណាចគ្រប់គ្រង និងសេចក្តីសប្បុរសរបស់ព្រះ ដែលទ្រង់បានបង្កើត ហើយថែរក្សាយើងដោយគ្មានជំនួយណាមួយពីយើងឡើយ។

មុនពេលដែលមនុស្សបានកើតជាថ្មីឡើង នៅក្នុងការបង្កើតថ្មីក្នុងនគររបស់ព្រះវិញ្ញាណ មនុស្សមិនបានរួមចំណែកណាមួយដើម្បីរៀបចំខ្លួន សំរាប់ការកើតជាថ្មី និងនគរថ្មីនោះទេ។ ស្រដៀងគ្នានោះដែរ នៅពេលដែលមនុស្សត្រូវបានបង្កើតមកជាថ្មី មនុស្សមិនបានរួមចំណែកក្នុងការថែរក្សាភាពជាថ្មីនោះនៅក្នុងនគរទ្រង់ឡើយ។ ព្រះវិញ្ញាណ បង្កើតយើងជាថ្មី និងថែរក្សាយើង ពេលយើងកើតជាថ្មី ដោយគ្មានជំនួយណាមួយពីយើងឡើយ។ ដូចជាគម្ពីរយ៉ាកុបបានថែងថា “ទ្រង់បានបង្កើតយើងរាល់គ្នាមកតាមព្រះហឫទ័យទ្រង់ ដោយសារព្រះបន្ទូល

ដ៏ពិត ប្រយោជន៍ឲ្យយើងបានបែបដូចជាផលដំបូង ក្នុងរបស់ទាំងប៉ុន្មានដែលទ្រង់បង្កើតមក” (យ៉ាកុប ១:១៨)។ (លោក យ៉ាកុប កំពុងតែនិយាយពីការកើតជាថ្មី)។ ប៉ុន្តែព្រះមិនបង្កើតយើងជាថ្មី ដោយមិនឲ្យយើងស្គាល់ពីការនោះទេ ដ្បិតព្រះបង្កើតយើងជាថ្មី ហើយនិងថែរក្សាយើងរាល់គ្នាសំរាប់គោលបំណងនេះឯង យ៉ាងនោះយើងអាចនឹងសហការជាមួយព្រះបាន។

ហើយតើអ្វីជាចំណែករបស់ “ឆន្ទៈសេរី” នៅក្នុងការទាំងអស់នេះ? តើវាចំណែកអ្វីដែរឬទេ? គ្មានទេ! គ្មានអ្វីទាំងអស់!

## សេចក្តីសន្និដ្ឋាន

នៅក្នុងការទាស់ប្រឆាំងនេះ ខ្ញុំមិនចង់បង្កើតកម្តៅ ជាជាងបង្កើតពន្លឺនោះទេ។ ប៉ុន្តែប្រសិនបើខ្ញុំរែកញែកអ្វីណាមួយខ្លាំងពេក នោះខ្ញុំនឹងទទួលស្គាល់កំហុសរបស់ខ្ញុំ ប្រសិនបើវាជាកំហុសមែន។ ប៉ុន្តែទេ ខ្ញុំមានការដឹងប្រាកដមួយថា ទីបន្ទាល់របស់ខ្ញុំនេះ នាំមកឯលោកិយកាន់តែបន្ទាន់ឡើង នៅក្នុងបុព្វហេតុនៃព្រះ។ សូមឲ្យព្រះជាម្ចាស់បញ្ជាក់ពីទីបន្ទាល់នេះនៅថ្ងៃចុងក្រោយចុះ! នៅពេលដែលខ្ញុំត្រូវបានគាំទ្រដោយទីបន្ទាល់នៃអ្នកឯទៃទៀត ក្នុងបុព្វហេតុការពារសេចក្តីពិត ដោយមិនខ្ជិលច្រអូស ឬដោយការបោកប្រាស់ ប៉ុន្តែដោយការខំប្រឹងប្រែងវិញ។ ពេលនោះ តើអ្នកណានឹងរីករាយជាងខ្ញុំ!

ប្រសិនបើខ្ញុំហាក់ដូចជាជូរចត់ចំពោះអ្នកពេក សូមអត់ទោសឲ្យខ្ញុំផង។ ខ្ញុំមិនបាន

ធ្វើអញ្ជើងដោយចេញពីបំណងអាក្រក់ទេ ប៉ុន្តែគ្រាន់តែព្រួយបារម្ភថា ក្រែងលោអ្នកកំពុងតែបំផ្លាញបុព្វហេតុដើម្បីព្រះគ្រីស្ទ ដោយទម្ងន់នៃឈ្មោះរបស់អ្នកវិញ។ ហើយតើអ្នកណាតែងតែអាចគ្រប់គ្រងបិចរបស់ខ្លួនបាន ខណៈដែលមិនមែនជាឱកាសដើម្បីបង្ហាញភាពកត់ក្ដៅនោះ? សូម្បីតែអ្នក ជារឿយៗអ្នកក៏គប់ព្រួញភ្លើងដាក់ខ្ញុំដែរ។ ប៉ុន្តែការទាំងអស់នេះ មិនជះឥទ្ធិពលនៅក្នុងការវែកញែកនេះទេ ហើយយើងដែលពាក់ព័ន្ធនឹងការវែកញែកនេះ ត្រូវតែអត់ទោសឲ្យគ្នាទៅវិញទៅមក ដ្បិតយើងគ្រាន់តែជាមនុស្ស ហើយគ្មានអ្វីនៅក្នុងយើង ក្រៅពីលក្ខណៈរបស់មនុស្សនោះទេ។ សូមឲ្យព្រះជាម្ចាស់ដែលបណ្ដាលការនេះ បានបើកភ្នែករបស់យើង ហើយជួយអ្នកដើម្បីថ្វាយសិរីល្អដល់ទ្រង់។ អាម៉ែន។

# សេចក្តីបន្ថែម

## ប្រវត្តិសាស្ត្រក្រោយមកនៃការមិនចុះសម្រុងគ្នា និងសារៈសំខាន់របស់វា

តើអ្នកអាននៅសតវត្សទី២០គិតយ៉ាងដូចម្តេច ពីការមិនចុះសម្រុងគ្នា ដែលនៅពីក្រោយសៀវភៅ “ចំណងនៃឆន្ទៈ” របស់លូសើរ? នៅពេលអ្នកបាន អានសៀវភៅបង្រួមដ៏ងាយយល់នេះហើយ អ្នកច្បាស់ជាកោតសរសើរចំពោះ សមត្ថភាពក្នុងការវែកញែក ដ៏ពូកែរបស់គាត់។ ប៉ុន្តែអ្វីដែលយើងផ្តោតសំខាន់នោះ គឺថាតើករណីរបស់គាត់ជាការវែកញែកតាមបទគម្ពីរឬយ៉ាងណា។ ប្រសិនបើអ្វីដែល គាត់បានសរសេរគឺជាសេចក្តីបង្រៀននៃព្រះបន្ទូលរបស់ព្រះ នោះយើងត្រូវតែធ្វើ ការកត់សំគាល់វានៅពេលបច្ចុប្បន្ននេះ។

មនុស្សជាច្រើននឹងសន្និដ្ឋានថា អ្វីដែលលូសើរបានសរសេរគ្រាន់តែជា អ្វីមួយដែលគេហៅថា លទ្ធិខាលវិន ហើយពួកគេនឹងមិនទទួលបានប្រយោជន៍អ្វី ទាំងអស់ពីវា។ ពួកជំនុំលូសើរនៅពេលបច្ចុប្បន្ននេះហាក់ដូចជាគ្រាន់តែធ្វើអញ្ចឹង ហើយងាយយល់ណាស់ ដែលគ្រីស្ទានជាច្រើននៅសព្វថ្ងៃនេះ នឹងធ្វើដូចគ្នាអញ្ចឹង ដែរ។

ប្រសិនបើយើងមើលទៅឯសម័យកែទម្រង់ នោះយើងឃើញយ៉ាង ច្បាស់ថា ពួកមេដឹកនាំប្រឆាំងដូចជា លូសើរ ស្វីងគ្លី ខាលវិន ប៊ូសើរ ប៊ីសា

មេលេនថន ចនណាក្ស ជាដើម។ មនុស្សទាំងអស់នេះសុទ្ធតែឯកភាពថា ដោយនិស្ស័យសាច់ឈាម មនុស្សមិនអាចធ្វើអ្វីបានទាំងអស់ចំពោះសេចក្តីសង្គ្រោះរបស់ខ្លួន ហើយថា ព្រះមានអំណាចគ្រប់គ្រងទាំងស្រុងនៅក្នុងព្រះគុណ។ ពួកកែទម្រង់អាចនឹងមានការខុសគ្នាអំពីអ្វីផ្សេងទៀត ប៉ុន្តែអំពីការនេះវិញ ពួកគេទាំងអស់គ្នាសុទ្ធតែបានឯកភាព។ វាអានឹងត្រឹមត្រូវដែលនិយាយថា នេះគឺជាគោលលទ្ធិគ្រឹះនៃការកែទម្រង់។ ជាញឹកញាប់គេគិតថា គោលលទ្ធិនៃការញែកចេញជាបរិសុទ្ធដោយសេចក្តីជំនឿ ជាសេចក្តីពិតស្នូលនៅក្នុងការសិក្សាវិជ្ជាព្រះបែបកែទម្រង់។ ប៉ុន្តែពួកកែទម្រង់ ដោយបែរទៅរកសេចក្តីបង្រៀនរបស់សាវក ប៉ុល បានផ្តោតសំខាន់ថា សេចក្តីសង្គ្រោះទាំងមូលមួយរបស់មនុស្សមានបាប គឺបានមកដោយសារព្រះគុណដ៏ឥតគិតថ្លៃនៃព្រះតែមួយប៉ុណ្ណោះ។ គោលលទ្ធិនៃការញែកចេញជាបរិសុទ្ធដោយសេចក្តីជំនឿ មានសារៈសំខាន់ ព្រោះវាការពារសេចក្តីបង្រៀនដែលថា មនុស្សជាអ្នកមានបាបដ៏ឥតទីពឹង ហើយបានទទួលសេចក្តីសង្គ្រោះដោយសារតែព្រះគុណរបស់ព្រះប៉ុណ្ណោះ។ ប៉ុន្តែសេចក្តីពិតស្នូលនៃការកែទម្រង់ គឺជាសេចក្តីពិតដែលព្រះគុណរបស់ព្រះមានអំណាចគ្រប់គ្រងទាំងអស់ និងឥតគិតថ្លៃ។

ការប្រឆាំងទៅនឹងគោលជំហរដែលធ្វើឡើងដោយរបស់ពួកកែទំរង់ មិនដែលឈប់មួយរយភាគរយឡើយ។ វាកាន់ឆេះបំភ្លឺអោយកាន់តែឃើញច្បាស់ពីជំនឿខុសឆ្គងរបស់ពួកជឿលើសេចក្តីបង្រៀនអាមីនាស ដែលបដិសេធថាមនុស្សគ្មានជំនួយអ្វីទាំងអស់ ហើយវែកញែកថា សេចក្តីសង្គ្រោះពិតជាពឹងនៅលើអ្វីម្យ៉ាងដែលយើងធ្វើសំរាប់ខ្លួនឯង។ ការទាំងអស់នេះត្រូវបានបង្រៀនដោយបុរស

ម្នាក់ឈ្មោះ វ៉ាន់ បាមិន (អ្នកជឿលើសេចក្តីបង្រៀនអាមីនាស) ដែលក្លាយជាសាស្ត្រាចារ្យវិជ្ជាព្រះគម្ពីរនៅឯសាកលវិទ្យាល័យ Leyden នៅប្រទេសនីសើលែន នាឆ្នាំ ១៦០៣។ នៅឆ្នាំ ១៦១៨ មហាសន្និបាតអន្តរជាតិមួយត្រូវបានធ្វើឡើងនៅ Dortrecht (Dort) ដែលមានរយៈពេល៦ខែ។ សេចក្តីបង្រៀនរបស់អាមីនាស និងពួកអ្នកដើរតាមគាត់ ត្រូវបានបដិសេធនិងកាត់កាល់ចោល។

សេចក្តីបង្រៀនអាមីនាសមិនបានស្លាប់ជាមួយ Synod of Dort ទេ។ វានៅតែរស់នៅហើយមានសកម្មភាព។ John Wesleyធ្វើអោយវាកាន់តែពេញនិយមឡើង ហើយវានៅតែពេញនិយម។ អ្វីដែលសេចក្តីបង្រៀនរបស់អាមីនាស បានធ្វើគឺបែងចែកសេចក្តីសង្គ្រោះនៃមនុស្សមានបាប រវាងព្រះជាម្ចាស់ និងមនុស្សមានបាបផ្ទាល់។ គេនិយាយថា មានផ្នែកនៃសេចក្តីសង្គ្រោះដែលជាកិច្ចការរបស់ព្រះ និងផ្នែកដែលអ្នកមានបាបផ្ទាល់ត្រូវធ្វើសំរាប់ខ្លួនឯង។ សេចក្តីបង្រៀនរបស់ព្រះគម្ពីរ ជាអ្វីដែលពួកកែទំរង់បានឯកភាព ថ្វាយដល់ព្រះគ្រប់ទាំងសិរីល្អទាំងអស់នៅក្នុងសេចក្តីសង្គ្រោះរបស់យើង។ សេចក្តីសង្គ្រោះ ពឹងលើព្រះគុណដ៏មានអំណាចគ្រប់គ្រងរបស់ព្រះជាម្ចាស់ ដែលជាកិច្ចការដ៏គ្រប់លក្ខណ៍ហើយពេញលេញរបស់ព្រះគ្រីស្ទ ព្រមទាំងកិច្ចការដ៏មានប្រសិទ្ធភាព និងគ្រប់អំណាចព្រះចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ។ ព្រះជាម្ចាស់ទទួលគ្រប់ទាំងសិរីល្អគឺថា "សេចក្តីសង្គ្រោះគឺជារបស់ព្រះអម្ចាស់"។

សេចក្តីបង្រៀនរបស់អ្នកជឿលើសេចក្តីបង្រៀនអាមីនាស អំពីសេចក្តីសង្គ្រោះ មានលក្ខណៈប្រហាក់ប្រហែលនឹងសេចក្តីបង្រៀនរបស់Romeដែរ ដ្បិត

សេចក្តីបង្រៀនទាំងពីរសុទ្ធតែថា ព្រះជាម្ចាស់មិនអាចសង្គ្រោះមនុស្សមានបាបបានទេ បើគ្មានការសហការ! (ប្រសិនបើការសហការរបស់មនុស្សមានបាបពិតជាសំខាន់ ចុះតើសុលអ្នកតើស៊ីស បានទទួលសេចក្តីសង្គ្រោះដោយរបៀបណា?) សេចក្តីបង្រៀនរបស់អាមីនាស គឺជាការបដិសេធ និងជាការទាល់ចោលជំនឿគ្រីស្ទាននៅសញ្ញាថ្មីដែលគាំទ្រជំនឿនៃការប្រព្រឹត្តិ។ ការពឹងលើខ្លួនឯងសំរាប់សេចក្តីជំនឿ មិនខុសពីការពឹងលើខ្លួនឯងសំរាប់ការប្រព្រឹត្តិនោះទេ។ មនុស្សបែបនោះក៏ដូចជាអ្នកមិនជឿឯទៃទៀតដែរ។

សៀវភៅដែលលោកអ្នកទើបតែបានអាននេះ គឺនិយាយពីការដ៏សំខាន់ណាស់។ អ្វីដែលលូសើរប្រយុទ្ធដើម្បីការពារ នៅតែត្រូវការការប្រយុទ្ធដើម្បីការពារ។ អ្វីដែលពួកកែទំរង់បានងើបឈរឡើងដើម្បីការពារ នៅតែត្រូវការការងើបឈរដើម្បីការពារ។ លោក លូសើរ ហើយនិងពួកកែទំរង់ឯទៃទៀត ដែលពួកអ្នកដែលត្រូវបានបង្រៀនថា សេចក្តីសង្គ្រោះបានមកដោយសារព្រះគុណ ដែលការបានសំដែងយ៉ាងច្បាស់នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ហើយ។ នៅបច្ចុប្បន្ននេះគ្មានការសំខាន់ណា ដែលសំខាន់ជាងនេះទេ។ អ្វីដែលលូសើរបានសរសេរ នៅតែគេត្រូវការនៅពេលឥឡូវនេះដែរ! ព្រះបន្ទូលរបស់ព្រះមិនដែលហួសសម័យទេ ហើយព្រះជាម្ចាស់នៅតែមកកាន់មានបន្ទូលមកកាន់មនុស្សនៅសព្វថ្ងៃនេះ ដូចជាទ្រង់តែងតែមានបន្ទូលស្រាប់ហើយ។